# ទស្សនាទានស្តីពីវិវាទព្រំដែន
# សមុទ្ររវាងកម្ពុជា-ថៃ

## ក្នុងបរិបទនៃយុទ្ធសាស្ត្រអន្តរជាតិ





ហង់ ជួន ណារ៉ុន



Edition PREAH VIHEAR

២០១២

# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**សារណា**

ដើម្បីទទួលបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកនីតិអន្តរជាតិ និងប្រៀបធៀប

# ទស្សនាទានស្ដីពីខ្សែបន្ទាត់ព្រំដែនសមុទ្រ រវាងកម្ពុជា-ថៃ ក្នុងបរិបទនៃយុត្តសាស្ត្រអន្តរជាតិ

ដោយ **ហង់ ជួន ណារ៉ុន**

**ប្រធានដឹកនាំសារណា**

លោកសាស្ត្រាចារ្យ Vincent TOMKIEWICZ

សាកលវិទ្យាល័យ បារីស ៨ (Paris 8)

**ឆ្នាំសិក្សា ២០១០-២០១២**

**ភ្នំពេញ**

*អង្គហេតុ និងគំនិតដែលលើកឡើងក្នុងសារណានេះគឺជាមតិផ្ទាល់របស់អ្នកនិពន្ធ ។ មតិយោបល់របស់អ្នកនិពន្ធ មិនឆ្លុះបញ្ចាំងពីទស្សនៈរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិឡើយ។*

*សាកលវិទ្យាល័យពុំមានជំហរឯកភាព ឬជំទាស់ទៅនឹងមតិយោបល់ ដែលបានលើកឡើងនៅក្នុងសារណានេះទេ។ មតិយោបល់ទាំងនេះត្រូវចាត់ទុកថាជាមតិយោបល់ផ្ទាល់របស់អ្នកនិពន្ធ ។*

«ព្រំដែនរបស់ប្រជាជនអាតែន(Athéniens) ឬរបស់ប្រជាជនកំប៉ាញនីញៀង (Campaniens) សំដៅដល់ព្រំដែនដែលប្រជាជនក្បែរខាងបែងចែកគ្នាតាមរយៈ ការកំណត់ព្រំដែនឯកជន (SÉNÈQUE, *Des bienfaits, liv. VII, ch. 4.*)។ ជាក់ស្តែង ប្រជាជាតិនីមួយៗ

> ដើម្បីកសាងរាជាណាចក្រមួយ បានកំណត់ព្រំដែនរបស់ខ្លួន និងបានបង្កើតទីក្រុងស្របច្បាប់នៅលើដី។
>
> (SÉNÈQUE, Octavie)»[1].

[1] GROTIUS (H.), *La liberté des mers.* Paris, Imprimerie royale, 1845, p. 37.

# ពាក្យបំព្រួញ និងអក្សរកាត់

| | |
|---|---|
| ADM | ទិនានុប្បវត្តិនៃនីតិសមុទ្រ |
| AFDI | ទិនានុប្បវត្តិបារាំងស្តីពីនីតិអន្តរជាតិ |
| ANC | បណ្ណសាររដ្ឋានជាតិកម្ពុជា |
| CIJ | តុលាការយុត្តិធម៌អន្តរជាតិ |
| CMB | អនុសញ្ញាទីក្រុងម៉ុងតេហ្គោបេយ៍ |
| CNUDM | សន្និសីទអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ |
| CPA | តុលាការមជ្ឈត្តការអចិន្ត្រៃយ៍ |
| JDZ | តំបន់អភិវឌ្ឍន៍រួមគ្នា |
| ONU | អង្គការសហប្រជាជាតិ |
| RCADI | កម្រងឯកសារបង្រៀនរបស់បណ្ឌិតសភានីតិអន្តរជាតិ |
| RGDIP | ទស្សនាវដ្ដីទូទៅស្តីពីនីតិសាធារណៈអន្តរជាតិ |
| SFDI | សង្គមបារាំងដើម្បីនីតិអន្តរជាតិ |
| TIDM | តុលាការអន្តរជាតិទទួលបន្ទុកនីតិសមុទ្រ |
| ZEE | តំបន់សេដ្ឋកិច្ចផ្ដាច់មុខ |

# មាតិកា

**សេចក្តីផ្តើម**……………………………………………………………………………………១

**<u>ភាគទី១</u>**

**វិវាទព្រំដែនសមុទ្ររវាងកម្ពុជា-ថៃ៖ ជម្លោះនៃការកំណត់ព្រំដែនសមុទ្រ**

<u>មាតិកាទី១- ព្រំដែនកម្ពុជា៖ ទំនាក់ទំនងជិតស្និទ្ធរវាងដែនដី និងលំហសមុទ្រ</u>……………..៣៣

*ជំពូកទី១- អនុសញ្ញាស្តីពីព្រំដែនគោកកម្ពុជា-ថៃ*………………………………………………………៣៣

ផ្នែកទី១- អាណាព្យាបាលបារាំង និងសន្ធិសញ្ញាព្រំដែនដែលជាមូលដ្ឋាននៃព្រំដែនគោកកម្ពុជា……………………………………………………………………………………………៣៤

*ជំពូកទី២- ការពង្រីកលំហសមុទ្រកម្ពុជា*……………………………………………………………….៤៩

ផ្នែកទី១ – ឥទ្ធិពលនៃខ្សែបន្ទាត់មូលដ្ឋានកម្ពុជាទៅលើវិសាលភាពនៃលំហសមុទ្រកម្ពុជា……………………………………………………………………………………………

ផ្នែកទី២ – លំហសមុទ្រកម្ពុជា……………………………………………………………………..

<u>មាតិកាទី២- ដើមចមនៃវិវាទព្រំដែនសមុទ្ររវាងកម្ពុជា-ថៃ</u>…………………………………………..

*ជំពូកទី១- ការទាមទារលំហសមុទ្រក្នុងឈូងសមុទ្រថៃពីសំណាក់ប្រទេសថៃដែលជាដើមចមនៃវិវាទ*………………………………………………………………………………………………………

*ជំពូកទី២- ការជំទាស់របស់ភាគីថៃពាក់ព័ន្ធនការពង្រីកលំហសមុទ្រកម្ពុជា*……………………………..

<u>មាតិកាទី៣-តំបន់សមុទ្រត្រួតស៊ីគ្នារវាងកម្ពុជា-ថៃ</u>…………………………………………………………

*ជំពូក១-តំបន់ត្រួតស៊ីគ្នាជាផលវិបាកនៃការទាមទារផ្អែកគតិយុត្តិខុសគ្នារវាងកម្ពុជា-ថៃ*…………………..

**សេចក្តីសន្និដ្ឋានបឋម**………………………………………………………………………………..

# <u>ភាគទី២</u>
# ការកំណត់ព្រំដែនសមុទ្ររវាងកម្ពុជា-ថៃ៖
# ការស្វែងរកដំណោះស្រាយប្រកបដោយសមធម៌

<u>មាតិកាទី១ : ការវិវត្តន៍នៃនីតិស្តីពីការកំណត់ព្រំដែនសមុទ្រ៖ ឆ្ពោះទៅរកសន្តិសុខគតិយុត្តិ និងភាពអាចព្យាករណ៍បានកាន់តែខ្លាំង</u>........................................................................

*ជំពូកទី១-ដំណោះស្រាយប្រកបដោយសមធម៌ ជាគោលដៅនៃការកំណត់ព្រំដែនសមុទ្រ*………………..

*ជំពូកទី២-សង្គតិភាវូបនីយកម្មនៃវិធានក្នុងការកំណត់លំហសមុទ្រ*……………………………………….

<u>មាតិកាទី២ : ការសាកល្បងកំណត់ព្រំដែនសមុទ្រកម្ពុជា-ថៃ ធៀបទៅនឹងវិធានមានស្រាប់</u>…………………………………………………………………………………………….

*ជំពូកទី១-វិធានអនុវត្តចំពោះការកំណត់ព្រំដែនសមុទ្រដែនដី*……………………………………….

ផ្នែកទី១-សមធម្មាយមិនប្រាកដថាជាវិធីសាស្ត្រអនុវត្តដោយស្វ័យប្រវត្តិនោះទេ………………

ផ្នែកទី២-ការពិចារណាទៅលើកាលៈទេសៈសមស្រប និងការប្រើប្រាស់វិធីពិសេសក្នុងការកំណត់ខ្សែព្រំដែនខាងរវាងកម្ពុជា-ថៃ…………………………………………………………..

*ជំពូកទី២ : វិធានអនុវត្តចំពោះការកំណត់ព្រំដែនខ្ពង់រាបបាតសមុទ្រក្នុងឈូងសមុទ្រថៃ*………………..

**សេចក្តីសន្និដ្ឋានបញ្ចប់**……………………………………………………………………………..

**ឧបសម្ព័ន្ធ A1-A3** ………………………………………………………………………………………

**គន្ថនិទ្ទេស**…………………………………………………………………………...

# សេចក្ដីផ្ដើម

អធិបតេយ្យភាពដែនដីគឺជាបញ្ហាមួយដ៏សែនរសើប។ គ្មានប្រទេសណាមួយសុខចិត្តបាត់បង់ទឹកដីរបស់ខ្លួនឡើយ សូម្បីតែមួយចំអាមក៏ដោយ។ ដោយហេតុនេះហើយទើបជម្លោះព្រំដែនសមុទ្រនានាបានកើតឡើង តាំងពីរាប់សតវត្សរ៍មកហើយ។ ជាក់ស្ដែង ការពិភាក្សាស្ដីពីនីតិសមុទ្របានប្រព្រឹត្តទៅនៅដើមសតវត្សរ៍ទី១៧ លើផ្អែកទ្រឹស្ដី និងទស្សនវិជ្ជា រវាងអ្នកច្បាប់ជាតិអង់គ្លេសឈ្មោះ **សេលដេន** (SELDEN) (១៥៨៤-១៦៥៤) ដែលប្រឹងប្រែងការពារយ៉ាងក្លៀវក្លា នូវទស្សនាទានសមុទ្រជារបស់រដ្ឋដែលមានអំណាចជាងគេ *(Mare Clausum)* (១៦៣៥) ដែលជាទស្សនាទានមួយដែលពុំបានផ្អែកលើច្បាប់ ឬសន្ធិសញ្ញាណាមួយឡើយ តែផ្អែកទៅលើកម្លាំងបាយទៅវិញ និងលោក **ហ្ក្រោស្យុស** ជនជាតិហូឡង់ (GROTIUS) (១៥៨៣-១៦៤៥) ដែលជាអ្នកការពារគោលការណ៍សេរីភាពសមុទ្រ *(Mare Liberum)* (១៦០៩)។ លោក GROTIUS បានកត់សម្គាល់ថា ការរកឃើញតែម្យ៉ាងដោយពុំមានការគ្រប់គ្រង និងការកាន់កាប់នោះ ពុំចាត់ទុកថាជាប័ណ្ណកម្មសិទ្ធិឡើយ។ លោកបានសង្កេតឃើញថា៖

«... ការរកឃើញដែលសមនឹងទទួលបានប័ណ្ណកម្មសិទ្ធិ គឺការរកឃើញដែលផ្សាភ្ជាប់ទៅនឹងការគ្រប់គ្រងធ្វើយ៉ាងណាឲ្យវាត្រូវបានចាប់យក ប្រសិនបើវាជាចលនវត្ថុ និងត្រូវបានបោះបង្គោលព័ទ្ធជុំវិញ និងមានការការពារ ប្រសិនបើវាជាអចលនវត្ថុ ដែលយើងមិនអាចអះអាងបានក្នុងករណីជាក់លាក់នេះ...

មិនតែប៉ុណ្ណោះ វាថែមទាំងជាគោលការណ៍មួយ ដែលការរកឃើញផ្ដល់សិទ្ធិតែទៅលើវត្ថុទាំងឡាយ ដែលពុំទាន់មានម្ចាស់ពីមុនមកប៉ុណ្ណោះ»[2]។

លោក GROTIUS បានព្យាយាមបកស្រាយថា ពុំមានបុគ្គល ឬប្រជាជាតិណាមួយអាចយកសមុទ្រ មកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួនបានឡើយ ដោយហេតុថា ទាំងលក្ខណៈ ទាំងបុព្វហេតុប្រយោជន៍សាធារណៈពុំអនុញ្ញាត។ លោក GROTIUS បានបន្ថែមទៀតថា៖

«... វត្ថុទាំងឡាយណាដែលពុំអាចកាន់កាប់បាន ឬពុំធ្លាប់មានគេកាន់កាប់ មិនអាចជារបស់ផ្ទាល់ខ្លួនរបស់នរណាម្នាក់ឡើយ ដោយហេតុថាកម្មសិទ្ធិណាក៏ដោយត្រូវចាប់ផ្ដើមចេញពីការកាន់កាប់។

ចំពោះហេតុផលដដែលនេះ សមុទ្រត្រូវតែជារបស់មនុស្សគ្រប់គ្នា ដោយសារវាធំទូលាយហួសពុំអាចនរណាកាន់កាប់បាន និងអាចប្រើប្រាស់បានគ្រប់គ្នាដោយអស្ចារ្យ ដែលគេយកចិត្តទុកដាក់ប្រើសម្រាប់នាវាចរណ៍ ឬនេសាទ»[3]។

[2] GROTIUS (H.), *Op. cit.*,p. 26.
[3] GROTIUS (H.), *Op. cit.*,p. 37-38.

លើសពីនេះទៅទៀត នៅសតវត្សរ៍ទី១៧ រដ្ឋប្រជាជាតិទាំងឡាយពុំខ្វល់ខ្វាយនឹងមធ្យោបាយដើម្បីដណ្តើមយកដែនដីឡើយ។ ឆន្ទៈរបស់ប្រជាជនពុំត្រូវបានគេយកមកពិចារណា ដើម្បីបញ្ជាក់ថាការផ្ទេរអធិបតេយ្យភាពត្រូវបានធ្វើឡើង ដោយស្របច្បាប់ ឬដោយមិនស្របច្បាប់ឡើយ។ ទំនាក់ទំនងរវាងរដ្ឋប្រជាជាតិទាំងនេះផ្អែកទៅលើទស្សនៈសមតាផ្អែកកម្លាំង។ សណ្តាប់ធ្នាប់ពិភពលោកនៅពុំទាន់មាននៅឡើយទេ។ **ហង់រី គីស៊ីងហ្គ័រ** (Henri KISSINGER) បានលើកឡើងថា៖

> «...រដ្ឋថ្មីៗនៅទ្វីបអឺរ៉ុបកំពុងស្វែងរកគោលការណ៍ណាមួយ ដើម្បីដោះសារអញ្ញមតិ និងដោះស្រាយទំនាក់ទំនងរបស់ខ្លួន។ រដ្ឋទាំងនោះបានរកឃើញគោលការណ៍នេះនៅក្នុងទស្សនៈ*បុព្វហេតុរដ្ឋ និងសមតាផ្អែកកម្លាំង*»[4]។

ដើម្បីដោះស្រាយវិវាទរវាងរដ្ឋ និងរដ្ឋ អង្គក្សត្រនានាបានសម្រេចចិត្តជាមួយគ្នាថា តើត្រូវបែងចែកទីក្រុង និងខេត្តដោយរបៀបណា។ នៅសម័យសក្តិភូមិ ស្តេចត្រាញ់នីមួយៗមានដែនដីគ្រប់គ្រងរបស់ខ្លួន។ ដែនដីស្ថិតក្នុងបេតិកភណ្ឌរបស់ស្តេចត្រាញ់[5]។ គេបានលើកបុព្វហេតុរដ្ឋមកសំអាងដើម្បីដោះសារនយោបាយវាតទីនិយម។ គឺជាសម័យមួយដែលគ្របដណ្តប់ដោយនីតិអន្តរជាតិបុរាណ ដែលមានគោលពីរ គឺសហអត្ថិភាព និងប្លន់ប្រហារ[6]។ ផែនដីមួយភាគធំត្រូវបានកំណត់សម្រាប់ការធ្វើទេសានុពន្ធន៍ (annexion) ដោយសេរី តាមរយៈអាណានិគមនិយម។ ទស្សនាទាននៃពិភពលោកបែបនេះ បានបង្កើតជាមនោគមវិជ្ជានៃលំហដើម្បីរស់នៅ និងព្រំដែនធម្មជាតិ ដែលប្រើដើម្បីបញ្ជាក់ព្រំដែនមួយ នៅពេលដែលគេពុំមានភ័ស្តុតាងបញ្ជាក់។ សាស្ត្រាចារ្យ **អារ៉ុន** (ARON) បានបញ្ជាក់ថា៖

> «ព្រំដែនធម្មជាតិ ក្នុងកម្រិតដែលពាក្យនេះមានន័យ គឺជាព្រំដែនដែលត្រូវបានគូសជាមុននៅលើផែនទីរូបវន្ត ដោយកំណត់យកទន្លេ ឬជួរភ្នំ ជាសំអាងដើម្បីស្រួលការពារ។ ព្រំដែនធម្មជាតិត្រូវបានគេហៅថាជាព្រំដែនយុទ្ធសាស្ត្រ ឬយោធា។ ទឡ្ហីករណ៍យោធាមានតម្លៃស្មើនឹងទឡ្ហីករណ៍ជីវសាស្ត្រ ឬសេដ្ឋកិច្ចនៃលំហដើម្បីរស់នៅ។ ទឡ្ហីករណ៍យោធាគឺជាទឡ្ហីករណ៍ជំនួសទឡ្ហីករណ៍សត្យានុម័ត ឬជំនួសទឡ្ហីករណ៍ផ្អែកសីលធម៌ ។ តម្រូវការផ្អែកសន្តិសុខអាចយកមកដោះសារថា ការកាត់ខេត្តមួយរបស់គេដើម្បីបញ្ចូលក្នុងទឹកដីរបស់ខ្លួន គឺជាភាពចាំបាច់សំខាន់ក្នុងការដណ្តើមយកទឹកដីដ៏ធំធេង»[7]។

---

[4] KISSINGER (H.), *Diplomatie,* Paris, Fayard, 1996, p. 48.

[5] **ដែនដី** ជាវត្ថុមួយដែលជារបស់ស្តេចត្រាញ់។ ក្នុងចំណោមវិធីផ្ទេរដែនដីទាំងអស់ យើងឃើញមានការស្នងបន្ត និងការចែករំលែកដែនដីរបស់មហាក្សត្រមួយអង្គរវាងរាជទាយាទ ការព្រមព្រៀងរៀបចំអាពាហ៍ពិពាហ៍ដើម្បីបម្រួបបម្រួមទឹកដី ការផ្ទេរដែនដីពីក្សត្រអង្គមួយទៅអង្គមួយទៀតក្នុងក្របខ័ណ្ឌស្នងរាជមរតក កតិការបស់រាជវង្ស ឬកតិកាសន្តិវង្ស ឬព្រះរាជវង្សានុវង្ស ខសន្យាផ្តល់ដែនដីត្រឡប់វិញ ឬ**អនុប្បទាន**ដែនដីជាថ្នូរនឹងការការពារ (BARBERIS (J.), « Les liens juridiques entre l'État et son territoire : Perspectives théoriques et évolution du droit international », *AFDI,* vol. 45, 1999, pp. 134-136) ។.

[6] KOLB (R.), *Introduction au droit des Nations Unies,* Bruxelles, Bruylant, 2008, p. 45.

[7] ARON (R.), *Paix et guerre entre les nations,* Paris, Calmann-Lévy, 2004, p. 207.

ការប្រើប្រាស់សមុទ្រត្រូវបានគ្រប់គ្រងដោយរបប *សេរីនិយម (laissez-faire)* ដែលឆ្លុះបញ្ចាំងឲ្យឃើញនូវផលប្រយោជន៍របស់មហាអំណាចអឺរ៉ុបដ៏ខ្លាំងក្លា [8] ដែលផ្តោតតែទៅលើនាវាចរ និងការនេសាទប៉ុណ្ណោះ។ ក្រៅពីតំបន់ឆ្នេរដែលមានទំហំតូច សមុទ្រអន្តរជាតិបានបើកចំហរឲ្យគ្រប់ប្រទេសទាំងអស់ប្រើប្រាស់ដោយសេរី ដោយគ្មានលក្ខខណ្ឌ។

នាដើមសតវត្សរ៍ទី១៩ ចក្រភពអង់គ្លេសបានក្លាយជាសមាសភាពនិយ័តករនៃសមតាផ្នែកកម្លាំង នៅកម្រិតអឺរ៉ុប និងពិភពលោក។ ប្រទេសបារាំង និងចក្រភពអង់គ្លេសបានប្រណាំងប្រជែងគ្នាយ៉ាងដាច់អហង្ការក្នុងការដឹកនាំនយោបាយអាណានិគមនៅអាស៊ីអាគ្នេយ៍។ ទោះជាយ៉ាងណាក្តី ប្រទេសទាំងពីរ ត្រូវប្រឈមមុខជាមួយនឹងមហាអំណាចអាណានិគមនៅនឹងកន្លែងស្រាប់ផ្សេងៗទៀត ដូចជា ប្រទេសហូឡង់នៅឥណ្ឌូនេស៊ី និងប្រទេសអេស្ប៉ាញនៅហ្វីលីពីន។ ដូច្នេះ ប្រទេសបារាំង និងចក្រភពអង់គ្លេសបានចូលរួមនៅក្នុងការបែងចែកអាស៊ីអាគ្នេយ៍ ដើម្បីបង្កើតតំបន់ស្ថិតក្រោមឥទ្ធិពលរបស់ខ្លួន។ ដូច្នេះ ព្រំដែនជាក់លាក់បានក្លាយជាមធ្យោបាយទប់ទល់នឹងការរុលទៅមុខរបស់គូបដិបក្សរបស់ខ្លួន [9] ។ នៅខណៈដែលប្រទេសម៉ាឡាយ៉ា [10] និងប្រ៊ុយណេ ស្ថិតក្រោមអាណាព្យាបាលរបស់ចក្រភពអង់គ្លេស ប្រទេសបារាំងបានប្រញាប់ប្រញាល់មកបោះទីតាំងនៅឥណ្ឌូចិន។ បារាំង និងសៀមបានប្រតិកម្មដាក់គ្នាយ៉ាងស្វិតស្វាញ ដោយបារាំងប្រើប្រាស់ការតស៊ូប្រមូលឥទ្ធិពលនៅចន្លោះអាណាម និងសៀម ទៅលើរដ្ឋឡាវ និងខ្មែរ ដើម្បីដាក់អាណាព្យាបាលរបស់ខ្លួន[11]។

មុនបារាំងមកដល់នៅសតវត្សរ៍ទី១៩ ពុំទាន់មានខ្សែបន្ទាត់ព្រំដែន តាមទស្សនៈរបស់ពួកបស្ចឹមប្រទេសនៅឡើយទេ ។ ព្រំដែនប្រទេសកម្ពុជាមានលក្ខណៈប្រពៃណី ពីព្រោះពុំមានអ្វីសម្គាល់ ហើយគ្រប់គ្រងដោយនីតិទំនៀមទម្លាប់។ **មីសែល ប្លង់សា** (Michel BLANCHARD) កត់សម្គាល់ថា ព្រំដែននេះមានលក្ខណៈមិនច្បាស់លាស់ ដោយសារព្រំដែនឈរលើទស្សនទានលំហ ជាជាងទស្សនទានខ្សែបន្ទាត់[12]។ ក្នុងការអនុវត្តជាក់ស្តែង អ្វីៗមានភាពសាំញ៉ាំជំពាក់ជំពិនគ្នា។ តំបន់ស្ថិតក្រោមការត្រួតត្រារបស់យោធាវៀតណាមច្រើនតែសម្បូរជនជាតិខ្មែររស់នៅ ដែលបន្តបង់ពន្ធទៅឲ្យរាជធានីឧត្តុង្គ ដែលជាសញ្ញានៃអធិបតេយ្យភាព។ នៅតាមមូលដ្ឋានខ្លះ មានជនជាតិទាំងពីរតាំងទីលំនៅ ដែលភាគច្រើនជាជនជាតិខ្មែរនោះ ត្រូវបង់សួយសារអាករអោយប្រទេសទាំងពីរ[13]។ ជាក់ស្តែង អាណាចក្រខ្មែរ ដែល

---

[8] CHURCHILL (R.) et LOWE (A.), *The Law of the Sea,* Juris Publishing, Manchester University Press, 1999, p. 2.
[9] DUTHEIL de la ROCHÈRE (J.), *Les procédures de règlement des différends frontaliers,* in SOCIÉTÉ FRANÇAISE POUR LE DROIT INTERNATIONAL, *La frontière,* Pedone, Paris, 1980, p. 135.
[10] នៅឆ្នាំ១៩៦៣ ការប្រមូលផ្តុំអាណានិគម សារ៉ាវ៉ាក់ (Sarawak) និងប៊័រនេអូ-ណ័រ-សាបា (Bornéo-Nord-Sabah) ជាមួយនឹងម៉ាឡាយ៉ា (Malaya) បង្កើតបានជាសហព័ន្ធម៉ាឡេស៊ី។
[11] FOUCHER (M.), *Fronts et frontières,* Fayard, Paris, 1991, p. 317.
[12] BLANCHARD (M.), *Vietnam – Cambodge : Une frontière contestée.* Paris, L'Harmattan. 1999. p. 41.
[13] *Ibid.* p. 45.

បានរុងរឿងដល់កម្រិតកំពូលក្នុងសម័យអង្គរ (សតវត្សរ៍ទី៩ ដល់ទី១៤)[14]ត្រូវបានប្រទេសសៀម និងវៀតណាមអង្កៀមលេបយក ក្នុងអំឡុងពេលជាង ៤ សតវត្សរ៍។ រដ្ឋកម្ពុជាបានចុះខ្សោយដោយសារការបែកបាក់ផ្ទៃក្នុង ការប្រណាំងប្រជែងរវាងអាណាម និងសៀម និងជួនកាល ត្រូវស្ថិតក្រោមឥទ្ធិពលរបស់ប្រទេសជិតខាងទាំងពីរ។ ប៉ុន្តែកម្ពុជានៅតែជារដ្ឋឯករាជ្យដែលក្នុងន័យនីតិអន្តរជាតិបុរាណ[15]។ ប្រទេសកម្ពុជាមានក្បាលម៉ាសីនរដ្ឋបុរាណ ដែលពឹងផ្អែកទៅលើប្រជាជនដែលរស់នៅតាមវាលទំនាបតំបន់ភ្នំ និងជ្រលងភ្នំរាប់សតវត្សរ៍មកហើយ។ ដែនដីត្រូវបានកំណត់ដោយព្រំដែនតំបន់ប្រពៃណី[16]។ លោកសាស្ត្រាចារ្យ **ម៉ាក់ ភឿន** (MAK PHOEUN) បានពន្យល់អំពីទស្សនាទានព្រំដែនតាមនីតិទំនៀមទម្លាប់នេះ ដូចខាងក្រោម៖

> «សញ្ញាណនៃពាក្យ "មន្ត្រីជាន់ខ្ពស់" និង "ដែនដី" ទំនងជាយកមកអនុវត្តក្នុងទស្សនាទានលំហាដែនដី និងព្រំដែនរបស់ប្រទេសកម្ពុជា។ ដោយសារប្រព័ន្ធរដ្ឋបាលក៏ផ្អែកផងដែរទៅលើចំណងបុគ្គលមានស្រាប់រវាងនាហ្មឺនតាមខេត្ត និងមន្ត្រីជាន់ខ្ពស់នៃរាជវាំង ប្រទេសកម្ពុជាប្រៀបបីដូចជា "លំហាមួយពោរពេញដោយជាតិពន្ធុ និងវប្បធម៌រួមគ្នា សម្រាប់ការពង្រីករាជអំណាចរបស់ព្រះរាជា"។ ក្នុងន័យនេះ អំណាចនៅមជ្ឈិមមិន សូវផ្តោតការយកចិត្តទុកដាក់ទៅលើព្រំប្រទល់ដែនដីកម្ពុជាឡើយ ផ្ទុយទៅវិញច្រើនផ្តោតការយកចិត្តទុក ដាក់ទៅលើមនុស្សដែលរស់នៅក្នុងព្រំប្រទល់ដែនដីនេះជាង...។ ការមិនយកចិត្តទុកដាក់ចំពោះព្រំដែនពីសំណាក់អំណាចនៅមជ្ឈឹមនេះ បង្ហាញឲ្យឃើញពីការខ្វះការប្រុងប្រយ័ត្នរបស់អង្គក្សត្រកម្ពុជាខ្លះកាលពីសតវត្សរ៍ទី១៧ នៅចំពោះមុខការចូលមកកាន់កាប់ទឹកដីកម្ពុជាដោយជនបរទេស។ ការខ្វះការប្រុង

[14] នៅដើមសតវត្សទី៩ ព្រះមហារក្សត្រខ្មែរ ព្រះបាទជ័យវរ្ម័នទី២ បានរំដោះចេនឡា និងបង្រួបបង្រួមប្រទេស ដែលត្រូវបានយាយីពីសត្រូវ និងសង្គ្រាមផ្ទៃក្នុង។ ព្រះអង្គជាក្សត្របង្រួបបង្រួម និងជាស្ថាបនិករាជវង្សក្សត្រខ្មែរ។ ទ្រង់បានបង្កើតរាជធានីក្នុងតំបន់អង្គរ។ ទ្រង់បានអនុវត្តពិធីសាសនាផ្លូវការ«*លទ្ធិទេវរាជ្យ*» និងបានប្រកាសជាឱឡារិកនូវឯករាជ្យនៃអាណាចក្រខ្មែរឲ្យរួចផុតពីអតីតស្តេចជ្វា។ ទ្រង់ត្រូវបានគេប្រកាសជា«*ស្តេចចក្រវាឡ*»។ លទ្ធិសិវៈត្រូវបានអនុម័តជាសាសនាផ្លូវការ។ ពិធីទេវរាជ្យបានបង្កើតអំណាចនៃអាណាចក្រខ្មែរ និងជួយពង្រីកវប្បធម៌ និងសិល្បៈរបស់ខ្លួន និងសាងសង់បូជនីយដ្ឋានសាសនា។ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ (១១៨១-១២១៨?) អាណាចក្រខ្មែរបានរីកចម្រើនដល់កម្រិតកំពូល។ អាណាចក្រខ្មែរបានធ្លាក់ចុះដុនដាបក្នុងខ្វង់ឆ្នាំ១៤៣១ នៅពេលដែលរាជធានីអង្គរធំធ្លាក់ចូលក្នុងកណ្តាប់ដៃសៀម។ នោះគឺជាទីបញ្ចប់របស់អាណាចក្រខ្មែរ ដែលចុះខ្សោយដោយសារការវាយប្រហារឥតឈប់ឈរពីសំណាក់ចម្ប៉ា និងសៀម ហើយពុំអាចជួសជុលប្រឡាយទឹកដ៏ធំដែលជាអាយុជីវិតរបស់ប្រទេសបាន។ រាជធានីនៃអាណាចក្រខ្មែរបានទទួលរងការឆក់ប្លន់ និងត្រូវបានបោះបង់ចោល។ ព្រះចៅពញ៉ាយ៉ាតបានសម្រេចប្តូររាជធានី មកគង់នៅភ្នំពេញត្រង់ចំណុចប្រសព្វនៃទន្លេមេគង្គ និងទន្លេសាប ក្រោយមកនៅលង្វែក (LECLERE (A.), *Histoire du Cambodge,* Paris, Librairie Paul Geuthner, 1914, pp. 40-134 ; MIGOT (A.), *Les Khmers,* Paris, Le livre contemporain, 1960, pp. 70-206 ; GITEAU (M.), *Histoire du Cambodge,* Didier, Paris, 1957, pp. 41-133 ; KHIN SOK, *Le Cambodge entre le Siam et le Vietnam (de 1775 à 1860)*, EFEO, Paris, 1991 ; MAK PHOEUN, *Histoire du Cambodge de la fin du XVIe siècle au début du XVIIIe*, EFEO, Paris, 1995)។

[15]**រដ្ឋឯករាជ្យ** មានសមាសធាតុដូចតទៅ៖ រដ្ឋាភិបាល ទឹកដី ប្រជាជន និងសមត្ថភាពក្នុងការចរចាដោយផ្ទាល់ ជាមួយបរទេស ។ កម្ពុជានៅពេលនោះអាចចរចាដោយផ្ទាល់ជាមួយបេសកជនបរទេស។

[16] រចនាសម្ព័ន្ធភូមិសាស្ត្រនយោបាយផ្ទៃក្នុងដែលមាន«សណ្ឋាន»ជារង្វង់ដែលគ្រប់គ្រងជាបន្តបន្ទាប់គ្នា ហើយដែលមានអំណាចចុះខ្សោយបន្តិចម្តងៗ ចាប់ពីស្នូលកណ្តាលទៅដែលមានសមាសធាតុដូចគ្នា និងគ្របដណ្តប់លើគេ ហើយនេះគឺជារចនាសម្ព័ន្ធភូមិសាស្ត្រនយោបាយតាំងពីបរមបូរាណមកម្ល៉េះ (FOUCHER (M.), *Op. cit.,* p. 318)។

ប្រយ័ត្ននេះធ្វើឲ្យប្រជាជនកម្ពុជាចុះខ្សោយពេលប្រឈមមុខនឹងប្រជាជនវៀតណាម ដែលយកចិត្តទុកដាក់ជាប់ជានិច្ចទៅលើលំហ តាមរយៈការបញ្ជាក់ច្បាស់ពីព្រំប្រទល់ដែនដី និងតាមរយៈការស្រង់ស្ថិតិចម្ងាយក្នុងភូមិសាស្ត្រប្រពៃណី។ សម្រាប់ប្រជាជនវៀតណាម ព្រំដែនពុំមានភាពស្ថិតស្ថេរទេ ប៉ុន្តែគឺជាព្រំប្រទល់មួយដែលត្រូវបានកំណត់ អាស្រ័យតាមការប្រៀបធៀបកម្លាំងក្នុងខណៈណាមួយ ដែលពួកគេតែងតែព្យាយាមរុលទៅមុខឲ្យឆ្ងាយឥតឈប់ឈរ»[17]។

នាពាក់កណ្ដាលទីពីរនៃសតវត្សរ៍ទី១៩ ប្រទេសអង់គ្លេស និងបារាំងបានប្រជែងដណ្ដើមដាក់អាណានិគមនៅប្រទេសសៀម ដែលសឹងតែបាត់បង់ឯករាជ្យទៅហើយ។ ក្នុងទស្សនៈរបស់ប្រទេសអង់គ្លេស ដរាបណាប្រទេសសៀមនៅមានឯករាជ្យ និងស្ថិតក្នុងរង្វង់ឥទ្ធិពលអង់គ្លេស បារាំងអាចដណ្ដើមយកឥណ្ឌូចិនបានមួយភាគ។ ផ្ទុយមកវិញ បារាំងអាចទទួលបានជោគជ័យទាំងស្រុងពីការបញ្ចូលប្រទេសសៀមក្នុងអាណានិគមរបស់ខ្លួន។

លោកសាស្ត្រាចារ្យ ARON បានលើកឡើងថា នៅមុនឆ្នាំ ១៩១៤ នីតិសាធារណៈអន្តរជាតិអឺរ៉ុបពុំដែលមានបំណង ឬមានគោលការណ៍ដាក់សង្គ្រាមឲ្យស្ថិតនៅក្រៅច្បាប់ទាល់តែសោះ[18]។ ជាការពិតណាស់ សហរដ្ឋអាមេរិក ដែលជាមហាអំណាចថ្មីទើបលេចមុខឡើងនោះ ចង់ផ្លាស់ប្ដូរសណ្ដាប់ធ្នាប់ពិភពលោក។ ក៏ប៉ុន្តែ ទើបតែក្រោយសង្គ្រាមលោកទី១ទេ ដែលលោកប្រធានាធិបតីអាមេរិក **វីលសុន** (WILSON) បានថ្លែងសុន្ទរកថា ១៤ ចំណុច (Quatorze Points) នាថ្ងៃទី០៨ ខែមករា ឆ្នាំ១៩១៨ ដើម្បីសដាក់ចេញនូវទស្សនៈសង្គមប្រជាជាតិ ដែលជាអង្គការមួយបង្កើតឡើងក្នុងគោលដៅរក្សាសន្តិភាពតាមរយៈសន្តិសុខរួម និងមិនមែនតាមរយៈបណ្ដាញសម្ព័ន្ធភាពទេ[19]។ ពាក់ព័ន្ធនឹងលទ្ធិរបស់លោក WILSON លោក **គីស្ស៊ីងហ្គ័រ** (KISSINGER) បានសរសេរថា៖

«លោក WILSON បានផ្ដល់តួនាទីដល់អាមេរិកជាអ្នកជួយសង្គ្រោះគេ ៖ អាមេរិកមិនមែនមានភារកិច្ចបំពេញការងារ ដើម្បីរក្សាឲ្យមានសមតាកម្លាំងនោះទេ ក៏ប៉ុន្តែ មានភារៈកិច្ចពង្រីកគោលការណ៍ទាំងឡាយដែលគ្រប់គ្រងសមតានេះនៅក្នុងពិភពលោកទាំងមូល...។ គោលការណ៍ទាំងនេះសន្មតថា សន្តិភាពត្រូវមានមូលដ្ឋានលើការពង្រីក និងពង្រឹងលទ្ធិប្រជាធិបតេយ្យ ដែលរដ្ឋទាំងនោះត្រូវតែទទួលការវិនិច្ឆ័យទៅតាមលក្ខណៈវិនិច្ឆ័យដូចគ្នានឹងបុគ្គលម្នាក់ៗដែរ និងថា ផលប្រយោជន៍ជាតិគឺត្រូវផ្សារភ្ជាប់ទៅនឹងប្រព័ន្ធគតិយុត្តិសកល»[20]។

ទោះជាយ៉ាងណាក្ដី ប្រព័ន្ធគតិយុត្តិរបស់សង្គមប្រជាជាតិ ដែលមានគោលដៅបដិសេធសង្គ្រាមថាជាមធ្យោបាយកែប្រែលក្ខន្តិកៈដែនដី ត្រូវបានទទួលបរាជ័យ ព្រោះថារដ្ឋទាំងឡាយណាដែលមិនពេញចិត្ត ចង់ប្ដូរប្រព័ន្ធដែលមានស្រាប់រួចមកហើយ។ ទាល់តែចាប់ពីឆ្នាំ១៩៤៥ មកទេ ដែលនីតិ

---

[17] MAK PHOEUN, *Histoire du Cambodge de la fin du XVIe siècle au début du XVIIe*. Paris, EFEO. 1995. p. 420.
[18] ARON (R.), *op. cit.*, p. 119.
[19] KISSINGER (H.), *op. cit.*, p. 22.
[20] *Ibid.*,pp. 21-22.

អន្តរជាតិទំនើបត្រូវបានចាប់ផ្តើមដាក់ឲ្យអនុវត្ត[21] ដើម្បីដាក់សង្គ្រាមឲ្យនៅក្រៅច្បាប់[22]។ សណ្តាប់ធ្នាប់គតិយុត្តិដែលបង្កើតអង្គការសហប្រជាជាតិ គឺផ្អែកទៅលើគោលការណ៍ដូចគ្នានឹងសណ្តាប់ធ្នាប់ **វែរសៃ** (Versailles) និងសណ្តាប់ធ្នាប់សង្គមប្រជាជាតិដែរ ប៉ុន្តែសណ្តាប់ធ្នាប់នេះអនុវត្តចំពោះប្រជាជាតិនៃទ្វីបទាំងអស់ចាប់ពីពេលនោះមក[23]។

ផ្ទុយទៅវិញ ក្រោយសង្គ្រាមលោកលើកទី២ ដូចដែលលោក **កែលស៊ិន** (KELSEN)[24] បានគូសបញ្ជាក់ស្រាប់ ចាប់ពីពេលនោះមក ការប្រើកម្លាំងដើម្បីកែប្រែព្រំដែនមិនត្រឹមតែផ្ទុយនឹងខ្លឹមសារនៃធម្មនុញ្ញរបស់អង្គការសហប្រជាតិប៉ុណ្ណោះទេ ថែមទាំងផ្ទុយនឹងស្មារតីដែលកំពុងតែជំរុញការវិវត្តបច្ចុប្បន្ននៃនីតិអន្តរជាតិទូទៅទៀតផង។ មាត្រា ២ នៃធម្មនុញ្ញប្រគល់សិទ្ធិ និងករណីយកិច្ចដល់បណ្តារដ្ឋជាសមាជិក ក្នុងការបដិសេធមិនទទួលស្គាល់នូវស្ថានភាពទាំងឡាយណា ដែលកើតចេញពីការគំរាមកំហែង ឬការប្រើហិង្សា។ លោកសាស្ត្រាចារ្យ **ឌើ វីឈើរ** (De VISSCHER) បានកត់សម្គាល់ពីការវិវត្តរបស់នីតិអន្តរជាតិដោយគូសបញ្ជាក់ថា *«អំពើខុសច្បាប់ជាអន្តរជាតិមិនបង្កើតនូវប័ណ្ណកម្មសិទ្ធិមានសុពលភាពសម្រាប់នីតិអន្តរជាតិឡើយ»*[25]។ ក្នុងបរិបទហាមប្រាមការប្រើកម្លាំងនេះ បណ្តារដ្ឋទាំងអស់ត្រូវប្រកាន់យកនូវកាតព្វកិច្ចទូទៅមួយ គឺ ត្រូវមានសកម្មភាពសន្តិភាពលើលំហសមុទ្រ ដែលកើតចេញពីគោលការណ៍នីតិអន្តរជាតិទូទៅ[26]។ ដូច្នេះ ការបែងចែកដែនសមុទ្រត្រូវស្ថិតក្រោមបញ្ញត្តិច្បាប់។ នេះ

---

[21] **នីតិអន្តរជាតិទំនើប** ច្រានចោលវិសមភាព ការលូកដៃចូលកិច្ចការផ្ទៃក្នុង ការប្រើកម្លាំង។ គឺជានីតិដែលជំរុញការដោះស្រាយវិវាទដោយសន្តិវិធី សហប្រតិបត្តិការអន្តរជាតិ សិទ្ធិមនុស្ស ការលប់បំបាត់នូវរបបអាណានិគមនិយម។ គឺជានីតិដែលផ្តោតទៅលើការដោះស្រាយការគំរាមកំហែងរួមចំពោះមនុស្សជាតិដូចជា៖ អាវុធបរមាណូ ការបំផ្លាញបរិស្ថាន បុព្វហេតុមនុស្សធម៌ វិសមភាពភោគទ្រព្យ ជីវិតនយោបាយរបស់ប្រជាជន។ នីតិទំនើបនេះមានចែងក្នុងមាត្រា២ នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ។ ធម្មនុញ្ញនេះមានឥទ្ធិពលទៅលើនីតិទំនៀមទម្លាប់អន្តរជាតិ។ ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិមានលក្ខណៈធំជាងសន្ធិសញ្ញា ដែលហៅថា«រដ្ឋធម្មនុញ្ញអន្តរជាតិ»។ ធម្មនុញ្ញនេះកែប្រែនីតិទូទៅដែលមានពីមុនមក (KOLB (R.), *Introduction au droit des Nations Unies,* Bruxelles, Bruylant, 2008, pp. 46-47)។

[22] **កតិកាសញ្ញា BRIAND-KELLOGG** ៖រដ្ឋមន្ត្រីការបរទេសបារាំង Aristide BRIAND នៅក្នុងលិខិតចុះថ្ងៃទី ៦ ខែ មេសា ឆ្នាំ ១៩២៧ ថ្លែងចំពោះប្រជាជនអាមេរិក ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី១០នៃការចូលរួមរបស់សហរដ្ឋអាមេរិកក្នុងសង្គ្រាមលោកលើកទី១ បានស្នើឲ្យ រដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិក **Frank Billings KELLOGG** នូវកតិកាសញ្ញាស្តីពីការដាក់សង្គ្រាមឲ្យ«*នៅក្រៅច្បាប់*»។ **កតិកាសញ្ញា BRIAND-KELLOGG** ឬ កតិកាសញ្ញាទីក្រុងបារីស គឺជាអនុសញ្ញា ដែលត្រូវបានចុះហត្ថលេខានៅថ្ងៃទី ២៧ សីហា ឆ្នាំ ១៩២៨ នៅទីក្រុងបារីស និង ចូលជាធរមាននៅថ្ងៃទី ២៤ កក្កដា ឆ្នាំ ១៩២៩។ ដោយអនុលោមតាមកតិកាសញ្ញានេះ រដ្ឋហត្ថលេខីទាំង ៦៣ «*បានថ្កោលទោសការប្រើប្រាស់សង្គ្រាម ជាមធ្យោបាយសម្រាប់ដោះស្រាយវិវាទអន្តរជាតិ និងបដិសេធសង្គ្រាម ជាឧបករណ៍គោលនយោបាយ ក្នុងទំនាក់ទំនងរវាងរដ្ឋ និង រដ្ឋ*»។ រដ្ឋាភិបាលនៃប្រទេសទាំងពីរបានដាក់កតិកាសញ្ញានេះ ឲ្យប្រទេសឯទៀតចុះហត្ថលេខា ។ ជាការពិតណាស់ កតិកាសញ្ញានេះមិនបានបញ្ឈប់សង្គ្រាមទេ។ ក៏ប៉ុន្តែ វាបានក្លាយទៅជាមូលដ្ឋានសម្រាប់តុលាការ **Nuremberg** ដើម្បីចោទប្រកាន់បទឧក្រិដ្ឋប្រឆាំងសន្តិភាព។ ក៏ប៉ុន្តែ គោលការណ៍ហាមឃាត់ការប្រើប្រាស់សង្គ្រាម ជាមធ្យោបាយកែប្រែដែនដី ទើបតែត្រូវបានដាក់ចេញជាលើកដំបូង នៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ ជាគោលការណ៍ច្បាប់អន្តរជាតិ។

[23] ARON (R.), *op. cit.,* p. 125.

[24] KELSEN, *Principles of International Law,* 2e edit., pp. 41-432.

[25] DE VISSCHER (C.). *Les effectivités du droit international public,* Paris, Éditions A. Pédone. 1967, p. 24.

[26] PANCRACIO (J-P.), *Droit de la mer*, Paris, Dalloz, 2010, 1er édition, p. 94.

គឺជា «*ឧត្តមភាពនៃច្បាប់លើការប្រើកម្លាំង*» (le primat du droit sur la force)[27]។ ដើម្បីគោលដៅនេះ ធម្មនុញ្ញអង្គការសហប្រជាជាតិ ក៏បានបង្កើតសម្រាប់បណ្តារដ្ឋជាសមាជិកនូវក្របខ័ណ្ឌមួយ ដែលអាចធ្វើឲ្យបញ្ហាត្រួតពិនិត្យសមុទ្រជាលក្ខណៈអន្តរជាតិវិវត្តទៅមុខ។ ក្រោយសង្គ្រាមលោកលើកទី២ របបសេរីនិយម (laissez-faire) បានផ្លាស់ប្តូរទាំងស្រុង ដោយសារមហាអំណាចថ្មីៗលេចមុខឡើង (សហរដ្ឋអាមេរិក និងសហភាពសូវៀត) នៅលើឆាកអន្តរជាតិ និងដោយសារការវិវត្តន៍នៃរបបជាតិនិយម ព្រមទាំងស្វយ័តភាពសេដ្ឋកិច្ចរបស់ប្រទេសកំពុងអភិវឌ្ឍ ដែលទើបនឹងទទួលបានឯករាជ្យ[28]។

ការកកើត ឬការសាបសូន្យនៃរដ្ឋ គឺគ្រាន់តែជាបញ្ហានៃអង្គហេតុប៉ុណ្ណោះ[29]។ ដោយឈរលើនីតិអន្តរជាតិ ការបង្កើតរដ្ឋ គឺជាអង្គហេតុ ហើយមិនមែនជាកិច្ចគតិយុត្តិនោះទេ[30]។ វាគឺជា «*អង្គហេតុសំខាន់ជាងគេដែលច្បាប់កត់សម្គាល់ឃើញ។ អង្គហេតុសំខាន់ជាងគេមានន័យថា ជាអង្គហេតុដែលកើតមុនច្បាប់...*»[31]។ ដូចលោកសាស្ត្រាចារ្យ **រូស្សូ** (ROUSSEAU) សង្កេតឃើញស្រាប់៖ «*កំណើតរបស់រដ្ឋគឺជាអង្គហេតុសុទ្ធសាធ ដែលមិនចំណុះឲ្យវិធានសាមញ្ញនៃច្បាប់ឡើយ*»[32]។ រដ្ឋឯករាជ្យត្រូវធ្វើជាម្ចាស់ក្តោបក្តាប់លំហឲ្យបាន ព្រោះថាអំណាចរដ្ឋពឹងផ្អែកលើស្ថានភាពដែនដី និងធ្វើប្រតិបត្តិការដោយត្រួតត្រាលើដី និងប្រជាជនដែលរស់នៅទីនោះ តាមតក្កវិជ្ជាត្រៃដ្ឋាននៃធាតុផ្សំនៃរដ្ឋ គឺ រដ្ឋាភិបាល ដែនដី ប្រជាជន[33]។ រដ្ឋពុំអាចខ្វះដែនដីបានឡើយ។ ក្នុងអត្ថន័យនៃនីតិអន្តរជាតិបុរាណ ដែនដីត្រូវ

---

[27] LUCCHINI (L.) et VOELCKEL (M.), *Droit de la mer*, tome. I, la mer et son droit, les espaces maritimes, Paris, Pedone, 1990, p. V.

[28] **ការទទួលបានឯករាជ្យ** គឺជាអង្គហេតុគតិយុត្តិអន្តរជាតិ ដែលត្រូវបានផ្តល់ឥទ្ធិពលគតិយុត្តិដោយនីតិអន្តរជាតិ ពោលគឺការទទួលបាននូវលក្ខន្តិកៈគតិយុត្តិអន្តរជាតិរបស់រដ្ឋ រួមទាំងសិទ្ធិ និងកាតព្វកិច្ចទាំងអស់ (ដំបូងបង្អស់គឺអធិបតេយ្យភាព) ដែលរដ្ឋផ្សេងៗទៀតត្រូវគោរព។ ដូច្នេះ គុណសម្បត្តិជារដ្ឋក្នុងន័យនៃនីតិអន្តរជាតិគឺទទួលបានតែនៅពេលរដ្ឋនោះទទួលបានឯករាជ្យ និងទទួលបាននូវនីតិបុគ្គលអន្តរជាតិប៉ុណ្ណោះ។ រដ្ឋមានសមត្ថភាពគតិយុត្តិអន្តរជាតិពេញលេញបរិបូណ៌ ព្រោះថារដ្ឋអាចបំពេញកិច្ចគតិយុត្តិ និងជាអ្នកទទួលវិធានទាំងឡាយនៃនីតិអន្តរជាតិ (VIRALLY (M.), « Panorama du droit internationalcontemporain », *RCADI*, 1983-V, t. 183, pp. 52-72)។

[29] គណៈកម្មការមជ្ឈត្តការនៃសន្និសីទដើម្បីសន្តិភាពនៅយូហ្គោស្លាវីបានឲ្យនិយមន័យនៃលក្ខណៈវិនិច្ឆ័យនៃ **រដ្ឋ** ដូចតទៅ៖ ១. រដ្ឋត្រូវបានឲ្យនិយមន័យជារួមថាជាសមូហភាព ដែលផ្សំឡើងពីដែនដី និងប្រជាជន ស្ថិតនៅក្រោមអំណាចនយោបាយដែលមានរចនាសម្ព័ន្ធចាត់តាំងត្រឹមត្រូវ ២. រដ្ឋត្រូវបានសម្គាល់ដោយអធិបតេយ្យភាព ៣. ការទទួលស្គាល់ពីរដ្ឋផ្សេងៗមានឥទ្ធិពលជាសេចក្តីប្រកាសសុទ្ធសាធ ៤. អត្ថិភាព ឬការរលាយបាត់នៃរដ្ឋគឺជាបញ្ហាអង្គហេតុ (PELLET (A.), « Notes sur la Commission d'arbitrage de la Conférence européenne pour la paix en Yougoslavie », *AFDI.*, 1991, p. 337)។

[30] CRAWFORD (J.), *The Creation of States in International Law,* Oxford, Clarendon Press, 2nd ed, 2006, p. 14.

[31] ABI-SAAB (G.), « Cours général de droit internationalpublic », *RCADI*, 1987/-V, p. 68.

[32] ROUSSEAU (C.), *Droit international public.* Tome III, *« Les compétences »*, Paris, Sirey, 1977, p. 514.

[33] សូមមើល VIRALLY (M.), « Panorama du droit internationalcontemporain », *RCADI*, 1983-V, t. 183, pp. 47-93 ; ABI-SAAB (G.), « Cours général de droit internationalpublic », *RCADI*, 1987/-V, pp. 67-83 ; COMBACAU (J.) et SUR (S.), *Droit international public*, Paris, Montchrestien, 2008, 8e édition, pp. 277-278 ; DAILLIER (P.), FORTEAU (M.) et PELLET (A.), *Droit international public* (Nguyen Quoc Dinh), Paris, L.G.D.J., 8e édition, 2009, pp. 454-457; DECAUX (E.), *Droit international public*, Paris, Dalloz, 2010, 7e édition, pp. 151-153 ; DUPUY (P-M.) et KERBRAT (Y.), *Droit international public*, Paris, Dalloz, 2010, 10e édition, pp. 89-97 ; BROWNLIE (I.), *Principles of Public International Law*, Oxford, Oxford University Press, 2008, 7e edition, pp. 105-167 ; SHAW (M.), *International Law*, Cambridge, Cambridge University Press, 2008, 6e edition, pp. 487-552.

បានគេចាត់ទុកថា ជារាងកាយ ឬខ្លឹមរបស់រដ្ឋ ឬជាកម្មសិទ្ធិ ឬធនធានរបស់រដ្ឋ។ ដែនដីមានតម្លៃនិមិត្តរូប ឬស្ទើរតែអាថ៌កំបាំង[34]។

អធិបតេយ្យភាពដែនដី បង្កើតបានជាធាតុផ្សំសំខាន់មួយសម្រាប់អធិតេយ្យភាពជាតិ និងសម្រាប់សណ្តាប់ធ្នាប់អន្តរជាតិ ។ លោកសាស្ត្រាចារ្យ ARON មានប្រសាសន៍ថា ៖

> «មកដល់ពេលបច្ចុប្បន្ននេះ សណ្តាប់ធ្នាប់អន្តរជាតិទាំងអស់ សុទ្ធសឹងតែផ្អែកលើដែនដីជាសំខាន់។ សណ្តាប់ធ្នាប់អន្តរជាតិនេះឈរលើមូលដ្ឋាននៃការព្រមព្រៀងរវាងរដ្ឋអធិបតេយ្យនានា ស្តីពីការបែងចែកលំហដែនដី...។ ប្រសិនបើរដ្ឋណាមួយហានរំលោភកាត់ខ្សែបន្ទាត់ខណ្ឌចែកដែនដីជារដ្ឋបាលនយោបាយនេះ របស់រដ្ឋមួយទៀត វាជាសញ្ញាបង្ហាញពីការរំលោភបំពានជាក់ជាមិនខាន ដែលជា *ដើមចមនៃការប្រកាសសង្គ្រាម (casus belli)* » [35]។

សរុបមក ដែនដី និងព្រំដែនគឺជាសមាសធាតុដ៏សំខាន់បំផុតរបស់រដ្ឋ ហើយការស្វែងរកព្រំដែនច្បាស់លាស់ និងមានការទទួលស្គាល់ជាក់លាក់ គឺជាលក្ខខណ្ឌនៃការពង្រឹងរដ្ឋថ្មី (§១)។ ក្នុងន័យនេះ ការកំណត់ព្រំដែនសមុទ្រចៀសពុំរួចពីការប៉ះទង្គិចនឹងការទាមទារពីសំណាក់ប្រទេសជិតខាងឡើយ។ ប្រការនេះគឺជាតថភាពជាក់ស្តែងនៃវិវាទព្រំដែនសមុទកម្ពុជា-ថៃ (§២)។

## §១. ព្រំដែនច្បាស់លាស់ និងមានការទទួលស្គាល់ ៖ជាការពង្រឹងរដ្ឋថ្មីមួយ

ក្នុងន័យច្បាប់ រដ្ឋផ្សាភ្ជាប់ទៅនឹងដែនដី[36]។ រដ្ឋមានសមត្ថកិច្ចផ្ទាល់ខ្លួន ដែលអាចចែកជាសមត្ថកិច្ចសំភារៈ (កិច្ចទាំងឡាយ ដែលរដ្ឋអាចសម្រេចបានអនុលោមតាមសិទ្ធិរបស់ខ្លួន) សមត្ថកិច្ចបុគ្គល (អំណាចរដ្ឋចំពោះពលរដ្ឋ) និងសមត្ថកិច្ចដែនលំហ (អធិបតេយ្យភាពដែនដី)។ គេបានឲ្យនិយមន័យ

---

[34] ABI-SAAB (G.), « Cours général de droit internationalpublic », *RCADI*, 1987/-V, p. 69.

[35] ARON (R.), *Ibid.,* p. 187.

[36] នៅក្នុងនីតិអន្តរជាតិ មានទ្រឹស្តីចំនួន៤ ដែលបង្ហាញពី **ទំនាក់ទំនងគតយុត្តរវាងរដ្ឋ និងដែនដី** គឺ៖ (១) ដែនដីត្រូវបានចាត់ទុកជាសម្បត្តិរបស់ស្តេចត្រាញ់នៅសម័យយុគកណ្តាល (Moyen Age)។ (២) ទ្រឹស្តីដែនដី-សម្បត្តិផ្តាច់រដ្ឋចេញពីដែនដីរបស់ខ្លួនដើម្បីបង្កើតទំនាក់ទំនងកម្មសិទ្ធិ។ អ្នកនិពន្ធរូបនេះប្រកែកថាដែនដីជាធាតុផ្សំនៃរដ្ឋ។ យើងនិយាយអំពី អនុប្បទាន ការបោះបង់ ឬការទិញដែនដី។ មធ្យោបាយទិញអធិបតេយ្យភាពដែនដី រួមបញ្ចូលទាំងអាជ្ញាយុកាលលទ្ធកម្ម កំណើនដែនដីដោយសារល្បាប់ដុះ និងការកាន់កាប់ដីគ្មានម្ចាស់ (*Terra nullius*)។ រដ្ឋអនុវត្តសិទ្ធិភណ្ឌិកលើដែនដីរបស់ខ្លួន។ (៣) ទ្រឹស្តីដែនដី-ប្រធាន បកស្រាយថាដីត្រូវបានគេកំណត់ថាជា «ភាពជារដ្ឋ» ជា «អង្គរដ្ឋ» ជា «ធាតុនៃធម្មជាតិរដ្ឋ» ឬជា «សារជាតិនៃរដ្ឋ»។ ទ្រឹស្តីនេះពិពណ៌នារដ្ឋថាជាបាតុភូតមួយដែលបង្កើតឡើងដោយធាតុមូលដ្ឋានចំនួនបី គឺប្រជាជន ដែនដី និងរដ្ឋាភិបាល។ FRICKER បញ្ជាក់ថា ដែនដីគឺជាលំហដែលនៅក្នុងនោះ រដ្ឋអនុវត្តកិត្យានុភាព ឬអំណាចរបស់ខ្លួន។ ទ្រឹស្តីនេះពិពណ៌នារដ្ឋថាជាតថភាពសង្គមវិទ្យា។ (៤) ដែនដីគឺជាវិស័យសុពលភាពលំហរបស់រដ្ឋលើផ្អែកគតិយុត្តិ។ ទស្សនាទានរបស់ **រ៉ាដនីស្គី** (RADNITZKY) បានបង្កើតឡើងដោយឈរលើផ្អែកបទដ្ឋាន ដោយចាប់ពីសមត្ថកិច្ចរដ្ឋឡើងទៅ (BARBERIS (J.), « Les liens juridiques entre l'État et son territoire : Perspectives théoriques et évolution du droit international », *AFDI,* vol. 45, 1999, pp. 134-136 ; DAILLIER (P.), FORTEAU (M.) et PELLET (A.), *Droit international public*, *Op. cit.*,p. 456)។

ដែនដីរដ្ឋថាជា «*ដែនសមត្ថកិច្ចលំហនៃអំណាចរដ្ឋ*»[37]។ លោក KELSEN បានឲ្យនិយមន័យដែនដីរដ្ឋថាជា «*លំហដែលនៅខាងក្នុងនោះ រដ្ឋមួយត្រូវបានច្បាប់អន្តរជាតិទូទៅអនុញ្ញាតឲ្យសម្រេចកិច្ចទាំងឡាយ ដែលត្រូវបានចែងដោយច្បាប់ជាតិរបស់រដ្ឋនោះ ឬដូចគ្នាដែរ ជាលំហដែលនៅខាងក្នុងនោះ ស្ថាប័នដែលត្រូវបានកំណត់ដោយសណ្ដាប់ធ្នាប់គតិយុត្តិជាតិ ត្រូវបានអនុញ្ញាតឲ្យអនុវត្តសណ្ដាប់ធ្នាប់នេះ ដោយអនុលោមតាមនីតិអន្តរជាតិ*»[38]។

ដែនដីគឺជាសមាសធាតុ ដែលធ្វើឲ្យរដ្ឋខុសពីប្រធានផ្សេងៗទៀតនៃនីតិអន្តរជាតិ។ ដែនដីគឺជាកត្តាចាំបាច់ក្នុងការទទួលស្គាល់រដ្ឋ[39] ។ គឺឥទ្ធិពលរបស់រដ្ឋទៅលើដែនដីខ្លួននេះហើយ ដែលធានាអធិបតេយ្យភាពដែនដី មានន័យថា ដែនដីត្រូវបានកំណត់ដោយព្រំដែនដែលញែកគ្រប់សមត្ថកិច្ចរបស់រដ្ឋមួយពីរដ្ឋមួយទៀត [40] ។ ក៏ប៉ុន្តែ ឥទ្ធិពលរបស់រដ្ឋលើដែនដីបានមានការផ្លាស់ប្តូរ ដោយសារតែទស្សនាទាន «**រដ្ឋទន់ខ្សោយ**»[41]។

ដែនដីរមែងជាកម្មវត្ថុនៃជម្លោះរវាងរដ្ឋ និងរដ្ឋជានិច្ច និងជាពិសេសក្នុងអំឡុងពាក់កណ្ដាលទីពីរនៃសតវត្សរ៍ទី២០ នៅពេលបណ្ដារដ្ឋនៅអាហ្វ្រិក និងអាស៊ីទទួលបានឯករាជ្យ។ គេបានយោងដល់នីតិអន្តរជាតិ ដើម្បីឆ្លើយតបទៅនឹងការលុបបំបាត់របបអាណានិគមនិយម ជាពិសេសដើម្បីកំណត់ព្រំ

---

[37] នេះជាទ្រឹស្ដីរបស់លោក RADNITZKY។ នៅពេលយើងពិនិត្យមើលសមត្ថកិច្ចរបស់រដ្ឋក្នុងតំបន់សមុទ្រផ្សេងៗ យើងនឹងបកត្រឡប់មកសិក្សាអំពីទស្សនាទានលំហរបស់រដ្ឋនេះវិញ។

[38] KELSEN (H.), *Principles of International Law,* New York, 1952, p. 209.

[39] ទីមួយ **ការទទួលស្គាល់** គឺជាកិច្ចឯកតោភាគី ហើយជួនកាល គឺជាលទ្ធផលនៃការចរចា។ ទីពីរ វាគឺជាកិច្ចគតិយុត្តិជាក់លាក់ដែលបង្កើតឥទ្ធិពលច្បាប់ ដែលអ្នកបង្កើតវាចង់បាន (ចាត់ទុកអ្នកបង្កើតនេះជារដ្ឋអធិបតេយ្យ)។ ទីបី ការទទួលស្គាល់គឺជាកិច្ចឆន្ទានុសិទ្ធិ មានន័យថារដ្ឋអធិបតេយ្យមួយនឹងធ្វើកិច្ចនោះអាស្រ័យតាមផលប្រយោជន៍របស់ខ្លួន។ ដូច្នេះការទទួលស្គាល់គឺជាកិច្ចនយោបាយដែលធ្វើឡើង ក្នុងគោលបំណងនយោបាយ និងយុទ្ធសាស្ត្រភូមិសាស្ត្រនយោបាយ (géostratégique)។ ឧទាហរណ៍ ការទទួលស្គាល់គណៈកម្មាធិការជាតិអន្តរកាលលីប៊ី ពីសំណាក់បស្ចិមប្រទេស។ ការប្រកាសគោលជំហររបស់អង្គការសហប្រជាជាតិ តាមរយៈការបោះឆ្នោតសម្លេងភាគច្រើន ដើរតួនាទីជំនួសឲ្យការទទួលស្គាល់ ប្រៀបបានទៅនឹងករណីការទទួលស្គាល់តំណាងនៃរបបកម្ពុជាប្រជាធិបតេយ្យនៅអង្គការសហប្រជាជាតិពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩១ដូច្នោះដែរ (VIRALLY (M.), « Panorama du droit international contemporain », *RCADI*, 1983-V, t. 183, pp. 52-76)។

[40]**អធិបតេយ្យភាព** ត្រូវបានគេឲ្យនិយមន័យថា ជាការធានាផ្នែកគតិយុត្តិចំពោះឯករាជ្យភាព។ ទី១ វាគឺជាសិទ្ធិអនុវត្តសមត្ថកិច្ចបរិបូណ៌ និងអំណាចរដ្ឋក្នុងដែនដីណាមួយ។ ទី២ អធិបតេយ្យភាពបង្ហាញពីការបដិសេធភាពចំណុះផ្នែកគតិយុត្តិទៅនឹងឆន្ទៈណាមួយ ក្រៅពីឆន្ទៈរបស់រដ្ឋ មានន័យថា ក្រៅដែនដី។ អធិបតេយ្យភាពមានកេតនភណ្ឌមូលដ្ឋានចំនួនពីរគឺ សិទ្ធិផ្ដាច់មុខរបស់រដ្ឋក្នុងការប្រើអំណាចរដ្ឋនៅលើដែនដីរបស់ខ្លួន និងសិទ្ធិសម្រេចចិត្តដោយសេរីលើផ្នែកគតិយុត្តិ។

[41] សាស្ត្រាចារ្យ **ស៊ែរ ស្យ៊ែ** (Serge SUR) ចាត់ទុកថា នៅពេលណាគេនិយាយពីរដ្ឋទន់ខ្សោយ គឺគេនិយាយពីរដ្ឋទាំងឡាយណាដែលប្រឈមមុខទៅនឹងទំនាស់ផ្ទៃក្នុងរវាងសហគមន៍ដែលបែកបាក់គ្នា (ចំណុចនេះស្ដែងឡើងតាមរយៈការសម្លាប់រង្គាល ដែលមានរចនាសម្ព័ន្ធចាត់តាំងក្នុងកម្រិតតិច ឬច្រើន) និងរដ្ឋទាំងឡាយណាដែលសេវាសាធារណៈលែងដំណើរការ ដែលមិនអាចបំពេញមុខងាររបស់ខ្លួនជារដ្ឋអធិបតេយ្យមិនអាចធានាសន្តិសុខ យុត្តិធម៌ ការអប់រំសម្រាប់ទាំងអស់គ្នា និងដែលស្គាល់ពីបាតុភូតនៃអំពើពុករលួយ ឧក្រិដ្ឋកម្ម ដែលនេះជាការចាប់ផ្ដើមបែកបាក់នៃក្បាលម៉ាស៊ីនរដ្ឋ។ ភាពទន់ខ្សោយនេះអាចបណ្ដាលមកពីអាជ្ញាធរសាធារណៈ (ដូចជារដ្ឋាភិបាល រដ្ឋបាល កងទ័ព) និងបណ្ដាលមកពីសង្គមស៊ីវិល អាចជាធាតុមួយ ឬមួយក្នុងចំណោមធាតុទាំងបី។ (SUR (S.), « Sur les États défaillants », Commentaire, n°112, hiver 2005)។

ដែនអន្តរជាតិរបស់បណ្ដាប្រទេសដែលទើបនឹងទទួលបានឯករាជ្យថ្មីៗ[42]។ ចំពោះប្រទេសអាហ្វ្រិកមួយភាគធំ គេបានរកឃើញដំណោះស្រាយក្នុងការអនុវត្តគោលការណ៍ «**ខ្សែព្រំដែនមិនកែប្រែ**» *(uti possidetis)* [43]។

លោកសាស្ត្រាចារ្យ **ក្លូដ ប្លូម៉ាន់** (Claude Blumann) សង្កេតឃើញថា «*នៅក្នុងអតីតកាលជាប្រវត្តិសាស្ត្រ ព្រំដែនស្ថិតនៅត្រង់ចំណុចប្រសព្វជាតុល្យភាពនៃទិន្នន័យសង្គមវិទ្យាចំនួនបី៖ គឺ ដែនដី ជាតិ និងរដ្ឋ*» [44]។ ដោយហេតុនេះហើយ ទើបព្រំដែនមានតួនាទីនយោបាយសំខាន់ក្នុងការបញ្ជាក់ពីអធិបតេយ្យភាព និងឯករាជ្យភាពរបស់រដ្ឋមួយ។ ព្រំដែនត្រូវតែអនុវត្ត **ចំពោះបុគ្គលទាំងអស់** [45]

[42] **រដ្ឋដែលទើបទទួលបានឯករាជ្យថ្មីៗ** ត្រូវបានឲ្យនិយមន័យថាជារដ្ឋបន្តវេន ដែលដែនដីមុនពេល **បន្តវេនរដ្ឋ** គឺជាដែនដីចំណុះមួយដែលរដ្ឋមុនមានទំនួលខុសត្រូវផ្នែកទំនាក់ទំនងអន្តរជាតិ (art. 2 §1, f, commun à la convention de Vienne (1978) sur la succession d'États en matière de traités et à la convention de Vienne (1983) sur la succession d'États en matière de biens, archives et dettes d'État)។

[43] គោលការណ៍ «**ខ្សែបន្ទាត់ព្រំដែនមិនកែប្រែ** *(uti possidetis)*» គឺជា ទ្រឹស្តីមួយដែលមានការវិវត្តិយ៉ាងខ្លាំងក្លា ។ គោលការណ៍នេះមានប្រភពដើមពីនីតិរ៉ូម៉ាំង (*ខ្ញុំហាមមិនឲ្យរំខានការកាន់កាប់ដោយភាគី ដែលមានអចលនវត្ថុ នៅក្នុងករណីដែលការកាន់កាប់នោះមិនមានប្រើអំពើហិង្សា មិនមែនជាការកាន់កាប់ដោយលាក់កំបាំង ឬមិនច្បាស់លាស់ធៀបទៅនឹងភាគីបដិបក្ខ*) គោលការណ៍នេះត្រូវបានគេយកមកអនុវត្តិនៅក្នុង **នីតិសង្គ្រាម** (*នៅពេលចប់ជម្លោះ យុទ្ធការីម្ខាងៗនៅក្នុងអធិបតេយ្យភាពរបស់ខ្លួនអាចរក្សាដែនដីដែលខ្លួនកាន់កាប់ ក្នុងអំឡុងពេលប្រតិបត្តិការយោធាចុងក្រោយសម្រេចរួចរាល់*)។ នៅពាក់កណ្ដាលទីមួយនៃសតវត្សរ៍ទី១៩ គោលការណ៍«**ខ្សែបន្ទាត់ព្រំដែនមិនកែប្រែ**» ត្រូវបានគេយកមកអនុវត្តជាលើកដំបូង នៅពេលអតីតអាណានិគមអេស្ប៉ាញនៃទ្វីបអាមេរិកឡាទីនបានទទួលឯករាជ្យ (*ព្រំប្រទល់នៃតំបន់រដ្ឋបាលក្នុងសម័យអាណានិគមនិយម ត្រូវបានប្រែក្លាយទៅជាបន្ទាត់ព្រំដែនអន្តរជាតិ*)។ ការអនុវត្តគោលការណ៍នេះបង្កឲ្យមានការភ័ន្តច្រឡំរវាងសិទ្ធិក្នុងការកាន់កាប់ ពាក់ព័ន្ធនឹងការរក្សាដែនដីដែលអតីតអាណានិគមធ្វើជាម្ចាស់កម្មសិទ្ធិពីមុន ដោយអនុលោមតាមច្បាប់អេស្ប៉ាញ (*uti possidetis juris*) និង ការកាន់កាប់តាមព្រឹត្តិហេតុ មានន័យថាការរក្សាដែនដីដែលភាគីនីមួយៗមានតាមព្រឹត្តន័យ (*uti possidetis de facto*)។ នៅទសវត្សរ៍ឆ្នាំ១៩៥០ គោលការណ៍នេះត្រូវបានកែសម្រួលដើម្បីអនុវត្តទៅលើការលុបបំបាត់របបអាណានិគមនិយម នៅពេលដែលព្រំដែនអាហ្វ្រិកស្ទើរតែទាំងស្រុង ត្រូវបានគូសកំណត់ ដោយយោងទៅតាមព្រំប្រទល់រដ្ឋបាលក្នុងសម័យអាណានិគមនិយម និងត្រូវបានបញ្ជាក់ទទួលស្គាល់ថាត្រឹមត្រូវដោយ **យុត្តិសាស្ត្រអន្តរជាតិ**។ នៅទសវត្សរ៍ឆ្នាំ១៩៩០ គោលការណ៍«**ខ្សែបន្ទាត់ព្រំដែនមិនកែប្រែ**»ត្រូវបានអនុវត្តទៅលើករណី **ការសាបសូន្យ** ឬ **ការបំបែករដ្ឋ** នៃសាធារណរដ្ឋសហព័ន្ធនៃ សហភាពសូវៀត យូហ្គោស្លាវី និង ឆេកូស្លូវ៉ាគី។ អ្នកនិពន្ធខ្លះគូសបញ្ជាក់ថា វិធាននេះមានប្រសិទ្ធិភាពមានកម្រិត ក្នុងការកំណត់ព្រំដែនអន្តរជាតិ ដោយគ្រាន់តែយោងទៅព្រំប្រទល់រដ្ឋបាលដែលមានពីមុន។ ចំណែកឯអ្នកនិពន្ធខ្លះទៀតបានលើកឡើងថា គោលការណ៍នេះជាវិធានដែលគ្មាន **លក្ខណៈចាប់បង្ខំ** (*Opinio juris*) សម្រាប់រដ្ឋដែលមានការពាក់ព័ន្ធ។ ប៉ុន្មានឆ្នាំចុងក្រោយនេះ គោលការណ៍«**ខ្សែបន្ទាត់ព្រំដែនមិនកែប្រែ**»ត្រូវបានជាក្លាយជាកម្មវត្ថុនៃការពិភាក្សាដេញដោលផ្នែកទ្រឹស្តី រវាងភាគីគាំទ្រ និងភាគីជំទាស់ទៅនឹងការអនុវត្តគោលការណ៍នេះចំពោះករណី **ការសាបសូន្យ** ឬ **ការបំបែករដ្ឋ** (BLUM (Y.), *Historic Titles in International Law,* La Haye, Martinus Nijhoff, 1965, pp. 341-342 ; KOHEN (M.), *Possession contestée et souveraineté territoriale,* Paris, PUF, 1997, p. 426 ; CORTEN (O.), DELCOURT (B.) et LEVRAT (N.) (dir.), *Démembrements d'États et délimitations territoriales : l'*uti possidetis *en questions,* Bruxelles, Bruylant, 1999, p. 300 ; BEAUDOUIN (A.), Uti possidetis *et sécession,* Paris, Dalloz, 2011, pp. 1-46)។

[44] BLUMANN (C.), « Frontières et limites », in SOCIÉTÉ FRANÇAISE POUR LE DROIT INTERNATIONAL, *La frontière,* Paris, Pedone, 1980, p. 3.

[45] សន្ធិសញ្ញាព្រំដែនរវាងរដ្ឋមានសមត្ថកិច្ចពីរ មានឥទ្ធិពល **ចំពោះបុគ្គលទាំងអស់** *(erga omnes)* ពាក់ព័ន្ធនឹងស្ថានភាពគតិយុត្តិនៃដែនដី ព្រោះថារដ្ឋទាំងពីរនោះមានសមត្ថកិច្ចផ្ដាច់មុខរួមគ្នាមួយក្នុងការធ្វើសន្ធិសញ្ញានេះ។ ពាក់ព័ន្ធនឹងគោលដៅជាសត្យានុម័តនៃការកំណត់ព្រំដែននៃតំបន់សមុទ្រដែលជាកិច្ចឯកតោភាគី រដ្ឋអនុវត្តជាឯកតោភាគីនៅក្នុងវិស័យដែលស្ថិតនៅក្នុងសមត្ថកិច្ចផ្ដាច់មុខរបស់ខ្លួន។ វិធានដែលរដ្ឋ

ហើយ *ការទទួលស្គាល់ព្រំដែនជាអន្តរជាតិ* ត្រូវបានចាត់ទុកថាជាការធានាចាំបាច់នៃអធិបតេយ្យភាព[46] និងបូរណភាពដែនដីរបស់រដ្ឋ [47] ។ ដោយហេតុនេះហើយទើបព្រំដែនត្រូវបានចាត់ទុកថាជាលក្ខខណ្ឌចាំបាច់ខានមិនបានដើម្បីធ្វើឲ្យប្រជាជាតិមួយមានស្ថិរភាព និងដើម្បីប្រែក្លាយប្រជាជាតិនោះឲ្យទៅជារដ្ឋ[48]។

ក្រោយពីទទួលបានឯករាជ្យនៅឆ្នាំ ១៩៥៣ ប្រទេសកម្ពុជាបានបង្កើនកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីពង្រឹងរដ្ឋឲ្យបានរឹងមាំ។ បញ្ហាព្រំដែនត្រូវបានលើកឡើងនៅក្នុងសន្និសីទទីក្រុងហ្សឺណែវ ហើយសារណាមួយ[49] ត្រូវបានរៀបចំឡើង ដើម្បីទាមទារមកវិញនូវដែនដីកម្ពុជាដែលរដ្ឋបាលអាណានិគមនិយមបានដកហូតពីប្រទេសកម្ពុជា និងប្រគល់ទៅឲ្យប្រទេសវៀតណាម។ អស់រយៈពេលយ៉ាងយូរមកហើយ ដែលប្រទេសកម្ពុជាបានបដិសេធមិនទទួលស្គាល់គោលការណ៍ «**ខ្សែព្រំដែនមិនកែប្រែ**» *(uti possidetis)* ដោយចាត់ទុកថា គោលការណ៍នេះជាវិធានមួយដែលគ្មាន **លក្ខណៈចាប់បង្ខំ** (*Opinio juris*) ក្នុងការកំណត់ព្រំដែនអន្តរជាតិ ដោយឈរលើមូលដ្ឋាននៃព្រំដែនរដ្ឋបាលជំនាន់អាណានិគមនិយម[50] ព្រោះថា ទោះបីជាមុនពេលទទួលបានឯករាជ្យ ព្រំដែនកម្ពុជា-ថៃគឺផ្អែកលើសន្ធិសញ្ញាអន្តរជាតិនានាក៏ដោយ[51] ព្រំដែនកម្ពុជា-វៀតណាម គឺជាព្រំដែនរដ្ឋបាលតែប៉ុណ្ណោះ[52]។

---

បង្កើត និងស្ថានភាពគតិយុត្តិដែលរដ្ឋបង្កើតឡើង គឺជាវិធាន និងស្ថានភាពគតិយុត្តិដែលមានលក្ខណៈសត្យានុម័ត និងមាន **សុពលភាពសម្រាប់ទាំងអស់គ្នា**។

[46] រដ្ឋមួយអាចជួលតំបន់មួយនៃដែនដីរបស់ខ្លួន ឬផ្ទេរការគ្រប់គ្រងតំបន់នោះទៅឲ្យរដ្ឋមួយទៀតបាន ធ្វើយ៉ាងណាឲ្យរដ្ឋនោះ អាចអនុវត្ត **សមត្ថកិច្ច** ទាំងអស់ (អំណាចរាជាធិរាជ (*impérium*) ឬ **ឧត្តមានុភាពដែនដី**) ដោយរក្សា **សិទ្ធិចាត់ចែង** ដែនដីនោះ ដែលបង្កើតបានជា **អធិបតេយ្យភាពដែនដី** (BARBERIS (J.), *Op. cit.*,p. 146)។

[47] ព្រំដែនត្រូវបានគេចាត់ទុកថាជាការបែងចែក **អធិបតេយ្យភាព** ពីរ។ គោលការណ៍គ្រឹះនៃលទ្ធិផ្តាច់មុខនិយមនៃសមត្ថកិច្ចដែនដីតម្រូវឲ្យព្រំដែនទាំងអស់មានការកំណត់យ៉ាងល្អិតល្អន់។ ដោយសារអធិបតេយ្យភាពរបស់រដ្ឋ និងការហាមប្រើកម្លាំង ដែនដីរដ្ឋទាំងមូលមិនត្រូវទទួលរងឥទ្ធិពលដែលមាននិន្នាការដកហូតដែនដីពីអំណាចរបស់រដ្ឋជាដរាប ឬមួយខណៈពេលឡើយ។ គោលការណ៍ **ព្រំដែនមិនអាចរំលោភបាន** គឺជាផលវិបាកនៃគោលការណ៍ **បូរណភាពដែនដី** រដ្ឋ។ គោលការណ៍នេះផ្សារភ្ជាប់យ៉ាងងាយទៅនឹងគោលការណ៍ **ឯករាជ្យនយោបាយ** និងការថ្កោលទោសចំពោះរាល់ **អន្តរាគមន៍យោធា** (SALMON (J.) (dir.), *Dictionnaire de droit international public,* Bruxelles, Buylant, 2001, p. 592)។

[48] BLUMANN (C.), « Frontières et limites », *Op. cit.,* p. 4.

[49] Royaume du Cambodge, *Terres cambodgiennes au Sud-Vietnam,* Phnom Penh, 1953 ; ROYAUME DU CAMBODGE, *Aide mémoire relatif à la minorité cambodgienne du Kampuchea Krom (Sud-Vietnam),* Ministère des affaires étrangères, Phnom Penh, 1961, Archive nationale du Cambodge, B-102 ; HU NIM, *Kampuchea Krom : Bas du Cambodge ou ex-Cochinchine. Situation juridique*, Mémoire préparé pour le diplôme d'étude supérieure de Droit public, Faculté de droit et de sciences économiques, Phnom Penh, 1961 (mise en page par khemarajati@sympatico.ca).

[50] ចំពោះចំនុចលំអិតនៃបញ្ហាចោទនៃការពិភាក្សានេះ សូមមើល SARIN CHHAK, *Les frontières du Cambodge, Tome I, Les frontières du Cambodge avec les anciens pays de la Fédération Indochinoise : Le Laos et le Vietnam (Cochinchine et Annam)*, Paris, Dalloz, 1966, pp. 13-22 ; JENNAR (R.), *Les frontières du Cambodge contemporain*, thèse de doctorat soutenue à l'Institut national des langues et civilisations orientales, Paris, 1998 ; HISHAM MOUSAR, *Les frontières du Cambodge après l'intervention et l'occupation armée du Vietnam*, Mémoire de DEA de Droit international et organisations internationales, dir. Y. DAUDET, Université de Paris 1 – Panthéon – Sorbonne, 2002.

[51] សន្ធិសញ្ញាបារាំង-សៀម ឆ្នាំ ១៩០៤ និង ឆ្នាំ ១៩០៧

ក្នុងរយៈពេលជាងពីរទសវត្សរ៍ក្រោយពីបានទទួលឯករាជ្យ បញ្ហាព្រំដែនគឺជាអាទិភាពមួយដ៏មានសារៈសំខាន់ជាងគេ នៅក្នុងរបៀបវារៈនយោបាយអន្តរជាតិរបស់ប្រទេសកម្ពុជា ដែលស្វែងរកការទទួលស្គាល់ព្រំដែនរបស់ខ្លួនជាអន្តរជាតិ[53]។ ការស្វែងរកព្រំដែនច្បាស់លាស់ និងមានការទទួលស្គាល់ គឺជាការធានាសន្តិសុខដែលមិនអាចកាត់ថ្លៃបាន[54]។ ក៏ប៉ុន្តែ មានតែការទទួលស្គាល់គោលការណ៍«**ខ្សែព្រំដែនមិនកែប្រែ**» ដែលជាមូលដ្ឋានសម្រាប់ការទទួលស្គាល់ព្រំដែនកម្ពុជាជា អន្តរជាតិ[55]។

---

[52] ព្រំដែនរវាងកម្ពុជា និងកូសាំងស៊ីនត្រូវបានកំណត់ឡើងតាមសេចក្តីសម្រេចស្តីពីការកំណត់ព្រំដែន ឆ្នាំ ១៨៧០ និង អនុសញ្ញាកំណត់ព្រំដែនឆ្នាំ១៨៧៣ រវាងព្រះមហាក្សត្រ ព្រះបាទសម្តេចព្រះ **នរោត្តម** និងអគ្គទេសាភិបាលកូសាំងស៊ីន។ បន្ទាប់ពីចុះសន្ធិសញ្ញានោះមក បង្គោលព្រំដែនចំនួន ១២៤ ត្រូវបានបោះ។ ដូច្នេះ គេអាចចាត់ទុកថា ព្រំដែនកម្ពុជា-កូសាំងស៊ីន គឺជាព្រំដែនអន្តរជាតិ។ ក៏ប៉ុន្តែ ព្រំដែនរវាងកម្ពុជានិងអាណាមវិញ ត្រូវបានធ្វើឡើងតាមសេចក្តីសម្រេចជាឯកតោភាគី ចុះឆ្នាំ១៨៧០ ស្តីពីការកំណត់ព្រំដែន ដោយពុំមានការឯកភាពពីកម្ពុជា។ លើសពីនេះទៀត មិនមានបង្គោលព្រំដែនណាមួយត្រូវបានបោះលើដី ជាក់ស្តែងនៅឡើយដែរ។ ដូច្នេះ យើងអាចចាត់ទុកព្រំដែនរវាងកម្ពុជា និងអាណាម គឺជាព្រំដែនរដ្ឋបាលប៉ុណ្ណោះ (អត្ថបទគោលរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា សម្រាប់បំភ្លឺស្តីពី ការងារបោះបង្គោលខណ្ឌសីមាព្រំដែនគោក និង ការកំណត់ព្រំដែនសមុទ្រ រវាង ព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋសង្គមនិយមវៀតណាម. សម័យប្រជុំពេញអង្គរដ្ឋសភា ថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ៩)។

[53]នៅក្នុងសេចក្តីព្រាងសេចក្តីថ្លែងការណ៍ស្តីពីអព្យាក្រឹតភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ប្រទេសកម្ពុជាបានស្នើរដ្ឋទាំងអស់ទទួលស្គាល់ និងគោរពអធិបតេយ្យភាព ឯករាជ្យភាព អព្យាក្រឹតភាព និងបូរណភាពដែនដីកម្ពុជា ក្នុងរង្វង់នៃព្រំដែនបច្ចុប្បន្នរបស់ខ្លួន។ នៅក្នុងសេចក្តីព្រាងពិធីសារដែលភ្ជាប់ទៅនឹងនៃសេចក្តីព្រាងសេចក្តីថ្លែងការណ៍នេះ ប្រទេសកម្ពុជាបានលើកសំណើរជូនរដ្ឋទាំងអស់អោយទទួលស្គាល់ទំហំទឹកដីនៃព្រះរាជាណាចក្រកម្ពុជាក្នុងរង្វង់ព្រំដែនបច្ចុប្បន្ននេះ ដែលឈរលើមូលដ្ឋានដូចតទៅ៖ (ក) ជាមួយប្រទេសថៃ អនុសញ្ញា ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩០៤ និងសន្ធិសញ្ញា ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩០៧ និងថ្ងៃទី០៧ ខែធ្នូ ឆ្នាំ១៩៣៧ ដែលត្រូវបានចុះហត្ថលេខារវាងបារាំង និងសៀម និងត្រូវបានបញ្ជាក់ថាត្រឹមត្រូវដោយសាលដីការបស់តុលាការយុត្តិធម៌អន្តរជាតិ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២ ដូចត្រូវបានបង្ហាញនៅក្នុងផែនទីរបស់គណៈកម្មការកំណត់ព្រំដែនរវាងឥណ្ឌូចិន និងសៀម លើមាត្រដ្ឋាន ១/២០០.០០០ (ដងរែក និងខុង លេខ៧ និងលេខ៨ បេសកកម្ម **ប៊ែរណា** (Bernard) និងបេសកកម្ម **ម៉ុងហ្គេ-បូវ៉ារាដេជ** (Monguers-Bovaradej) លេខ ១, ២, ៣, ៤ និង ៥។ (ខ) ជាមួយប្រទេសវៀតណាម ព្រំដែនកំណត់ដោយផែនទីរបស់ក្រុមភូមិសាស្ត្រឥណ្ឌូចិន SGI ខ្នាត ១/១០០.០០០ ដែលប្រើប្រាស់មុនមានកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៥៤ ហើយសម្រាប់កោះតាមឆ្នេរ គឺនៅលើផែនទីសមុទ្រដែលភ្ជាប់មកជាមួយ របស់នាយកដ្ឋានភូមិសាស្ត្រកម្ពុជា ដោយឈរលើមូលដ្ឋាននៃផែនទីសមុទ្ររបស់ក្រុមជលភូមិសាស្ត្របារាំង បោះពុម្ពពីឆ្នាំ១៩២២ ដល់ឆ្នាំ១៩៥៨ (មាត្រដ្ឋាន ១/៣០០.០០០)។ ប៉ុន្តែ សេចក្តីព្រៀងកិច្ចព្រមព្រៀងស្តីពីអព្យាក្រឹតភាពរបស់កម្ពុជា ដែលធ្វើឡើងដោយសហរដ្ឋអាមេរិក បានគេចវេះពីដោះស្រាយបញ្ហាព្រំដែនកម្ពុជា ជាមួយថៃ និងវៀតណាម (ROYAUME DU CAMBODGE, *Correspondance officielle sur le problème de la neutralité et des frontières du Cambodge*, Ministère des affaires étrangères. 1964. Archive nationale, 95, B-101)។

[54]ព្រំដែនច្បាស់លាស់ត្រូវបានធានាដោយគោលការណ៍ **ខ្សែព្រំដែនមិនអាចកែប្រែ** (Intangibilité des frontières) ដែលហាមមិនឲ្យកែប្រែប័ណ្ណ គតិយុត្តិ ដែលជាមូលដ្ឋានក្នុងការកំណត់ព្រំដែន (SALMON (J.) (dir.), *Dictionnaire de droit international public, Op. cit.*,p. 590)។ តាមន័យនៃ **ខ្សែព្រំដែនមិនអាចកែប្រែ** (Intangibilité des frontières) នេះ មាត្រា ៦២ នៃអនុសញ្ញាទីក្រុងវីយែនស្តីពី **នីតិសន្ធិសញ្ញា** បានចែងថា រដ្ឋមួយមិនអាចសំអាងលើ ***ខ«ស្ថានភាពប្រែប្រួលយ៉ាងខ្លាំងក្លា»*** (clause *rebus sic stantibus* ou changement fundamental de circonstances) «*ដើម្បីបញ្ចប់សន្ធិសញ្ញាណាមួយ ឬដើម្បីដកខ្លួនចេញពីសន្ធិសញ្ញាណាមួយពាក់ព័ន្ធ នឹងសន្ធិសញ្ញាដែលកំណត់ព្រំដែនបានឡើយ*»។

[55]ការទទួលស្គាល់គោលកាណ៍ «**ខ្សែបន្ទាត់ព្រំដែនមិនកែប្រែ**» (*uti possidetis*) នៅក្នុងការដោះស្រាយវិវាទព្រំដែន ត្រូវបានធ្វើឡើង នៅពេលដែលសម្តេចព្រះ **នរោត្តម សីហនុ** ព្រះប្រមុខរដ្ឋនៅពេលនោះ បានយកផែនទីបោន ខ្នាត ១:១០០០០០ បោះពុម្ពដោយក្រុមភូមិសាស្ត្រឥណ្ឌូចិន ទៅតម្កល់ទុកនៅអង្គការសហប្រជាជាតិក្នុងឆ្នាំ១៩៦៤ ។ ព្រះអង្គបានអំពាវនាវឲ្យមានការធានារ៉ាប់រងពីសំណាក់មហាអំណាចនានា

ការជំទាស់ដំបូងបំផុតចំពោះបញ្ហាព្រំដែន ដែលប្រទេសកម្ពុជាបានលើកឡើងជាមួយនឹងប្រទេសជិតខាងរបស់ខ្លួន គឺការប្តឹងប្រទេសថៃឡង់ក្នុងករណីប្រាសាទព្រះវិហារ[56]។ កម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងក្លាំងក្លា ដើម្បីស្វែងរកដំណោះស្រាយផ្នែកនយោបាយ និងការទូតចំពោះវិវាទព្រំដែននេះ។ បន្ទាប់ពីប្រើប្រាស់មធ្យោបាយដោះស្រាយវិវាទក្រៅផ្លូវតុលាការអស់លទ្ធភាពហើយ ទើបនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៥៩ ប្រទេសកម្ពុជាបានដាក់ពាក្យបណ្តឹងប្តឹងប្រទេសថៃឡង់នៅតុលាការយុត្តិធម៌អន្តរជាតិ (CIJ)[57]។ រឿងក្តីប្រាសាទព្រះវិហារមិនត្រឹមតែជួយពង្រឹងរដ្ឋកម្ពុជាលើផ្នែកដែនដីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយពង្រឹងការរួបរួមជាតិ ជុំវិញសម្តេចព្រះ **នរោត្តម សីហនុ** ផងដែរ។

---

ក្នុងការគោរពបូរណភាពដែនដីកម្ពុជា តាមផ្លូវនីតិអន្តរជាតិ និងឲ្យទទួលស្គាល់ ព្រមទាំងគោរពឯករាជ្យភាព អព្យាក្រឹតភាព និងបូរណភាពដែនដីក្នុងរង្វង់ខ្សែព្រំដែនបច្ចុប្បន្ន ដោយបានប្រកាសដាច់ខាតថា មិនអាចរុះរើ និងកែប្រែបានឡើយ (អត្ថបទគោលរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា សម្រាប់បំភ្លឺស្តីពី ការងារបោះបង្គោលខណ្ឌសីមាព្រំដែនគោក និង ការកំណត់ព្រំដែនសមុទ្រ រវាងព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋសង្គមនិយមវៀតណាម. សម័យប្រជុំពេញអង្គរដ្ឋសភា ថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ៨)។

[56] នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៤៩ ប្រទេសបារាំងបានផ្ញើកំណត់ទូតមួយសុំឲ្យរាជរដ្ឋាភិបាលថៃពន្យល់ពីមូលហេតុនៃការបញ្ជូនសៀមបួនរូបទៅការពារប្រាសាទព្រះវិហារ។ នៅក្នុងខែឧសភា ឆ្នាំ១៩៤៩ ប្រទេសបារាំងបានផ្ញើកំណត់ទូតថ្មីមួយទៀតដើម្បីពន្យល់អំពីមូលហេតុដែលខ្លួនចាត់ទុកព្រះវិហារស្ថិតក្នុងដែនដីកម្ពុជា។ កំណត់ទូតទាំងពីរនេះមិនបានទទួលការឆ្លើយតបឡើយ។ បន្ទាប់ពីបានទទួលឯករាជ្យនៅក្នុងឆ្នាំ១៩៥៣ ប្រទេសកម្ពុជាបានបញ្ជូនឆ្មាំទៅយាមប្រាសាទ ប៉ុន្តែបានដកមកវិញ ព្រោះសង្កេតឃើញថាឆ្មាំថៃនៅទីនោះរួចស្រេចហើយ។ រាជរដ្ឋាភិបាលកម្ពុជាបានផ្ញើកំណត់ទូតមួយជូនរាជរដ្ឋាភិបាលថៃ ដើម្បីសាកសួរព័ត៌មាន។ នៅចុងខែមីនា ឆ្នាំ១៩៥៤ កម្ពុជាបានស្នើឲ្យរាជរដ្ឋាភិបាលថៃប្តូរឆ្មាំថៃ ដោយដាក់ឆ្មាំកម្ពុជាជំនួសវិញ។ ការចរចាផ្នែកការទូតដើម្បីដោះស្រាយវិវាទព្រំដែនពាក់ព័ន្ធនឹងប្រាសាទព្រះវិហារ ត្រូវបានបញ្ឈប់នៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ១៩៥៨។ ភាគីថៃបានទទូចកាន់កាប់ប្រាសាទព្រះវិហារ និងសុំឲ្យកម្ពុជាពិចារណាអំពី «ស្ថានការណ៍អង្គហេតុ» រីឯកម្ពុជាបានយល់ព្រមចរចាជាមួយថៃ លើផ្នែកនយោបាយ ប៉ុន្តែកិច្ចចរចានោះត្រូវផ្តើមចេញពីមូលដ្ឋានគតិយុត្តិដែលមានស្រាប់។ ប៉ុន្តែ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៥៨ ប្រទេសកម្ពុជាបានប្រកាសផ្អាកទំនាក់ទំនងការទូតជាមួយប្រទេសថៃ។ ការផ្តាច់ទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរត្រូវបានប្រកាសនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៦១ (តុលាការយុត្តធម៌អន្តរជាតិ *រឿងក្តីប្រាសាទព្រះវិហារ* សាលក្រមចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២, Rec. 1962, p. 32 ; សន្និសីទកាសែតធ្វើឡើងដោយប្រធានគណៈប្រតិភូកម្ពុជានាកិច្ចចរចារខ្មែរ-ថៃ ភ្នំពេញ ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ១៩៥៨ បណ្ណសារដ្ឋានជាតិកម្ពុជា B. 691, ID : 6252 ; ROYAUME DU CAMBODGE, *Documents relatifs à la suspension des relations diplomatiques entre le Cambodge et la Thaïlande,* Phnom Penh, 1958, pp. 59, ANC, B-105 ; ROYAUME DU CAMBODGE, *Livre blanc sur la rupture des relations diplomatiques entre le Cambodge et la Thaïlande,* Phnom Penh, le 23 octobre 1961, pp. 35, ANC, B-102)។

[57] **តុលាការយុត្តធម៌អន្តរជាតិ** បានសម្រេចដោយសម្លេង៩ទល់នឹង៣ ថាប្រាសាទព្រះវិហារស្ថិតនៅក្នុងដែនដីនៃអធិបតេយ្យភាពកម្ពុជា។ តុលាការកត់សម្គាល់ថា «ជាទូទៅ នៅពេលដែលប្រទេសពីរកំណត់ព្រំដែនមួយជាមួយគ្នា គោលបំណងចម្បងមួយក្នុងចំណោមគោលបំណងផ្សេងទៀត គឺត្រូវសម្រេចឲ្យបាននូវដំណោះស្រាយមួយដែលមានស្ថិរភាព និងជាស្ថាពរ»។ ឆ្លើយតបទៅនឹងទឡ្ហីករណ៍ថៃដែលថា បន្ទាត់ព្រំដែនព្រះវិហារនៅលើផែនទីនៃឧបសម្ព័ន្ធ១ ជាបន្ទាត់ព្រំដែនមិនពិតប្រាកដ និងមានកំហុស តុលាការបានប្រកាសអំពីផលវិបាកគតិយុត្តិនៃកំហុសអង្គច្បាប់។ តុលាការគូសបញ្ជាក់ថា តាមវិធានច្បាប់ ភាគីមួយមិនអាចអះអាងថា កំហុសគឺជា **ឧបការៈនៃការយល់ព្រម** បានឡើយ ប្រសិនបើភាគីនោះបានរួមចំណែកប្រព្រឹត្តកំហុសនេះដោយខ្លួនឯង ឬប្រសិនបើភាគីនោះអាចបញ្ចៀសកំហុសបាន ឬប្រសិនបើកាលៈទេសៈអនុញ្ញាតឲ្យភាគីនោះដឹងអំពីលទ្ធភាពនៃកំហុស។ តុលាការយល់ឃើញថាគ្រាន់តែគុណសម្បត្តិ និងសមត្ថភាពរបស់បុគ្គលនៃភាគីថៃដែលបានឃើញផែនទីឧបសម្ព័ន្ធ១ប៉ុណ្ណោះ ធ្វើឲ្យមានការលំបាកចំពោះប្រទេសថៃក្នុងការអះអាងអំពីកំហុសនេះតាមផ្លូវច្បាប់។ តុលាការសន្និដ្ឋានថាអស់រយៈពេល៥០ឆ្នាំប្រទេសថៃបានទទួលផលប្រយោជន៍ដែលអនុសញ្ញាកំណត់ព្រំដែនផ្តល់ឲ្យ និងថាដោយហេតុនេះ ប្រទេសថៃត្រូវទទួលស្គាល់អធិបតេយ្យភាពកម្ពុជាលើតំបន់ទំនាស់ ដូចដែលមានចែងក្នុងអនុសញ្ញា (*Affaire du Temple de Préah Vihear (Cambodge c.*

គឺឈរលើភាពសមហេតុផលនៃការពង្រឹងរដ្ឋនេះហើយ ទើបប្រទេសកម្ពុជាបានកំណត់ព្រំដែនសមុទ្ររបស់ខ្លួន ក្រោមអំណាចនៃនីតិសមុទ្រអន្តរជាតិ[58]។ ជាការពិតណាស់ ព្រំដែនគោក និងព្រំដែនសមុទ្រមានលក្ខណៈដូចគា និងខិតជិតគ្នា [59] ទោះបីជាមានភាពខុសគ្នាខ្លះដោយសារលក្ខណៈរូបសាស្ត្រនៃលំហដែលបានកំណត់រួច (លំហសមុទ្រគឺជាទឹកដែលជាវត្ថុរាវ ចំណែកឯដីគោកវិញ គឺជាវត្ថុរឹង) លក្ខខណ្ឌក្នុងការកំណត់ព្រំដែន (មានវិធានច្បាប់ដែលចែងអំពីការកំណត់ព្រំដែនសមុទ្រ ខណៈពេលដែលបន្ទាត់ព្រំដែនគោកត្រូវបានកំណត់តាមរយៈការចរចារវាងរដ្ឋ និងរដ្ឋ) និង អត្ថន័យជានិមិត្តរូប (ព្រំដែនគោកខណ្ឌចែកអធិបតេយ្យភាពពេញលេញ រីឯព្រំដែនសមុទ្រខណ្ឌចែកត្រឹមតែយុត្តាធិការសមុទ្រ ដែលពាក់ព័ន្ធនឹង «**សិទ្ធិអធិបតេយ្យ**» ដែលមានកម្រិត) ក៏ដោយ។ ទោះជាយ៉ាងណាក្តី ព្រំដែនគោក និងព្រំដែនសមុទ្រខិតជិតគ្នា ពាក់ព័ន្ធនឹងលក្ខណៈគតិយុត្តិនៃលំហដែលត្រូវបានកំណត់ព្រំដែន (ការធ្វើដែនដីភាវូបនីយកម្មលំហសមុទ្រ) និងពាក់ព័ន្ធនឹងរបបគតិយុត្តិនៃលំហទាំងនោះ (លក្ខណៈរួមសម្រាប់ព្រំដែនទាំងពីរប្រភេទ)។

ដូច្នេះ ទស្សនទានគតិយុត្តិអំពីព្រំដែន អធិបតេយ្យភាព និងឯករាជ្យ ហាក់ដូចជាមានទំនាក់ទំនងគ្នាយ៉ាងស្អិតរមួត។ ព្រំដែនខណ្ឌចែកអធិបតេយ្យភាព រីឯ«*អធិបតេយ្យភាព ក្នុងទំនាក់ទំនងរវាងរដ្ឋ និងរដ្ឋ មានន័យថាឯករាជ្យភាព។ ពាក់ព័ន្ធនឹងតំបន់ខ្លះក្នុងពិភពលោក ឯករាជ្យគឺជាសិទ្ធិក្នុងការអនុវត្តមុខងាររបស់រដ្ឋ យ៉ាងផ្តាច់មុខដោយមិនឲ្យរដ្ឋផ្សេងទៀតចូលពាក់ព័ន្ធបានឡើយ*»[60] ។

ក្នុងន័យនេះ អធិបតេយ្យភាពដែនដីទាមទារឲ្យមានសិទ្ធិផ្តាច់មុខក្នុងការអនុវត្តសកម្មភាពទាំងឡាយរបស់រដ្ឋ។ អាស្រ័យហេតុនេះហើយ ទើបគេអាចផ្តល់និយមន័យការកំណត់ព្រំដែនសមុទ្រ ថាជាដំណើរការ ពង្រីក **ខ្សែព្រំដែនសងខាង** (limites latérales) និង **ខ្សែព្រំដែនខាងក្រៅ** (limites extérieures) ដើម្បីអនុវត្តសមត្ថកិច្ចរដ្ឋ។ ទោះជាយ៉ាងនេះក្តី ការអនុវត្ត «**សិទ្ធិអធិបតេយ្យ**» របស់កម្ពុជាទៅលើលំហសមុទ្ររបស់ខ្លួន ត្រូវប៉ះទង្គិចនឹងការទាមទារដែនដីពីសំណាក់ប្រទេសថៃឡង់ដ៍ ហើយប្រការនេះបានបង្កើតជាតំបន់ត្រួតគ្នានៃអធិបតេយ្យភាពរវាងប្រទេសជិតខាងទាំងពីរ[61] និងដែលបណ្តាលឲ្យមានវិវាទព្រំដែនសមុទ្ររវាងកម្ពុជា និងថៃឡង់ដ៍។

---

*Thaïlande)*, Arrêt, 15 juin 1962, Recueil CIJ, p. 26, p. 37 ; TCHIKAYA (B.), *Mémento de la jurisprudence. Droit international public,* 5e édition, Hachette, Paris, 2010, pp. 77-79)។

[58] នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៥៧ ប្រទេសកម្ពុជាបានអនុម័តព្រះរាជក្រឹត្យស្តីពី **ខ្សែបន្ទាត់មូលដ្ឋាន** ដើម្បីវាស់ **សមុទ្រដែនដី** ដែលគេអាចចាត់ទុកបានថា ជាធាតុផ្សំមួយនៃដែនដីរបស់រដ្ឋ។

[59] BARDONNET (D.), « Frontières terrestres et frontières maritimes », *AFDI,* vol. 35, 1989, p. 1.

[60] C.P.A., *Affaire de l'île de Palmas (Etats-Unis d'Amérique c. les Pays-Bas)*, sentence du 4 avril 1928, R.S.A. 1928, p. 8.

[61] នៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩៧២ ប្រទេសកម្ពុជាបានអនុម័តព្រះរាជក្រឹត្យមួយ ដើម្បីគូសព្រំប្រទល់ **ខ្ពង់រាបឆ្នាតសមុទ្រ** របស់ខ្លួន។ ជាការឆ្លើយតបមកវិញ នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៧៣ ប្រទេសថៃបានអនុម័តសេចក្តីប្រកាសមួយដែលបង្កើតខ្សែបន្ទាត់កំណត់ព្រំដែន **ខ្ពង់រាបឆ្នាតសមុទ្រ**ថៃ ដោយបង្កើតឲ្យមានតំបន់ត្រួតគ្នានៃអធិបតេយ្យភាពរវាងកម្ពុជា-ថៃ ក្នុងឈូងសមុទ្រថៃ។

## §២. ស្ថានភាពឈូងសមុទ្រថៃក្នុងក្របខ័ណ្ឌទំនាស់ព្រំដែនសមុទ្រកម្ពុជា-ថៃឡង់

យើងចាំបាច់ត្រូវសិក្សាពិនិត្យសារធាតុនៃវិវាទព្រំដែនសមុទ្ររវាងកម្ពុជា និងថៃឡង់នេះ ក្នុងគោលដៅស្វែងរកដំណោះស្រាយដោយសន្តិវិធី។ វិវាទនេះអាចដោះស្រាយបានតាមរយៈ **ការកំណត់ព្រំដែន** សមុទ្រ។ ដូច្នេះ យើងគប្បីត្រូវវិភាគស្ថានភាពនៃឈូងសមុទ្រថៃ ជាពិសេសទីតាំងភូមិសាស្ត្រ និងធនធានជីវសាស្ត្រ ក៏ដូចជាភោគទ្រព្យរ៉ែ ព្រោះថាកត្តាទាំងនេះអាចមានឥទ្ធិពលដល់ការកំណត់ព្រំដែនសមុទ្រកម្ពុជា-ថៃ[62]ជាយថាហេតុ។

### ក. ភូមិសាស្ត្រនៃឈូងសមុទ្រថៃ

ឈូងសមុទ្រថៃស្ថិតនៅខាងជើងខ្សែបន្ទាត់ប្រវែង ២០៨ ម៉ាយល៍សមុទ្រ[63] ដែលវាស់ចេញពីចំណុច **កាម៉ៅ** (Ca Mau) ដែលស្ថិតនៅត្រង់ចុងខាងត្បូងបំផុតនៃប្រទេសវៀតណាម ទៅជាប់នឹងឆ្នេរសមុទ្រម៉ាឡេស៊ីជិត **កូតា បារូ** (Kota Bahru) (៦° ១២′N, ១០២° ២០′E)។ ឈូងសមុទ្រថៃលាតសន្ធឹងពីជើងទៅត្បូងប្រវែង ៤០០ ម៉ាយល៍សមុទ្រ ហើយនៅខាងជើងបំផុតគឺជាឆកសមុទ្របាងកក ដែលមានសណ្ឋានជាចតុកោណ[64]។ ឈូងសមុទ្រថៃមានក្រឡាផ្ទៃប្រមាណជា ២៨៣.៧០០ គ.ម²[65]។ ឈូងសមុទ្រនេះ អាចចាត់ទុកជា **សមុទ្រពាក់កណ្ដាលបិទ**[66] ដែលមានជម្រៅមិនសូវជ្រៅឡើយ មានបាតរាបស្មើ ដែលបែងចែកប្រទេសកម្ពុជាពីឧបទ្វីបម៉ាឡាកា កោះស៊ូម៉ាត្រា និងកោះជ្វា។ ឈូងសមុទ្រថៃនៅជាប់នឹង **សមុទ្រចិនខាងត្បូង** និងអាចចាត់ទុកថាជាដៃសមុទ្រចិនក៏ថាបាន។ នៅក្នុងបាតសមុទ្រ មានព្រែកក្រោមសមុទ្រមួយដែលស្ថិតនៅចំកណ្ដាលពាមសមុទ្រ និងមានជម្រៅ ៦០ ម៉ែត្រ និងទទឹង ៥០គ.ម ដែលភ្ជាប់ឈូងសមុទ្រថៃនៅនឹងសមុទ្រចិនខាងត្បូង[67]។ ឈូងសមុទ្រនេះ មានបណ្ដោយប្រវែង៤៥០ម៉ាយល៍សមុទ្រ និងទទឹងជាមធ្យមប្រវែង ២០៨ ម៉ាយល៍សមុទ្រ។ ដូច្នេះ ឈូងសមុទ្រថៃទាំងមូលបានក្លាយជាមុខសញ្ញានៃការទាមទារពីសំណាក់រដ្ឋជាប់សមុទ្រទាំងអស់ ដូចជា កម្ពុជា

---

[62]យើងចាំបាច់ត្រូវធ្វើការវិភាគនូវស្ថានភាពទូទៅនៃឈូងសមុទ្រថៃ ព្រោះថាភូមិសាស្ត្រមានឥទ្ធិពលយ៉ាងខ្លាំងក្លាទៅលើ **ការកំណត់ព្រំដែនសមុទ្រ**។

[63] ១ ម៉ាលយ៍សមុទ្រអន្តរជាតិ ស្មើនឹង ១.៨៥២,៣ ម៉ែត្រ។

[64] PRESCOTT (V.), *The Gulf of Thailand: Maritime Limits to Conflict and Cooperation,* Mima, Kuala Lumpur, 1998, pp. 10.

[65] *Ibid.,* p. 11.

[66] មាត្រា ១២២ នៃអនុសញ្ញា **ម៉ុងតេហ្គោ បេយ៍** (Montego Bay) បានឲ្យនិយមន័យ **សមុទ្របិទ** ឬ **សមុទ្រពាក់កណ្ដាលបិទ** ថាជា «**ឈូងសមុទ្រ** អាង ឬសមុទ្រ ដែលព័ទ្ធជុំវិញដោយរដ្ឋជាច្រើន និងតភ្ជាប់ទៅនឹងសមុទ្រមួយទៀត ឬមហាសមុទ្រដោយ **ច្រកសមុទ្រ** ចង្អៀតមួយ ឬ គឺជាតំបន់ដែលកើតឡើងទាំងស្រុង ឬភាគច្រើនដោយ **សមុទ្រដែនដី** និង **តំបន់សេដ្ឋកិច្ចផ្ដាច់មុខ** របស់រដ្ឋជាច្រើន»។ ដូច្នេះ អនុលោមតាមអនុញ្ញា Montego Bay ឈូងសមុទ្រថៃ អាចចាត់ទុកថាជា **សមុទ្រពាក់កណ្ដាលបិទ** ។

[67] PIYAKARNCHANA (T.), *Yield dynamics as an index of biomass shifts in the Gulf of Thailand.* In SHERMAN (K.) et ALEXANDER (L.M.), (eds), *Biomass Yields and Geography of Large Marine Ecosystems,* AAAS Symposium 111, Westview Press, Inc., Boulder, CO, 1989, pp. 95-142.

ម៉ាឡេស៊ី ថៃ និងវៀតណាម ក្នុងក្របខ័ណ្ឌនៃការបង្កើត **តំបន់សេដ្ឋកិច្ចផ្តាច់មុខ** និង**ខ្ពង់រាបបាតសមុទ្រ** ប្រវែង ២០០ម៉ាយល៍សមុទ្រ[68]។

ទឹកនៃឈូងសមុទ្រថៃមានសភាពស្ងប់ស្ងាត់ល្អ។ ព្យុះស៊ីក្លូន និង ទីហ្វុងដ៏សាហាវដែលមានញឹកញាប់នៅក្នុងសមុទ្រចិន មិនដែលកើតមាននៅឈូងសមុទ្រនេះឡើយ។ គឺមានតែកូនព្យុះតូចតាចខ្លះប៉ុណ្ណោះ នៅពេលដែលរបបខ្យល់មូសុងផ្លាស់ប្តូរ។ គេឃើញមាន **ថ្មប៉ប្រះទឹក** និងផ្កាថ្មតិចតួច។ ឈូងសមុទ្រថៃមានភាពអនុគ្រោះដល់ការធ្វើនាវាចរ។ ប៉ុន្តែ ចន្លោះពីខែមិថុនា ដល់ខែតុលា ខ្យល់មានសភាពពុំទៀងទាត់ ហើយព្យុះភ្លៀងអាចកើតឡើងភ្លាមៗ ហើយអាចបង្កឲ្យមានគ្រោះថ្នាក់[69]ដល់ការធ្វើនាវាចរ។ សីតុណ្ហភាពជាមធ្យមប្រចាំឆ្នាំលើផ្ទៃសមុទ្រប្រែប្រួលជុំវិញ ២៧$^{0}$C[70]។

ឈូងសមុទ្រថៃស្ថិតក្រោមឥទ្ធិពលនៃជំនោរទឹក។ គឺជាប្រភេទជំនោរចម្រុះ និងខ្សោយ ដោយមានកម្រិតខ្លាំងតែនៅពេលថ្ងៃ និងពុំបង្កឲ្យមានចរន្តទឹកហូរខ្លាំងឡើយ[71]។ របបជំនោរមានផលប៉ះពាល់ទៅលើ**នីតកំណត់ព្រំដែនសមុទ្រ** ជាពិសេសពាក់ព័ន្ធនឹងការកំណត់ **ខ្សែបន្ទាត់មូលដ្ឋាន** ឬការកំណត់ **ថ្មបប្រ៉ះទឹក**[72]។ ក្នុងពេលខ្យល់មូសុងបក់ពីទិសឦសាន ពីខែវិច្ឆិកា ដល់ខែមីនា ចរន្តទឹកហូរទៅទិសនិរតី ហើយមួយផ្នែកហូរឡើងទៅរកឆ្នេរម៉ាឡាកា រួចបត់តាមទិសទ្រនិចនាឡិកា។ ក្នុងពេលខ្យល់មូសុងបក់ពីទិសនិរតី ពីពាក់កណ្តាលខែឧសភា ដល់ខែកញ្ញា គេសង្កេតឃើញមានបាតុភូតបញ្ច្រាស់គ្នាវិញ។ ខ្យល់មូសុងបក់ពីទិសនិរតីនេះនាំមកនូវភ្លៀងធ្លាក់ខុសគ្នាយ៉ាងខ្លាំងពីប្រទេសមួយទៅប្រទេសមួយទៀត។ បរិមាណទឹកភ្លៀងធ្លាក់សរុបប្រចាំឆ្នាំប្រែប្រួលពី៥០០ ទៅ១០០០មីលីម៉ែត្រ[73]។

ឈូងសមុទ្រថៃព័ទ្ធជុំវិញដោយឆ្នេរសមុទ្រនៃប្រទេសចំនួន៤ ដែលមានប្រវែង ២.៤៦០គ.ម ក្នុងនោះមានប្រទេសកម្ពុជា (៤៦០គម) ប្រទេសម៉ាឡេស៊ី (១៥០គ.ម) ប្រទេសថៃឡង់ (១.៥៦០គ.ម) និងប្រទេសវៀតណាម (២៣០គម)[74]។ ជាទូទៅ ឆ្នេរសមុទ្រម៉ាឡេស៊ី មានលក្ខណៈត្រង់ស្មើ ជាធម្មតា និងមិនសូវក្រហេងក្រហូងឡើយ[75]។ លក្ខណៈត្រង់ស្មើនេះលាតសន្ធឹងរហូតដលាប្រទេសថៃ ត្រង់ជ្រោយលឹម កូឡាមប៉ុក (Cap Lem-Kolam Pook) ដែលនៅទីនោះ ឆ្នេរមានលក្ខណៈក្រហេងក្រហូង និងមានឆកតូចៗមួយចំនួន។ ឆកសមុទ្របាងកក ជាឆកធំជាងគេបំផុតនៃឈូងសមុទ្រថៃ។ ចាប់ពីជ្រោយលី

[68] NGUYEN HONG THAO, *Le Vietnam et ses différends maritimes dans la Mer de Bien Dong (Mer de Chine méridionale)*, Paris, Pedone, 204, p. 13.

[69] KHIM (Y.), *Le Cambodge et le problème de l'extension des espaces maritimes dans le golf de Thaïlande*, Thèse pour le doctorat d'État en droit, Paris II, 1978, p. 23.

[70] KONINCK (R. de.), *L'Asie du Sud-Est,* Paris, Armand Colin, 2e édition, 2009, p. 28.

[71] KHIM (Y.), *Op. cit.,* p. 21.

[72] «**ថ្មបប្រ៉ះទឹក**» គឺជាកោះធម្មជាតិដែលមានសមុទ្រព័ទ្ធជុំវិញ ដែលគេអាចមើលឃើញពេលទឹកនាច តែលិចបាត់ក្នុងទឹកនៅពេលទឹកជោរ (មាត្រា ១៣ នៃអនុសញ្ញា Montego Bay ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨២)។

[73] KONINCK (R. de.), *Op. cit.,* p. 34.

[74] KHIM (Y.), *Op. cit.*, p. 24.

[75] *Ibid.*

យ៉ងទៅ (Cap Liant) ឆ្នេរសមុទ្រថៃបែកក្រហេងក្រហូង ចំនួន៧ ឬ៨កន្លែង[76]។ ខ្សែទឹកធំៗដែលហូរចាក់ទៅក្នុងឈូងសមុទ្រ ក្នុងតំបន់ ប្រទេសថៃ មានដូចជា ទន្លេចៅប្រយ៉ា ទន្លេមេខ្លង និងទន្លេតាពី។ ឆ្នេរសមុទ្រវៀតណាម ដែលក្នុងតំបន់ហាទៀង មានលក្ខណៈរឆេងរឆូង និងសម្បូរថ្មផ្ទាំងថ្មធំៗដែលបង្កើតបានជាជ្រោយឌើតាប (Cap de Table)[77]។ ខ្សែទឹកធំដែលហូរចាក់ទៅក្នុងតំបន់ខាងលើគឺទន្លេមេគង្គ។ ចាប់ពីជ្រោយនេះទៅ ឆ្នេរសមុទ្រមានលក្ខណៈរូងជ្រៅបង្កើតបានជាឆករាជា (Baie de Rach-Gia) ហើយហូរចុះទៅកាន់ទិសខាងត្បូងត្រង់ រហូតដល់ឆកការលុន (Cua-Lon) ដែលចុងឆកកាមៅ (Ca Mau) បង្កើតបានជាព្រំដែនខាងត្បូងនៃឈូងសមុទ្រថៃ[78]។

ប្រទេសកម្ពុជាព័ទ្ធជុំវិញដោយឆ្នេរនៃឈូងសមុទ្រថៃ ដែលមានប្រវែង ៤៦០គម។ ឆ្នេរសមុទ្រនេះមានប្រវែងមួយភាគប្រាំមួយនៃព្រំដែនកម្ពុជាសរុប។ ឆ្នេរសមុទ្រកម្ពុជាលាតសន្ធឹងពីខេត្តកំពតដល់ខេត្តកោះកុង ដែលមានឆ្នេរទំនាប ល្បាប់ភក់ដែលសម្បូរដោយដើមកោងកាង និងឆ្នេរមានផ្ទាំងថ្មក្រហេងក្រហូង ភាគច្រើនមានឆ្នេរខ្សាច់ ដែលមានដើមស្វាយដុះនៅឆ្លាស់គ្នាគួរឲ្យកត់សម្គាល់។ ជាទូទៅទីណាមានភ្នំស្ថិតនៅកៀកសមុទ្រ ទីនោះមានតំបន់ឆ្នេរក្រហេងក្រហូង សម្បូរដោយផ្ទាំងថ្ម ដែលបង្ករគ្រោះថ្នាក់ដល់ការធ្វើនាវាចរជាញឹកញាប់។ ច្រាំងសមុទ្រទាំងមូលដែលលាតសន្ធឹងពីឆកវាលរិញដល់កែប មានសភាពទាប ដោយសារមានកោះដ៏ធំ ឈ្មោះកោះត្រល់ (Phu-Quoc) ជារបាំងខ្យល់មូសុងនិរតីនៅបាំងចំពីមុខ។ នៅគ្រប់ទីកន្លែងផ្សេងទៀត តំបន់ឆ្នេរដែលកើតពីដីសណ្តរនៃទន្លេក្បែរឆ្នេរ មានស្ថានភាពទាប។

អាងឈូងសមុទ្រថៃ គឺជាប្រព័ន្ធជលធារ ដែលមានស្ទឹង និងទន្លេតូច និងខ្លីល្មមជាង ២០ ដែលមានរបបទឹកហូរខ្លាំង និងយ៉ាងគំហុកហូរចាក់ទៅក្នុងសមុទ្រ ដែលបង្កើតឲ្យមាននូវរបបទឹកជោរ និងនាច ដូចជាស្ទឹងមេទឹក ព្រែកតាតៃ ស្ទឹងថៃអារ៉ែង ព្រែកពិផាត ព្រែកកំពង់សោម និងស្ទឹងកំពតជាដើម។ ឈូងសមុទ្រថៃ គឺជាផ្លូវនាវាចរណ៍សមុទ្រដ៏មានសារសំខាន់សម្រាប់សេដ្ឋកិច្ចកម្ពុជា។ កំពង់ផែស្វយ័តក្រុងព្រះសីហនុអាចឲ្យនាវាធំៗមកពីសមុទ្រអន្តរជាតិចូលចតបាន និងចូលរួមវិភាគទានយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចតំបន់សមុទ្រកម្ពុជា។

ឆ្នេរសមុទ្រកម្ពុជាចាប់ពីទិសពាយ័ព្យ ដល់ទិសអាគ្នេយ៍ អាចចែកចេញជា៥ផ្នែកគឺ៖

- ពីព្រំដែនថៃ (ចាំយាម) ដល់ព្រែកគគីរ ឆ្នេរមានលក្ខណៈទាប មានល្បាប់ភក់ និងសម្បូរដើមកោងកាង។

[76] KHIM (Y.), *Op. cit.*, p. 26.
[77] *Ibid.*, p. 27.
[78]**ឆ្នេរផត** នៃឈូងសមុទ្រថៃបង្កើតបានជា«**កាលៈទេសៈពិសេស**» ដែលត្រូវយកមកគិតគូរនៅក្នុងការកំណត់ព្រំដែនសមុទ្រ ក្នុងគោលដៅទទួលបាននូវ«**លទ្ធផលប្រកបដោយសមធម៌**»។

- ពីព្រែកគគីរ ដល់ជ្រោយស្វរិយោវង្ស ឆ្នេរដែលស្ថិតនៅក្បែរជួរភ្នំ និងទទួលរងខ្យល់មូសុង សម្បូរដោយផ្ទាំងថ្ម និងមានរាងក្រហេងក្រហូង។ នៅកន្លែងខ្លះ ជ្រោយទាំងនេះមានឆកសមុទ្រ ដ៏ស្រស់ត្រកាល ហ៊ុំព័ទ្ធដោយដើមស្វាវ ឬដើមដូង ដូចជា ជ្រោយយាយសែន ជ្រោយស្មាច់ និង ជ្រោយស្វរិយោវង្ស។
- ឆ្នេរនៃឆកកំពង់សោមព័ទ្ធជុំវិញដោយប្រជុំកោះដូចភ្នំជាជួរៗ។ ពីទិសខាងលិចទៅទិសខាងកើត ឆកនេះមានព្រំប្រទល់ជាប់នឹងជ្រោយស្វរិយោវង្ស ជ្រោយថ្មស និងជ្រោយវាលរិញ ដែលមាន កំពង់ផែក្រុងព្រះសីហនុ។ នៅទិសខាងលិច តំបន់ឆ្នេរមានរាងទាប និងត្រង់។ នៅទិសខាង កើត តំបន់ឆ្នេរមានសណ្ឋានទាប តែនៅទិសខាងជើង ឆ្នេរមានសភាពដូចថ្ម។ នៅខាងត្បូង គេ ឃើញមាន **ថ្មប៉ប្រះទឹក** ។ ឆកដ៏ល្វឹងល្វើយមួយនេះចាប់គោកបន្តិចម្តងៗ ដោយសារតែមាន ល្បាប់ហូរចាក់ពីព្រែកជាច្រើនសន្ទឹកសន្ទាប់។
- ពីក្រុងព្រះសីហនុ ដល់ឆកទឹកសាប គេឃើញមានឆ្នេរខ្សាច់ ដែលសម្បូរដោយដើមស្វាវ នៅ ឆ្លាស់គ្នាជាមួយនឹងផ្ទាំងថ្ម។ នៅចំកណ្តាលឆ្នេរនេះ មានឆករាម ដែលនៅខាងចុងមានកំពង់ផែ រាម ដែលត្រូវមានរបាំងការពារខ្យល់មូសុង។
- ពីឆកទឹកសាប ដល់ហាទៀង (ប្រទេសវៀតណាម) តំបន់ឆ្នេរផតចូលក្នុងដោយសារឆកទឹក សាប និងឆកវាលរេញ ដែលមានឆ្នេរទាប និងពេញដោយភក់។ បន្ទាប់មក តំបន់ឆ្នេរនេះ មានរាងជាធ្នូទ្រេតទៅរកឆ្នេរដ៏ចោទនៃភ្នំបូកគោ និងសម្បូរដោយដើមកោងកាង។ នៅទិសខាង កើតពាមនៃស្ទឹងកំពត តំបន់ឆ្នេរនៅទាបដដែល លើកលែងតែជ្រោយកែប ដែលជាតំបន់ដែល ជាទីកំសាន្តដ៏សែនមនោរម្យ។

កោះមួយចំនួនស្ថិតនៅក្បែរឆ្នេរសមុទ្រកម្ពុជា ជាប់នឹងជួរភ្នំក្រវ៉ាញ ហើយកោះទាំងនោះ គឺជា កោះដែលស្ថិតនៅជួរមុខគេ ដូចជាកោះកុងមានកំពស់ខ្ពស់ជាង ៤៥០ម៉ែត្រ ចំណែកឯកោះរ៉ុងវិញមាន កំពស់ខ្ពស់ជាង ៣០០ម៉ែត្រ ។ កោះកុង និងកោះរ៉ុងនេះ មានប្រជាជនជាអ្នកនេសាទត្រីរស់នៅជា ប្រចាំ[79]។ កោះទាំងពីរនេះគ្របដណ្តប់ដោយព្រៃស្តុក ដែលគេមិនទាន់ធ្វើអាជីវកម្មនៅឡើយ។ ក៏ប៉ុន្តែ កោះទាំងនេះត្រូវបានប្រើប្រាស់ជាកន្លែងសម្រាប់នេសាទត្រីដ៏សំខាន់ នៅក្នុងរដូវមូសុងឦសាន [80] ។ កោះទាំងអស់ដូចជា កោះកុង កោះរ៉ុង កោះរុងសន្លឹម និងកោះសេះ មានក្រឡាផ្ទៃជាមធ្យមចំនួន ៥,៦០ គម$^{២}$ និងមានកម្ពស់ជាមធ្យម ២៤៧ម៉ែត្រ។

[79] NORODOM RANARIDDH, *Les limites du domaine maritime du Cambodge*, Thèse pour le doctorat d'État en droit, Université de droit, d'économie et des sciences d'Aix-Marseille, juin 1976, p. 82.
[80] TAN KIM HUON, *Géographie du Cambodge, de l'Asie des Moussons et des principales puissances.* Phnom Penh, 1961, p. 27.

## ១. ជីវធនធាន និងភោគទ្រព្យរ៉ែ

ការសិក្សាពីព្រំដែនសមុទ្រក៏ត្រូវផ្តោតទៅលើជីវធនធាន និងភោគទ្រព្យរ៉ែផងដែរ។ ជាការពិតណាស់ ព្រំដែនសមុទ្រត្រូវសម្រួលដល់ការអភិរក្សជីវធនធាន និងភោគទ្រព្យរ៉ែនៃឈូងសមុទ្រថៃ[81]។ ការអនុវត្តរបស់បណ្តារដ្ឋនៅអាស៊ីក៏អនុគ្រោះដល់ការគ្រប់គ្រង និងការធ្វើអាជីវកម្មរួមគ្នាទៅលើធនធានទាំងនោះផងដែរ[82]។ ក្នុងន័យនេះ គោលបំណងនៃការបង្កើត **តំបន់សេដ្ឋកិច្ចផ្តាច់មុខ** ក្នុងក្របខណ្ឌនៃអនុសញ្ញា Montego Bay ឆ្នាំ១៩៨២ មានមានគោលដៅសំខាន់បំផុត គឺការពឹង ផ្អែកយ៉ាងខ្លាំងនៃរដ្ឋជាប់ឆ្នេរ ចំពោះធនធានទាំងឡាយ ដែលស្ថិតនៅក្នុងតំបន់ឆ្នេរសមុទ្រ។

សមុទ្រនៃឈូងសមុទ្រថៃស្ថិតនៅលើខ្ពង់រាបបាតសមុទ្រមិនសូវជាជ្រៅប៉ុន្មានទេ ហើយងាយទទួលទឹកល្បាប់ពីទន្លេ និងស្ទឹងបឹងបួរជាច្រើនដែលប្រោះដីដ៏មានជីវជាតិ មុននឹងហូរចាក់ចូលទៅក្នុងសមុទ្រ។ ដោយសារជំរៅរាក់នេះ និងដោយសារលក្ខខណ្ឌជីវសាស្ត្រសម្បូរបែបនៃទឹកសមុទ្រ ឈូងសមុទ្រថៃអាចរក្សាពូជសត្វវន្តជាតិ និងមច្ឆជាតិជាច្រើនប្រភេទ ដែលជាកម្មវត្ថុនៃការចង់បានពីសំណាក់នាវាធ្វើអាជីវកម្មក្នុងតំបន់ ក៏ដូចជានាវានេសាទបរទេសផងដែរ[83]។

ធនធានមច្ឆាក្នុងឈូងសមុទ្រថៃទាក់ទាញអ្នកនេសាទយ៉ាងច្រើនសន្ធឹកសន្ធាប់។ សត្វដែលពេញនិយម ជាងគេគឺក្តាម បង្កង បបែល ឆ្លាម ត្រីស្បៃកា និងត្រី anchois។ អ្នកនេសាទជាច្រើននាក់ប្រកបរបបនេសាទនៅក្នុងឈូងសមុទ្រនេះ។ ការនេសាទសមុទ្រនៅក្នុងឈូងសមុទ្រថៃកាន់តែកើនឡើងហួសប្រមាណ ហើយការនេសាទនេះទៀតដើរតួនាទីសំខាន់ជាយូរមកហើយសម្រាប់រដ្ឋជាប់ឆ្នេរឈូងសមុទ្រថៃ តាំងពីមុនមាននីតិសមុទ្រទំនើបទៅទៀត[84]។ ផលនេសាទជាមធ្យមនាពេលបច្ចុប្បន្ននេះមានចំនួន ១,១ លានតោន[85] ធៀបទៅនឹងឆ្នាំ១៩៨៨ ដែលមានចំនួនដល់ទៅ២,៧តោន។ ដូច្នេះ

---

[81] ក្នុងការដោះស្រាយដោយ *មជ្ឈត្តការរវាងប្រទេសស៊ុយអែត និងន័រវេស* ជាដំបូង គេបានកែតម្រូវខ្សែបន្ទាត់ព្រំដែនសមុទ្រ ដើម្បីជៀសវាងការបែងចែកតំបន់សំបុកត្រី ក្នុងគោលដៅការពារបរិស្ថាន (Affaire des *Grisbardana entre la Suède et la Norvège*, CPA, sentence du 23 octobre 1909, p. 31)។

[82] យើងអាចលើកឧទាហរណ៍នៃ **តំបន់អភិវឌ្ឍន៍រួមគ្នា** រវាងកូរ៉េខាងត្បូង និងជប៉ុន (១៩៧៤) រវាងម៉ាឡេស៊ី និងថៃ (១៩៧៩) រវាងម៉ាឡេស៊ី និងវៀតណាម (១៩៩២) រវាងអូស្ត្រាលី និងឥណ្ឌូនេស៊ី (១៩៨៩) រវាងអូស្ត្រាលី និងទីម័រខាងកើត (២០០២)។ ក្រៅពីនេះ នៅមាន **តំបន់នេសាទរួមគ្នា** រវាងចិន និងជប៉ុន (១៩៩៧) រវាងជប៉ុន និងកូរ៉េខាងត្បូង (១៩៩៨) និងរវាងចិន និងកូរ៉េខាងត្បូង (២០០០)។

[83] KONINCK (R. de.), *Op. cit.*, p. 27.

[84] PRESCOTT (V.), *Op. cit.*, p. 11.

[85] ប្រទេសថៃមានផលនេសាទច្រើនក្រាស់ក្រែល ដោយសារមាននាវាបំពាក់ដោយបរិក្ខារនេសាទសមុទ្រល្អៗ ក្នុងនោះមាននាវាសម្រាប់នេសាទនៅតាមដែនទឹកអន្តរជាតិ (KONINCK (R. de.), *Op. cit.*, p. 114)។

យើងសង្កេតឃើញមានការថយចុះយ៉ាងខ្លាំងនូវផលសត្វវន្តជាតិ និងមច្ឆជាតិ[86]។ មូលហេតុចម្បងគឺការធ្វើអាជីវកម្មហួសប្រមាណ ការបំពុល ការដុះសារ៉ាយ[87] និងការថយចុះនូវអុកស៊ីសែន[88]។

ការធ្វើអាជីវកម្មធនធានសមុទ្រប្រកបដោយតុល្យភាព គឺជាបញ្ហាប្រឈមចម្បងសម្រាប់ប្រទេសជាប់ឈូងសមុទ្រថៃទាំងអស់។ ឆ្នេរឈូងសមុទ្រថៃជាញឹកញាប់នៅជាប់នឹងឆ្នេរទឹកសាប និងទឹកប្រៃ ដែលសម្បូរដើមកោងកាង ដែលបង្កើតបានជាតំបន់វណបសម្រាប់ប្រព័ន្ធអេកូឡូស៊ីសមុទ្រ រួមទាំងដើម្បីការពារប្រជាជនពីព្យុះស៊ូណាមិ។ ប៉ុន្តែ ការចិញ្ចឹមបង្គាបានរួមចំណែកបំផ្លាញដើមកោងកាងនៅលើឆ្នេរឈូងសមុទ្រ។

ឆ្នេរឈូងសមុទ្រថៃសម្បូរទៅដោយធនធានធម្មជាតិ។ នៅទីនោះ យើងឃើញមានដីកសិកម្មមានជីជាតិ ជួរផ្កាថ្ម ព្រមទាំងទេសភាព និងឆ្នេរដ៏ស្អាតប្រៀបដូចជាឋានសួគ៌។ ដោយសារសីតុណ្ហភាពក្តៅហើយសើម ឈូងសមុទ្រថៃក៏មានជួរផ្កាថ្មផងដែរ។ ផ្កាថ្មទាំងនេះតំណាងឲ្យប្រព័ន្ធអេកូឡូស៊ីផ្សេងៗខាងផ្នែកជីវសាស្ត្រ ដែលដើរតួនាទីសំខាន់ក្នុងកម្រិតដែលប្រព័ន្ធអេកូឡូស៊ីនេះមានឥទ្ធិពលទៅលើស្តុកមច្ឆជាតិ ទៅលើលក្ខខណ្ឌបរិយាកាស និងទៅលើកម្រិតបំពុល និងសំណឹកមាត់សមុទ្រ។ ជួរផ្កាថ្មទាក់ទាញភ្ញៀវទេសចរមកពីជុំវិញពិភពលោកឲ្យមកហែលមុជទឹកនៅបាតសមុទ្រ។ ប៉ុន្មានឆ្នាំចុងក្រោយនេះ ចំនួនកន្លែងហែលទឹកបានកើនឡើងច្រើន ពិសេសនៅប្រទេសម៉ាឡេស៊ី ថៃ និងវៀតណាម។ ប៉ុន្តែ ជួរផ្កាថ្មក៏រងការបំផ្លាញដោយសារសកម្មភាពមនុស្សកាន់តែច្រើនឡើងដែរ។ ជួរផ្កាថ្មត្រូវបានគេធ្វើអាជីវកម្មហួសប្រមាណ (ជាញឹកញាប់ដោយសារការនេសាទបែបបំផ្លិចបំផ្លាញ ដូចជាការសម្អាតដោយប្រើធាតុស៊ីយ៉ានៀ (Cyanure)) រងការប៉ះពាល់ដោយសារការបំពុល ត្រូវបានបំផ្លិចបំផ្លាញដោយសារវិស័យទេសចរណ៍មានការធ្វេសប្រហែស និងចរាចរណ៍ផ្លូវសមុទ្រ[89]។ ទោះបីជាបរិស្ថាន

---

[86] PIYAKARNCHANA (T.), *Changing state and health of the Gulf of Thailand Large Marine Ecosystem.*In SHERMAN (K.) and TANG (Q.), (eds), *Large Marine Ecosystems of the Pacific Rim – Assessment, Sustainability, and Management,* Blackwell Science, 1999, pp. 240-250.

[87] សារ៉ាយកើតចេញពីកំណើនការប្រើប្រាស់ជីនីត្រាតដោយប្រជាកសិករ។

[88] នៅក្នុងឆ្នាំ១៩៩៦ ឆ្លើយតបទៅនឹង ***សំណើសុំយោបល់ពិគ្រោះស្តីពីភាពស្របច្បាប់នៃការគំរាមកំហែង ឬការប្រើអាវុធបរមាណូ*** តុលាការក៏បានប្រកាសផងដែរថា៖ *«បរិស្ថានមិនមែនជាអរូបិកម្មទេ ប៉ុន្តែជាលំហដែលមនុស្សរស់នៅ និងជាលំហដែលផ្តល់គុណភាពនៃជីវភាព និងសុខភាពរបស់មនុស្ស រួមទាំងសម្រាប់មនុស្សជំនាន់ក្រោយផងដែរ»*។ **កាតព្វកិច្ចទូទៅរបស់រដ្ឋ** ក្នុងការធានាឲ្យបានថា សកម្មភាពដែលបានអនុវត្តក្នុងព្រំដែននៃយុត្តាធិការរបស់ខ្លួន ឬក្រោមការត្រួតពិនិត្យរបស់ខ្លួន គោរពដល់បរិស្ថានក្នុងរដ្ឋផ្សេងទៀត ឬក្នុងតំបន់មិនមែនយុត្តាធិការជាតិនោះ បច្ចុប្បន្នគឺជាផ្នែកមួយនៃវិធាននានានៃ **នីតិបរិស្ថានអន្តរជាតិ**» (C.I.J., *Licéité de la menace ou de l'emploi d'armes nucléaires*, avis consultatif du 8 juillet 1996, *C.I.J. Recueil* 1996, p. 241-242, par. 29)។

[89] សេចក្តីសម្រេចនៃសន្និសីទទីក្រុងហ្សឺណែវឆ្នាំ១៩៥៨ តម្រូវឲ្យរដ្ឋជាប់សមុទ្រសហប្រតិបត្តិការជាមួយអង្គការអភិរក្សអន្តរជាតិទាំងឡាយដែលទទួលខុសត្រូវលើការបង្កើត និងអនុវត្តវិធានការអភិរក្សនៅក្នុងសមុទ្រអន្តរជាតិជាប់គ្នា ដើម្បីអនុម័ត និងឲ្យគេគោរពវិធានការអភិរក្សចាំបាច់ទាំងឡាយក្នុងតំបន់នេសាទក្រោមយុត្តាធិការរបស់ខ្លួន ក្នុងករណីស្តុកត្រីមួយប្រភេទ ឬច្រើនប្រភេទ ឬធនធានជីវសាស្ត្រសមុទ្រផ្សេងទៀតមាននៅក្នុងតំបន់នេសាទស្ថិតក្រោមយុត្តាធិការរបស់ខ្លួន និងនៅក្នុងតំបន់សមុទ្រអន្តរជាតិជាប់គ្នា។ មាត្រា ៦ (១) នៃអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៥៨ ស្តីពីការនេសាទ និងការអភិរក្សជីវធនធាននៃសមុទ្រអន្តរជាតិចែងថា៖ *«រដ្ឋជាប់សមុទ្រត្រូវឲ្យរក្សាជាពិសេសនូវ*

មានផលប៉ះពាល់តិចតួចទៅលើការកំណត់ព្រំដែនក៏ដោយ អនុសញ្ញាក្រុងហ្សឺណែវ ឆ្នាំ១៩៥៨ ស្តីពីជលផលបានចែងអំពីកាតព្វកិច្ចអភិរក្ស [90] ដែលភ្ជាប់ទៅនឹងផលប្រយោជន៍ និងសិទ្ធិរបស់រដ្ឋជាប់សមុទ្រ។ មាត្រា ៥៦.១ ក) នៃអនុសញ្ញាឆ្នាំ១៩៨២ បានផ្តល់ជូនរដ្ឋជាប់ឆ្នេរនូវ«***សិទ្ធិអធិបតេយ្យ*** *ក្នុងការរុករក និងធ្វើអាជីវកម្មអភិរក្សនិងគ្រប់គ្រងធនធានជីវសាស្ត្រ និងមិនមែនជីវសាស្ត្រ...*»។

ឈូងសមុទ្រថៃមានអាងក្រោមដីជាច្រើន ដែលមានរចនាសម្ព័ន្ធសាំញ៉ាំ។ អាងទាំងនេះបង្កើតឡើងដោយរណ្តៅអស៊ីមេទ្រីនានា ដែលពេញប្រៀបដោយល្បប់ស័កទីបី។ នៅក្រោមល្បប់នៃរណ្តៅនោះ មានថ្មកាបោនសមុទ្របឋមស័ក កញ្ចុំថ្មក្រានីត និងល្បប់ក្លាយ។ អាងទាំងនេះជាច្រើនត្រូវបានសម្គាល់ដោយថ្មមេក្រាស់ជាប់ៗគ្នា ដែលអាចមានតេលសិលា។ ប៉ុន្តែការ កំណត់ព្រំដែនខ្សែស្របនៃអាងទាំងនេះ ក៏ដូចជាបម្រែបម្រួលនៃការនាំកម្តៅក្នុងផែនដី និងជម្រៅថ្មមេដែលកប់ក្នុងដីនេះ ធ្វើឲ្យរបាយឧទង្គារ (hydrocarbures) មានភាពសាំញ៉ាំ និងពិបាកព្យាករ[91]។ លទ្ធភាពរុករកនៅមានច្រើន ប៉ុន្តែការព្យាករណ៍ទស្សទាយថានឹងមានការរុករកទ្រង់ទ្រាយតូចជាច្រើន។ ធនធានសំខាន់ៗក្នុងឈូងសមុទ្រថៃរួមមានធនធានផូស៊ីល ដូចជា ប្រេងកាត និងឧស្ម័នធម្មជាតិដែលកប់នៅបាតសមុទ្រ[92]។

យោងតាមការអង្កេតស្ថិតិថាមពល ឆ្នាំ២០១០ របស់ក្រុមហ៊ុនប្រេងកាត British Petroleum ប្រទេសម៉ាឡេស៊ី មានធនធានប្រេងកាតបម្រុងចំនួន ៥,៥២ ពាន់លានធុង នៅចុងឆ្នាំ២០០៩ ស្មើនឹង ០,៤១% នៃធនធានប្រេងកាតបម្រុងពិភពលោក។ ការផលិត ជាពិសេសនៅក្នុងតំបន់សមុទ្រ មានចំនួនស្ទើរតែថេរ ប្រមាណជា ៧៤០.០០០ ធុងក្នុងមួយថ្ងៃ នៅឆ្នាំ២០០៩ ស្មើនឹង ០,៨៦% នៃការផលិតពិភពលោក[93]។ ម៉ាឡេស៊ីជាប្រទេសផលិតប្រេងកាតលំដាប់លេខពីរនៅអាស៊ីអាគ្នេយ៍ បន្ទាប់ពីប្រទេសឥណ្ឌូនេស៊ី។ បច្ចុប្បន្ន ម៉ាឡេស៊ីទាញយកប្រេងកាតប្រមាណជា១០% ពីប្រេងកាតបម្រុងរបស់ខ្លួនក្នុងមួយឆ្នាំៗ។ ដូច្នេះ កម្រិតនៃការផលិតបច្ចុប្បន្នប្រហែលជាមិនរក្សាបានយូរឡើយ។ ការផលិតពាក់កណ្តាលបានមកពីអាង «តាពី» (Tapis) ដែលប្រេងនៅគុណភាពខ្ពស់ប្រើជាផលិតផលយោង នៅលើទីផ្សារតំបន់។ អាស្រ័យដោយមូលហេតុនេះហើយទើបម៉ាឡេស៊ីកំពុងបង្កើនកិច្ចខិតខំប្រឹងប្រែងធ្វើការរុក

ផលិតភាពនៃជីវធនធាននៅក្នុង **លំហសមុទ្រអន្តរជាតិ** ទាំងមូលដែលជាប់គ្នានឹង **សមុទ្រដែនដី** របស់ខ្លួន» (*Les Résolutions adoptées par la Conférence des Nations Unies sur le droit de la mer, le 27 avril 1958* ; *Convention de Genève de 1958 sur la pêche et la conservation des ressources biologiques de la haute mer*, ANC, B-689, ID : 6111)។

[90] យោងតាមនិយមន័យក្នុងអនុសញ្ញាទីក្រុងហ្សឺណែវស្តីពីការនេសាទ ការអភិរក្សបង្កើតឲ្យមាន **ភាតព្វកច្ចផ្នែកមធ្យោបាយ** (ការអនុវត្តវិធានការ) ដើម្បីសម្រេចគោលដៅណាមួយ។

[91] *Petroleum Geology of the Gulf of Thailand.*Greg Croft Inc. Téléchargé le 5 janvier 2011, site http://www.gregcroft.com/thailand.ivnv.

[92] រ៉ែប្រេងកាត និងឧស្ម័នអាចជះឥទ្ធិពលដល់ **ការកំណត់ព្រំដែន**។ នៅក្នុង ***រឿងក្តីសមុទ្រខាងជើង*** *(Affaire de la mer du Nord)* ឯកតាធនធានប្រេង (L'unité des depôts d'hydrocarbures) ត្រូវបានគេចាត់ទុកថាជា «**កាលៈទេសៈសមស្រប**» ក្នុងការកំណត់ព្រំដែនប្រកបដោយសមធម៌។

[93] http://www.mbendi.com/indy/oilg/ogus/as/my/p0005.thm.Téléchargé le 5 février 2011.

រកថ្មីៗ ពិសេសនៅតំបន់សមុទ្រជ្រៅ។ តំបន់សម្បទានមួយកន្លែងទើបតែត្រូវបានផ្តល់ជូនក្រុមហ៊ុន Total នៅឆ្នាំ២០១០ នៅក្នុងតំបន់ទំនាស់ជាមួយប្រទេសប្រ៊ុយណេ។ ម៉ាឡេស៊ីក៏ផលិតឧស្ម័នធម្មជាតិផងដែរ ហើយការផលិតនោះកើនយ៉ាងឆាប់រហ័ស ដោយជាមធ្យម ផលិតបាន ៧៥០.០០០ធុងក្នុងមួយថ្ងៃ។ ម៉ាឡេស៊ីជាប្រទេសផលិតឧស្ម័នធម្មជាតិលំដាប់លេខបីក្នុងពិភពលោក បន្ទាប់ពីឥណ្ឌូនេស៊ី និង អាល់ហ្សេរី[94]។

យោងតាមការអង្កេតស្ថិតិថាមពលឆ្នាំ២០១០ របស់ក្រុមហ៊ុនប្រេងកាត British Petroleum ប្រទេសវៀតណាម មានធនធានប្រេងកាតបម្រុងចំនួន ៤,៥ ពាន់លានធុងនៅចុងឆ្នាំ២០០៩ ស្មើនឹង ០,៣៣% នៃធនធានប្រេងកាតបម្រុងពិភពលោក។ រ៉ែប្រេងកាតទាំងនេះច្រើនមាននៅក្នុងតំបន់សមុទ្រ។ នៅឆ្នាំ២០០៩ ក្នុងមួយថ្ងៃ ការផលិតកើនដល់ ៣៤៥.៣០០ ធុង ស្មើនឹង ០,៤៣% នៃការផលិតក្នុងពិភពលោក[95]។ រ៉ែប្រេងកាតក្នុងតំបន់សមុទ្រទាំងនេះ ដែលរ៉ែធំជាងគេគឺនៅ បាក់ ហូ (Bach Ho) ផលិតបានជាប្រេងកាតគុណភាពខ្ពស់ចេញពីអាងស្តុកក្រានីត។ វៀតណាមបានចាប់ផ្តើមផលិតប្រេងកាតនៅឆ្នាំ១៩៨៩។ ការផលិតមានសន្ទុះខ្លាំងរហូតដល់ឆ្នាំ២០០១ ក្រោយមក សន្ទុះមានភាពប្រក្រតី។ ដែនបម្រុងឧស្ម័នធម្មជាតិរបស់ប្រទេសវៀតណាម ត្រូវបានធ្វើអាជីវកម្មតិចតួចនៅឡើយ។ ក្រុមហ៊ុន Petro Vietnam គឺជាប្រតិបត្តិកររដ្ឋក្នុងវិស័យប្រេងកាត។ ក្រុមហ៊ុន Petro Vietnam បានសាងសង់រោងចក្រចម្រាញ់ប្រេងកាតនៅភូមិភាគកណ្តាលនៃប្រទេសវៀតណាម។

តាមការអង្កេតស្ថិតិថាមពលឆ្នាំ២០១០ របស់ក្រុមហ៊ុន British Petroleum ប្រទេសថៃមានធនធានប្រេងកាតបម្រុង ៤៥៤ លានធុងនៅចុងឆ្នាំ២០០៩។ នៅឆ្នាំ២០០៩ ប្រទេសថៃផលិតប្រេងឆៅបានជាមធ្យម ៣៣០.០០០ ធុងក្នុងមួយថ្ងៃ ស្មើនឹង០,៣៥%នៃការផលិតក្នុងពិភពលោក[96]។ ប៉ុន្តែប្រទេសថៃប្រើប្រាស់ប្រេងកាតអស់ប្រមាណជា ៨១២.០០០ ធុងក្នុងមួយថ្ងៃ យោងតាម BP Stats, 2004។ ប្រទេសថៃក៏ផលិតបានផងដែរនូវឧស្ម័នធម្មជាតិរាវ (GNL) ចំនួន ១៥០.០០០ ធុងសមមូលនឹងប្រេងកាត (bep) ក្នុងមួយថ្ងៃ និងឧស្ម័នធម្មជាតិចំនួន ៣១០.០០០ ធុងសមមូលនឹងប្រេងកាតក្នុងមួយថ្ងៃ ដែលភាគច្រើននៅតំបន់សមុទ្រ នៅក្នុងអាងរ៉ែតូចៗជាច្រើន ដែលអាងរ៉ែមួយចំនួននៅជាប់ជាមួយប្រទេសម៉ាឡេស៊ី។ ដូច្នេះ ដើម្បីបំពេញតម្រូវការរបស់ខ្លួន ថៃត្រូវនាំចូលផលិតផលប្រេងកាតពីខាងក្រៅ។

---

94 http://www.mbendi.com/indy/oilg/ogus/as/my/p0005.thm.Téléchargé le 5 février 2011.
95 *Idem.*
96 *Ibid.*

យោងតាមវិធាននៃនីតិអន្តរជាតិ ការផ្តល់តំបន់សម្បទានប្រេងកាតក្នុងតំបន់សមុទ្រគឺជាកិច្ចគ្រប់គ្រងសកម្មភាពរដ្ឋ ដើម្បីធានាបាននូវ **ការគ្រប់គ្រងជាក់ស្តែង** (Effectivités)[97]នៃតំបន់សមុទ្រមានទំនាស់[98] ។ **ការគ្រប់គ្រងជាក់ស្តែង**ដើរតួនាទីសំខាន់ក្នុងការកំណត់ព្រំដែន[99] ។ អាស្រ័យហេតុនេះ យោងតាម **ការអនុវត្ត** របស់រដ្ឋនានា លំហសមុទ្រមានជម្លោះត្រូវបានបែងចែកជាប្លុកប្រេងកាត ដើម្បីផ្តល់ជូនក្រុមហ៊ុនប្រេងកាត ជាសម្បទានប្រេងកាត។ ប្លុកប្រេងកាតទាំងនេះ[100]ស្ថិតក្រោមបញ្ញតិច្បាប់ប្រេងកាតរបស់រដ្ឋជាប់ឆ្នេរ ដែលជាកិច្ចអធិបតេយ្យនៃនីតិកម្ម លើផ្នែកគតិយុត្តិ ក្នុងគោលបំណងបញ្ជាក់ហេតុផលនៃការទាមទារតំបន់មានជម្លោះពីសំណាក់រដ្ឋ[101]។

សកម្មភាពប្រេងកាត *Upstream*[102] នៅប្រទេសថៃ ត្រូវបានបែងចែកជាអាងប្រេងកាត ដូចជាអាងប៉ាតានី (Pattani) អាងប៉ាតានីខាងត្បូង អាងប៉ាតានីខាងជើង អាងជុំប៉ុន (Chumpon) អាងក្រា (Kra) អាងសុងខ្លា (Songkla) អាងខាងលិច អាងហួរហ៊ីន (Huahin) អាងរ៉ាយ៉ុង (Rayong) និងអាងជាប់ឆ្នេរម៉ែសុត (Mae Sot) និងអាងស្រដៀងគ្នាដទៃៗទៀត[103]។ ក្នុងចំណោមអាងខាងលើ អាងប៉ាតានី ប៉ាតានីខាងត្បូង និងប៉ាតានីខាងជើងគឺជាកន្លែងផលិតប្រេងកាត និងឧស្ម័នធម្មជាតិដ៏ធំ ដោយប្រេងកាតភាគច្រើនត្រូវបានផលិតនៅខាងជើងអាង ហើយឧស្ម័នធម្មជាតិភាគច្រើនត្រូវបានផលិតនៅ

---

[97] **ការគ្រប់គ្រងជាក់ស្តែង** (Effectivités) សំដៅដល់ការគ្រប់គ្រងដោយជាក់ស្តែងដើម្បីអនុវត្តអំណាចអធិបតេយ្យរបស់រដ្ឋលើដែនដីរបស់ខ្លួន។ ប៉ុន្តែ ក្នុងការអនុវត្តជាក់ស្តែង **ការគ្រប់គ្រងជាក់ស្តែង** នេះគឺជាសកម្មភាពនានារបស់រដ្ឋ ជាអាកប្បកិរិយាផ្ទាល់របស់រដ្ឋ ឬស្ថាប័ននានារបស់រដ្ឋ ជាកិច្ចអធិបតេយ្យផ្នែកនីតិកម្ម គ្រប់គ្រង ឬយុត្តិធម៌... (ROS (N.), *Les effectivités,* in INDEMER, *Le processus de délimitation maritime : étude d'un cas fictif, colloque international*, Monaco 27-29 mars 2003, Paris, Pedone, 2004, p. 198)។

[98] ROS (N.), *Op. cit.*, p. 201.

[99] នៅពេលពុំមាន **ប័ណ្ណកម្មសិទ្ធិ** ពិតប្រាកដ **ការគ្រប់គ្រងជាក់ស្តែង** មានតួនាទីគ្របដណ្តប់។ ប៉ុន្តែ ក្នុងករណីផ្ទុយពីនេះ ទម្ងន់នៃ **ការគ្រប់គ្រងជាក់ស្តែង**នោះវាអាស្រ័យទៅលើទំនាក់ទំនងរបស់វាជាមួយនឹង**ប័ណ្ណកម្មសិទ្ធិ** ។ ប្រសិនបើ **ប័ណ្ណកម្មសិទ្ធិ** និង **ការគ្រប់គ្រងជាក់ស្តែង** ដើរផ្ទុយគ្នា នោះ **ការគ្រប់គ្រងជាក់ស្តែង** នឹងមិនយកជាបានការទេ ហើយ **ប័ណ្ណកម្មសិទ្ធិ** ជាកត្តាកំណត់។ ប្រសិនបើ **ប័ណ្ណកម្មសិទ្ធិ** និង **ការគ្រប់គ្រងជាក់ស្តែង** ដើរស្របគ្នា នោះ **ការគ្រប់គ្រងជាក់ស្តែង** មានមុខងារបញ្ជាក់ភាពត្រឹមត្រូវឲ្យ **ប័ណ្ណកម្មសិទ្ធិ** ។ ប្រសិនបើ **ប័ណ្ណកម្មសិទ្ធិ** មានភាពមិនច្បាស់លាស់ **ការគ្រប់គ្រងជាក់ស្តែង** ចូលរួមនៅក្នុងការបកស្រាយ **ប័ណ្ណកម្មសិទ្ធិ** នោះ (ROS (N.), *Op. cit.*, p. 199)។

[100] ក្នុងករណីខ្លះ ប្លុកប្រេងកាតអាចចាត់ទុកជា **កាលៈទេសៈសមស្រប** ក្នុងការកំណត់ព្រំដែនសមុទ្រ។ ក្នុងសំណុំរឿង*ខ្ពង់រាបបាតសមុទ្រលីប៊ី-ទុយណេស៊ី* តុលាការពិនិត្យមើល **ឥរិយាបថ** (Conduite) របស់ភាគីទាំងពីរអំពី **ខ្សែបន្ទាត់ខណ្ឌប្លុកប្រេងកាត** ដែលផ្តល់ដោយលីប៊ី និងទុយណេស៊ី ទោះបីជាជាវាមានលក្ខណៈបណ្តោះអាសន្នក្តី ថាមានលក្ខណៈសមធម៌។ តុលាការបានចាត់ទុក **ខ្សែបន្ទាត់ខណ្ឌប្លុកប្រេងកាត** ទាំងនេះថាជា **កាលៈទេសៈសមហេតុ** ដែលត្រូវយកមកពិចារណាដើម្បីសម្រេចបាននូវការកំណត់ព្រំដែនប្រកបដោយសមធម៌ (C.I.J. *Affaire du Plateau Continental (Tunisie/Jamahiriya Arabe Libyenne)*, arrêt du 24 février 1982, *C.I.J. Recueil* 1982, § 118, p. 84)។

[101] ដើម្បីបង្អាក់ **កច្ចឯកតោភាគ** របស់រដ្ឋ ដែលបានផ្តល់ប្លុកប្រេងកាតជាសម្បទាន រដ្ឋមួយដែលជំទាស់នឹងអធិបតេយ្យភាពរបស់រដ្ឋមួយទៀតក្នុងតំបន់ជម្លោះ ត្រូវចែកតំបន់ជម្លោះជាប្លុកប្រេងកាត និងផ្តល់ប្លុកនោះដល់ក្រុមហ៊ុនប្រេងកាតផ្សេងទៀត។

[102] សកម្មភាពប្រេងកាត *Upstream* សំដៅដល់ការរុករក និងការធ្វើអាជីវកម្មរ៉ែប្រេងកាត។

[103] *Petroleum Geology of the Gulf of Thailand.*Greg Croft Inc. téléchargé le 5 janvier 2011, site http://www.gregcroft.com/thailand.ivnv.

ខាងត្បូង។ ឧទាហរណ៍ អណ្តូង Erawan ដែលក្រុមហ៊ុន Chevron ធ្វើអាជីវកម្ម គឺជាដែនឧស្ម័នដ៏ធំជាងគេ ដែលស្ថិតនៅអាងប៉ាតានី។ ដែនធំជាងគេនៅខាងជើងអាងប៉ាតានី មានដូចជា បែនសាម៉ាស (Benchamas) ដែលត្រូវបានកត់សម្គាល់ដោយសារការផលិតប្រេងកាត និងតាន់តាវ៉ាន់ (Tantawan) ដែលផលិតឧស្ម័នធម្មជាតិ ព្រមទាំងប្រេងកាតមួយចំនួន។ ថ្មីៗនេះ ការផលិតប្រេងកាតរបស់ថៃបានកើនឡើងយ៉ាងច្រើន ដោយសារគេទើបនឹងរកឃើញរ៉ែប្រេងកាតនៅប៉ាកាក្រុង (Pakakrong) នៅម៉ាលីវ៉ាន់ (Maliwan) និងហ្សាមហ្ស៊ុយរ៉េ (Jarmjuree)។ ដែនទាំងនេះត្រូវបានក្រុមហ៊ុនឆេហ្វ្រុនធ្វើអាជីវកម្មផ្តាច់មុខជាមួយក្រុមហ៊ុនថៃប៉ូ (Thaipo)។

សកម្មភាពប្រេងកាត *Upstream* នៅកម្ពុជាត្រូវបានបែងចែកជាបីតំបន់យ៉ាងជាក់លាក់ ដែលក្នុងនោះ បញ្ហាប្រឈមមានភាពខុសគ្នាយ៉ាងខ្លាំងតាមតំបន់នីមួយៗ[104]។ (១) តំបន់គោក (ឬ onshore) ដែលគ្របដណ្តប់ស្ទើរតែទាំងស្រុងលើដែនដីរបស់កម្ពុជា។ (២) តំបន់សមុទ្រ (ឬ offshore) ដែលអធិបតេយ្យភាពពុំមានទំនាស់ និង (៣) តំបន់សមុទ្រមានទំនាស់រវាងខ្មែរ-ថៃ ស្ថិតនៅខាងលិចដែនដីសមុទ្រកម្ពុជា ជាជាតំបន់ត្រួតស៊ីគ្នា (*Overlapping Claim Area* - OCA)។

តំបន់សមុទ្រមួយទៀត ដែលហៅថា **ដែនទឹកប្រវត្តសាស្ត្រ** គឺជាកម្មវត្ថុនៃជម្លោះអធិបតេយ្យភាពរវាងកម្ពុជា និងវៀតណាម[105] ប៉ុន្តែតំបន់នេះទំនងជាមិនបង្កឲ្យមានបញ្ហាប្រឈមខាងប្រេងកាតនោះទេ តែគ្រប់គ្រងដោយកិច្ចព្រមព្រៀងរវាងកម្ពុជា និងវៀតណាម។ ភាគីទាំងពីរមាន ភារកិច្ចក្នុងការកំណត់ព្រំដែននៃតំបន់ទឹកប្រវត្តិសាស្ត្រ នៅក្នុងពេលវេលាមួយសមស្រប។

---

[104] ប្រទេសកម្ពុជាមានប្លុកប្រេងកាតសរុបចំនួន ៣៩ ក្នុងនោះ១៩ប្លុកស្ថិតក្នុងតំបន់គោក និង៦ប្លុកក្នុងតំបន់សមុទ្រពុំមានជម្លោះ (ដើមឡើយតំបន់សមុទ្រមាន៧ប្លុក ប៉ុន្តែ ក្រោយមក គេផ្គុំជា៦ប្លុក) និង៩ប្លុកក្នុងតំបន់សមុទ្រមានជម្លោះ ដែលគេផ្គុំជា៩តំបន់។

[105] កម្ពុជា និងវៀតណាមធ្លាប់មានវិវាទសមុទ្រនឹងគ្នាត្រង់កោះត្រល់ (Phu Quoc)។ នៅឆ្នាំ១៩៣៩ អគ្គទេសាភិបាលឥណ្ឌូចិន លោក **ប្រេវយេ** (Brévié) បានធ្វើការសម្រេចចិត្តផ្នែករដ្ឋបាល ដោយបង្កើត «**ខ្សែបន្ទាត់ប្រេវយេ**» កំណត់ព្រំដែនរដ្ឋបាល ដែលគូសនៅលើផែនទីជលភូមិសាស្ត្រ ដោយកាត់ **កោះត្រល់** ឲ្យវៀតណាម និងកោះ **ពូឡូវ៉ៃ** ឲ្យកម្ពុជា។ ក្រោយពេលទទួលបានឯករាជ្យ ប្រទេសកម្ពុជាបានសើរើគោលការណ៍ **ខ្សែបន្ទាត់មិនកែប្រែ**។ បញ្ហាកោះត្រល់ជាកម្មវត្ថុវិវាទកម្ពុជា-វៀតណាម ក្នុងរយៈពេលជាច្រើនឆ្នាំ ក្រោយពីទទួលបានឯករាជ្យ។ ក៏ប៉ុន្តែ នៅក្នុងឆ្នាំ ១៩៦៤ សម្តេចព្រះ **នរោត្តម សីហនុ** ព្រះប្រមុខរដ្ឋ នាពេលនោះ បានយកផែនទីខ្សែប្រេវីយេឆ្នាំ ១៩៣៩ ទៅតម្កល់នៅអង្គការសហប្រជាជាតិ ហើយស្នើសុំឲ្យអន្តរជាតិ និងប្រទេសសាមីទទួលស្គាល់ថាជាខ្សែព្រំដែនសមុទ្ររវាងតម្ពុជា និង វៀតណាម។ នៅឆ្នាំ១៩៨២ ដើម្បីឈានទៅដល់ការដោះស្រាយដែលអាចទទួលយកបាន កម្ពុជា និងវៀតណាមបានចុះកិច្ចព្រមព្រៀងមួយស្តីពី **ដែនទឹកប្រវត្តសាស្ត្រ**។ កិច្ចព្រមព្រៀងនេះមិនមានបំណងបង្កើតព្រំដែនសមុទ្រជាក់លាក់ និងជាស្ថាពរនោះទេ ប៉ុន្តែដើម្បីកាត់បន្ថយតំបន់ត្រួតគ្នាដែលរដ្ឋទាំងពីរទាមទារ ដោយបង្កើត «**ដែនទឹកប្រវត្តសាស្ត្រ**» ដែលជួយកាត់បន្ថយតំបន់ត្រួតគ្នាបានជាងពាក់កណ្តាល ដោយមានគំនូសជាក់លាក់។ យោងតាមមាត្រា ១ នៃកិច្ចព្រមព្រៀងនេះ កោះ **ពូឡូវ៉ៃ** ជារបស់កម្ពុជា រីឯកោះ **ថូជូ** និង **កោះត្រល់** ជារបស់វៀតណាម។ កិច្ចព្រមព្រៀងឆ្នាំ១៩៨២ ចែងអំពីការចរចាគ្នាឡើងវិញរវាងភាគីទាំងពីរ «នាពេលណាមួយសមស្រប...ក្នុងស្មារតីសមភាព មិត្តភាព គោរពឯករាជ្យភាពគ្នាទៅវិញទៅមក អធិបតេយ្យភាព បូរណភាពដែនដី និងផលប្រយោជន៍ស្របច្បាប់» ដើម្បីកំណត់ព្រំដែនសមុទ្ររវាងប្រទេសទាំងពីរក្នុង **ដែនទឹកប្រវត្តសាស្ត្រ** (មាត្រា ២)។

សកម្មភាពរុករករ៉ែនៅកម្ពុជា មានតាំងពីឆ្នាំ១៩៥០ មកម្ល៉េះ។ ជំនាន់នោះ ក្រុមភូគព្ភវិទូចិនមួយក្រុមបានធ្វើការស្រាវជ្រាវភូគភ្កវិទ្យាដំបូងលើដែនដីកម្ពុជា។ នៅទសវត្សរ៍ទី៦០ ភូគព្ភវិទូប៉ូឡូញបានព្យាយាមគូសផែនទីដែនក្រោមដី។ ចន្លោះពីឆ្នាំ១៩៧២ ដល់ឆ្នាំ១៩៧៤ ក្រុមហ៊ុនបារាំង អែហ្វ (Elf) បានជីកអណ្តូងដំបូងមួយចំនួនក្នុងតំបន់សមុទ្រមានដូចជា B-1, H1 និង L-I។ អណ្តូងទាំងបីមានភាពស្ងួត។ ចុងក្រោយនេះ នៅក្នុងឆ្នាំ១៩៨៧ ភូគព្ភវិទូរុស្ស៊ី និងកម្ពុជាបានធ្វើការសិក្សាភូគព្ភ និងភូមគម្ពរូបសាស្ត្រ។ ការសិក្សានេះបាននាំដល់ការធ្វើចំណាត់ថ្នាក់ដែនដីកម្ពុជាទាំងមូលជាប្លុករុករកប្រេង។

ដំបន់គោកកម្ពុជាចែកជា ១៨ប្លុក បង់លេខពី ៨ ដល់ ២៦។ តំបន់គោកមានការរុករកតិចតួច ប៉ុន្តែនៅជំណាក់កាលនេះ ជាទូទៅ ការស្វែងរុករកប្រេងនៅក្នុងដំបន់គោកទើបតែចាប់ផ្តើមនៅឡើយ។ ដោយមានកិច្ចសហការជាមួយក្រុមហ៊ុនន័រវេស ឈ្មោះប៉េហ្សេអេស (PGS) អាជ្ញាធរជាតិប្រេងកាតកម្ពុជា (ដែលគេស្គាល់ជាភាសាអង់គ្លេសថា CNPA នៃ *Cambodian National Petroleum Authority*) បានធ្វើយុទ្ធនាការរុករកស៊ីស្មិកនៅលើទឹកដីកម្ពុជា លើផ្ទៃដីប្រមាណជា ១.៤០០គម[106] នៅឆ្នាំ២០០៨។ លទ្ធផលបង្ហាញថា តំបន់បឹងទន្លេសាប[107]មានសញ្ញានូវវត្តមាននៃធនធានប្រេងកាត។ ដោយសារដំបន់នេះជាអតីតឈូងសមុទ្រ បឹងទន្លេសាបអាចមានសក្តានុពលធនធានប្រេងកាត និងឧស្ម័នធម្មជាតិមួយចំនួនជាយថាហេតុ។ ក៏ប៉ុន្តែ សណ្ឋានដីនៅតំបន់ជាប្រភេទដីជួរភ្នំ ដូច្នេះផ្ទៃដីខាងក្រោមត្រូវបានចែកជាកង់ៗ ពោលគឺអណ្តូងប្រេងនឹងមានទំហំតូចៗ ដាច់ៗពីគ្នាពិបាកនឹងធ្វើអាជីវកម្ម។ ម្យ៉ាងវិញទៀត ក្រៅពីការលំបាកទាំងឡាយដែលតំបន់នេះមាន នៅមានហានិភ័យផ្នែកបរិស្ថាន និងសង្គមដែលពាក់ព័ន្ធនឹងការរុករកក្នុងប្រព័ន្ធអេកូឡូស៊ី ដែលមានលក្ខណៈពិសេសដូចគ្នាទៅនឹងប្រព័ន្ធអេកូឡូស៊ីនៃទន្លេសាបដែរ។ នាពេលបច្ចុប្បន្ន បឹងដ៏ធំមួយនេះពោរពេញដោយខ្សាច់ និងថ្មស្រទាប់បឹង និងថ្មកំបោទឹកសាបដោយកន្លែង។ ថ្មស្រទាប់បឹងទាំងនេះសម្បូររូបធាតុសរីរាង្គសមល្មម ដើម្បីអាចក្លាយជាថ្មមេប្រេងកាតដ៏ល្អប្រសើរ[108]។

ប្លុក៨ និង៩ ស្ថិតនៅលើអាងល្បប់មួយ ឈ្មោះអាងកំពង់សោម ចំណែកប្លុក១១ និង២៦ ទំនងជាមានសណ្ឋានដីគួរឲ្យចាប់អារម្មណ៍ផងដែរ។ ប៉ុន្តែ នៅឆ្នាំ២០០៧ ប្លុកគោកតែមួយគត់ (ប្លុក១២ដែលមានក្រឡាផ្ទៃ ៥,៧៤០គម²) នៅខាងត្បូងទន្លេសាប ត្រូវបានប្រគល់ឲ្យក្រុមហ៊ុនឥណ្ឌូនេស៊ីឈ្មោះ

---

[106] លទ្ធផលនៃការសិក្សាស៊ីស្មិក 2D (យោងតាមវិធី Advanced weight drop ឬហៅកាត់ថា AWD) ជួយឲ្យប្រទេសកម្ពុជាពង្រីកអាងប្រេងកាតពី ៥ ទៅ៨កន្លែង។

[107] លទ្ធផលនៃការសិក្សាស៊ីស្មិក 2D នេះ បង្ហាញថាអាងប្រេងកាតចំនួនពីរត្រូវបានបង្កើតឡើង ដោយអាងទី១ ជាអាងខាងកើតបឹងទន្លេសាប ស្ថិតនៅក្នុងខេត្តកំពង់ចាម និងកំពង់ធំ (ក្នុងតំបន់ប្រាសាទសំបូរព្រៃគុហ៍) និងព្រះវិហារ រីឯអាងទី២ ជាអាងខាងលិចបឹងទន្លេសាប ស្ថិតនៅក្នុងខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង និងសៀមរាប (ក្នុងតំបន់អង្គរ) (យោងតាមបទសម្ភាសន៍ផ្ទាល់ខ្លួនរបស់អ្នកនិពន្ធជាមួយអតីតនាយកអាជ្ញាធរជាតិប្រេងកាតកម្ពុជា ឈ្មោះលោក **តែ ដួចតារា**) ។

[108] *Petroleum Geology of the Gulf of Thailand.*Greg Croft Inc. téléchargé le 5 janvier 2011, 11:20 heures, site http://www.gregcroft.com/thailand.ivnv.

Medco (ប្រតិបត្តិករគឺ Medco Energi (ឥណ្ឌូនេស៊ី) ៥២,៥% ដៃគូឈ្មោះ CNPA ៤០% JHL (ឥណ្ឌូនេស៊ី) ៧,៥%)។ កិច្ចសន្យាបែងចែកការផលិត (Production sharing contract-PSC) ត្រូវបានចុះហត្ថលេខានៅថ្ងៃទី២៨ កញ្ញា ឆ្នាំ២០០៧។ នៅឆ្នាំ២០០៧ ពុំមានសកម្មភាពណាមួយត្រូវបានអនុវត្តឡើយ ប៉ុន្តែ ក្រុមហ៊ុនភីជីអេស (PGS) បានទទួលទិន្នន័យស៊ីស្មិក 2D នៃផ្ទៃដី ៥០០គម² នៅឆ្នាំ២០០៨។

ដែនដីតំបន់សមុទ្រកម្ពុជាពុំមានទំនាស់ ត្រូវបានចែកចេញជា៦ប្លុក ដែលត្រូវបានកំណត់ដោយអក្សរពី A ដល់ F[109]។ នៅឆ្នាំ១៩៩១ ប្លុកសមុទ្រមួយចំនួនត្រូវបានផ្តល់ឲ្យក្រុមហ៊ុនឈ្មោះ Entreprise Oil ក្រុមហ៊ុន Cambodian Petroleum Exploration (Campex, Japan) និងក្រុមហ៊ុន Premier Oil (ចក្រភពអង់គ្លេស)។ នៅឆ្នាំ១៩៩៧ ប្លុកពីរទៀតត្រូវបានផ្តល់ឲ្យក្រុមហ៊ុន Woodside Energy (អូស្ត្រាលី)។ នៅឆ្នាំ១៩៩៩ ក្រុមហ៊ុន Woodside Energy បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្រាវជ្រាវរួមគ្នាមួយដើម្បីវាយតម្លៃពីលទ្ធភាពរបស់តំបន់សមុទ្រកម្ពុជា។ ប៉ុន្តែ រហូតដល់អំឡុងឆ្នាំ ២០០០ ទើបគេបានទទួលលទ្ធផលមួយចំនួនពីសកម្មភាពនេះ ហើយប្រតិបត្តិការប្រេងកាតក៏ចាប់ផ្តើមមានការរីកចម្រើន។ គ្រប់ប្លុកទាំងអស់ត្រូវបានប្រគល់ឲ្យក្រុមហ៊ុនឯកជន។ ប្លុក A នៃតំបន់សមុទ្រជាប្លុកទីមួយដែលត្រូវបានរាជរដ្ឋាភិបាលផ្តល់ឲ្យក្រុមហ៊ុនប្រេង តាំងពីឆ្នាំ១៩៩៧ មកម្ល៉េះ។ ផ្ទៃក្រឡាដំបូងរបស់ប្លុក គឺមានទំហំ ៦.២៧៨គម²។ ប៉ុន្តែចាប់តាំងពីខែមីនា ឆ្នាំ២០០៧ មក ផ្ទៃក្រឡា ២៥% ត្រូវបានប្រគល់ទៅឲ្យអាជ្ញាធរជាតិប្រេងកាតកម្ពុជាវិញ យោងតាមបញ្ញត្តិដែលមានចែងក្នុងកិច្ចសន្យាបែងចែកការផលិតបន្ទាប់ពីក្រុមហ៊ុនធ្វើការរុករករួចមក ដែលធ្វើឲ្យតួលេខនៅសល់ត្រឹម ៤.៧០៩គម²។ ក្នុងគ្រប់ករណីទាំងអស់ នៅក្នុងដំណាក់កាលអភិវឌ្ឍន៍ដែលជាទូទៅមានរយៈពេលពី៣ទៅ៥ឆ្នាំ ការផលិតប្រេងកាតដែលពីមុនត្រូវបានចាត់ទុកដោយសុទិដ្ឋិនិយមថាអាចចាប់ផ្តើមនៅឆ្នាំ២០០៩នោះ នឹងមិនចាប់ផ្តើមមុនឆ្នាំ២០១៣ ឡើយ។ កិច្ចសន្យាបែងចែកការផលិតត្រូវបានចុះហត្ថលេខារវាងក្រុមហ៊ុន Chevron និង Moeco ជាមួយរាជរដ្ឋាភិបាលកម្ពុជា នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០២ (ប្រតិបត្តិករឈ្មោះ ក្រុមហ៊ុន Chevron ៥៥% ដៃគូមានក្រុមហ៊ុន Moeco ៣០% និងក្រុមហ៊ុន GS Caltex ១៥%)។ នៅឆ្នាំ២០០៤ គេបានរកឃើញតម្រុយប្រេងកាតក្នុងអណ្តូងរុករក ក្នុងវិសម្ពាធភូគព្ភសាស្ត្រ ហៅថាអាងខ្មែរ (ជាភាសាអង់គ្លេសហៅថា Khmer Trough ឬ Khmer Basin)។ ប៉ុន្តែ ក្រុមហ៊ុនអាមេរិកឈ្មោះ Chevron ដែលជា

---

[109] ប្លុក A ត្រូវបានប្រគល់ឲ្យក្រុមហ៊ុន Chevron (សហរដ្ឋអាមេរិក ៣០%) Moeco (ជប៉ុន ៣០%) GS Caltex (សហរដ្ឋអាមេរិក ១៥%) និង Kris Energy (សិង្ហបុរី ២៥%)។ ប្លុក B ត្រូវបានប្រគល់ឲ្យក្រុមហ៊ុន PTTEP (ថៃ ៣៣,៣៥%) SPC (សិង្ហបុរី ៣៣,៣៣%) និង Resourceful Petroleum (ម៉ាឡេស៊ី ៣៣,៣៣%)។ ប្លុក C ត្រូវបានប្រគល់ឲ្យក្រុមហ៊ុន Polytec (ចិន-ហុងកុង ១០០%)។ ប្លុក D ត្រូវបានប្រគល់ឲ្យក្រុមហ៊ុន Mirage Energy (អតីតក្រុមហ៊ុន China Petrotech របស់ចិន-ហុងកុង ១០០%)។ ប្លុក E ត្រូវបានប្រគល់ឲ្យក្រុមហ៊ុន Medco (ឥណ្ឌូនេស៊ី ៦០%) Kuwait Energy (គុយវ៉ែត ៣០%) និង JHL (ឥណ្ឌូនេស៊ី ១០%) និងប្លុក F ត្រូវបានប្រគល់ឲ្យក្រុមហ៊ុន CNOOC Limited (ចិន ១០០%។ ការសិក្សារុករកស៊ីស្មិកត្រូវបានធ្វើឡើងនៅគ្រប់ប្លុកក្នុងសមុទ្រ ទាំងអស់ ប៉ុន្តែ អណ្តូងប្រេងកាតត្រូវបានខួងតែនៅក្នុងប្លុក A និង F ប៉ុណ្ណោះ។

ប្រតិបត្តិកររបស់ប្លុកនោះ មិនដែលធ្វើការវាយតម្លៃជាសាធារណៈណាមួយពីសក្តានុពលនៃធនធានប្រេងនៅក្នុងប្លុកនេះឡើយ។

ប្រតិបត្តិការនៅក្នុងប្លុក A ស្ថិតនៅដំណាក់កាលវាយតម្លៃធនធាន។ អណ្តូងរុករកសរុបចំនួន ១៥ ត្រូវបានខួងចាប់តាំងពីថ្ងៃចុះហត្ថលេខាលើកិច្ចសន្យាបែងចែកការផលិត ក្នុងនោះ អណ្តូងចំនួនប្រាំត្រូវបានខួងនៅក្នុង ឆ្នាំ២០០៤/២០០៥ អណ្តូងចំនួនប្រាំទៀតនៅក្នុងឆ្នាំ២០០៦ និងអណ្តូងចំនួនប្រាំនៅឆ្នាំ២០០៧ បន្ថែមពីលើអណ្តូងដែលត្រូវបានខួងនៅក្នុងឆ្នាំ ១៩៩០។ នៅក្នុងអំឡុងយុទ្ធនាការខួងរុករកប្រេងនៅក្នុងឆ្នាំ ២០០៤/២០០៥ គេបានរកឃើញតម្រុយប្រេងកាតនៅក្នុងអណ្តូងចំនួន ៤ និងតម្រុយឧស្ម័ននៅក្នុងអណ្តូងចំនួន ១។ ប្រេងកាតដែលត្រូវបានយកមកធ្វើការពិសោធន៍នាពេលនោះមានលក្ខណៈគួរឲ្យចាប់អារម្មណ៍ ដូចជា ចំណុះស្ពាន់ធម៌ទាប ហើយមាន API ចំនួន៤៥°។ ក៏ប៉ុន្តែតម្រុយប្រេងកាតដែលយកបាននោះមានអាត្រាអន្ទិលខ្ពស់។ ជាក់ស្តែង តាមការប៉ាន់ស្មានរបស់ក្រុមហ៊ុន គេអាចទាញយកប្រេងពីក្នុងដីបានតែក្នុងកម្រិត ពី១០% ទៅ ២០% តែប៉ុណ្ណោះ។ ថ្មីៗនេះ ក្រុមហ៊ុន Chevron បានប្រកាសថា អាត្រាដែលអាចទាញយកប្រេងមានចំនួន ១៥%។ ប្រេងកាតដែលយកចេញពីអណ្តូងក្នុងប្លុក A មានបរិមាណទាប គឺមិនដល់ ៥០០ លានធុង ដូចត្រូវបានប្រកាសដោយខ្វះការប្រុងប្រយ័ត្ននាពេលកន្លងទៅទេ ព្រោះថាតួលេខជាក់ស្តែងនៃការវាយតម្លៃជាបឋមបានបង្ហាញថា ធនធានប្រេងដែលអាចមាន ស្ថិតនៅចន្លោះពី ៨០ ដល់ ១០០លានធុង។

តំបន់សមុទ្រមានជម្លោះត្រូវបានរាជរដ្ឋាភិបាលកម្ពុជាបែងចែកជាបួនតំបន់ ស្មើនឹង៩ប្លុក។ តំបន់ I និង II ត្រូវបានប្រគល់ទៅឲ្យក្រុមហ៊ុនប្រេងកាតឈ្មោះ Conoco Philips (សហរដ្ឋអាមេរិក) និង Idemitsu (ជប៉ុន) សម្រាប់រយៈពេលមិនកំណត់។ នៅក្នុងឆ្នាំ ២០០៧ ប្លុក III ដែលប្រគល់ទៅឲ្យក្រុមហ៊ុន Shell (៥០%) និងក្រុមហ៊ុន BHP (៥០%) ត្រូវបានប្រគល់ទៅឲ្យក្រុមហ៊ុន Total ចាប់ពីឆ្នាំ២០០៩មក បន្ទាប់ពីរយៈពេលកិច្ចសន្យាបានចប់សុពលភាព។ ប្លុក IV បច្ចុប្បន្ននៅទំនេរនៅឡើយ[110] (សូមមើលផែនទីលេខ២ ក្នុងឧបសម្ព័ន្ធ)។ បើតាមការប្រកាសរបស់ក្រុមហ៊ុនអាមេរិកឈ្មោះ Chevron ដែលទទួលបានសម្បទានប្រេងកាតពីប្រទេសថៃនៅក្នុងតំបន់មានជម្លោះរវាងកម្ពុជា និងថៃឡូងដ៍ រ៉ែប្រេងកាតអាចនឹងមានច្រើនក្នុងតំបន់នេះ។

## គ. ចំណោទបញ្ហានៃវិវាទសមុទ្រខ្មែរ-ថៃ

វិវាទសមុទ្រក្នុងឈូងសមុទ្រថៃកើតឡើងម្យ៉ាងដោយសារកម្ពុជាទាមទារ **ខ្សែបន្ទាត់គោលសមុទ្រ** និងម្យ៉ាងទៀតដោយសារថៃជំទាស់មិនឲ្យកម្ពុជា **ពង្រីកលំហសមុទ្រ** របស់កម្ពុជា។ ទំនាស់នេះកើតចេញពី «*ការខ្វែងគំនិតគ្នាលើផ្នែកអង្គច្បាប់ ឬអង្គហេតុ បដិវាទកម្ម ការប្រឆាំងនឹងនិក្ខេបបទគតិយុត្តិ ឬ*

[110] កិច្ចសន្យាសម្បទានប្រេងកាតដែលប្រគល់ឲ្យក្រុមហ៊ុន BHP (អូស្ត្រាលី) និង Inpex (ជប៉ុន) បានផុតកំណត់ហើយ។

*ផលប្រយោជន៍...»* [111]។ វិវាទនេះត្រូវបានចាត់ទុកជាវិវាទផ្នែកគតិយុត្តិ។ ការអនុវត្តវិធាននៃច្បាប់វិជ្ជមានញែកវិវាទគតិយុត្តិ[112]ពីវិវាទលក្ខណៈនយោបាយ[113]។ ដូច្នេះ វាជាវិវាទមួយដែលភាគីទាំងសងខាងខ្វែងគំនិតគ្នាលើការអនុវត្ត ឬបកស្រាយច្បាប់មានស្រាប់ [114] ។ វិវាទសមុទ្រខ្មែរ-ថៃកើតឡើងព្រោះថាក្នុងវិវាទនេះ «***ការទាមទារ*** *លើអង្គច្បាប់មានការផ្ទុយគ្នា។ ឧទាហរណ៍* ***ការទាមទារ*** *លើអង្គច្បាប់ពីភាគីម្ខាងត្រូវបានជំទាស់ពីភាគីម្ខាងទៀត...»* [115]។ យើងអាចចាត់ទុកវិវាទនេះថា ជាវិវាទខាងផ្នែកគតិយុត្តិ។ ភាពខុសគ្នារវាងវិវាទគតិយុត្តិ ពីវិវាទនយោបាយ គឺថា សម្រាប់វិវាទគតិយុត្តិ គេត្រូវអនុវត្តនូវវិធានច្បាប់។ ដូច្នេះ នេះគឺជាវិវាទ ដែលភាគីទាំងពីរមិនឯកភាពគ្នា ក្នុងការអនុវត្ត ឬក្នុងការបកស្រាយនូវច្បាប់ជាធរមាន។ វិវាទព្រំដែនសមុទ្ររវាងកម្ពុជា និងថៃឡូងដ៍បានលេចចេញជារូបរាងឡើង ដោយសារតែនៅក្នុងវិវាទនេះ «ការទាមទារខាងផ្នែកគតិយុត្តិនៃភាគីពីរបានប៉ះទង្គិចគ្នា ពោលគឺ ការទាមទារដើម្បីទទួលសិទ្ធិដោយភាគីម្ខាង ត្រូវភាគីម្ខាងទៀតជំទាស់តវ៉ា។ វិវាទនេះបង្កើតឲ្យមាន **តំបន់ត្រួតស៊ីគ្នា** នៅក្នុងឈូងសមុទ្រថៃ។ ប៉ុន្តែ រាល់កិច្ចឯកតោភាគីដែលតាមរយៈនេះ ភាគីខ្មែរនិងថៃបានកំណត់ប្រវែងទទឹងនិងបណ្ដោយនៃ **តំបន់អធិបតេយ្យ** និង **តំបន់សិទ្ធិអធិបតេយ្យ**របស់ខ្លួន អាច**ជំទាស់នឹងតតិយជន** (opposable aux tiers) បាន លុះត្រាតែសេចក្ដីសម្រេចរបស់ប្រទេសទាំងពីរអនុលោមតាមវិធាននៃនីតិអន្តរជាតិ។ នេះមានន័យថា ការទាមទាររបស់ប្រទេសទាំងពីរត្រូវបញ្ជាក់មូលហេតុដោយផ្អែកលើមូលដ្ឋានច្បាប់។ ដោយសារពុំមានការជំទាស់លើអធិបតេយ្យភាពរបស់ប្រទេសទាំងពីរលើសមុទ្រក្នុងឈូងសមុទ្រថៃ (ដូចជាទំនាស់ដណ្ដើមកោះ) *វិវាទសមុទ្ររវាងកម្ពុជា-ថៃ គឺជា* ***ចំណោទនៃការកំណត់ព្រំដែនសមុទ្រ***។

ដូច្នេះ ចំណោទបញ្ហានៃវិវាទសមុទ្រខ្មែរ-ថៃចោទជាសំណួរដែលនឹងបកស្រាយជូននៅផ្នែកទី២នៃសារណា អំពីវិធីស្វែងរក***វិធានដែលអនុវត្តនៅក្នុងការកំណត់ព្រំដែនដើម្បីទទួលបានដំណោះស្រាយប្រកបដោយសមធម៌ក្នុងការកំណត់ព្រំដែនសមុទ្រកម្ពុជា-ថៃ*** ព្រោះថាយន្តការដោះស្រាយវិវាទរមែងរាប់បញ្ចូលទាំងផ្នែកការទូត គតិយុត្តិ សេដ្ឋកិច្ច និងភូមិសាស្ត្រនយោបាយទៀតផង។

ការប៉ុនប៉ងផ្នែកទ្រឹស្ដីក្នុងការចងក្រងជាវិធាននៃច្បាប់ ពាក់ព័ន្ធនឹងការកំណត់ព្រំដែនសមុទ្រដែលចាប់ផ្ដើមតាំងពីចុងសតវត្សរ៍ទី១៩ មក បានឈានដល់ការអនុម័តយកវិធានជាអនុសញ្ញា ដែល

---

[111] C.P.J.I., *Affaire des Concessions Mavrommatis en Palestine (Grèce c. Grande-Bretagne)*, *C.P.J.I. Recueil* ---, série A, n°2, p.11 ; voir aussi TCHIKAYA (B.), *Mémento de la jurisprudence : droit international public,* Paris, Hachette, 5e édition, 2010, p. 31.

[112] វិវាទគតិយុត្តិសំដៅដល់ «ការជំទាស់ (...) គ្រប់ប្រភេទ ដែលភាគីជំទាស់គ្នាទៅវិញទៅមកលើអង្គច្បាប់» (formule des conventions d'arbitrage de Locarno du 16 1925), R.T.S.D.N., vol. 54, p. 289 ; SALMON (J.) (dir.), *Dictionnaire de droit international public,* Bruxelles, Buylant, 2001, p. 338).។

[113] ចំពោះការពិនិត្យលក្ខណៈគតិយុត្តិ ឬនយោបាយនៃវិវាទ សូមមើល PAZARTZIS (P.), *Les engagements internationaux en matière de règlement pacifique des différends entre États,* Paris, L.G.D.J., 1992, pp. 36-44.។

[114] SALMON (J.) (dir.), *Dictionnaire de droit international public, Op. cit.*, p. 338.

[115] BASDEVANT (J.) (dir.), *Dictionnaire de la terminologie du droit international public,* Paris, Sirey, 1960, p. 211.

មានលក្ខណៈវិនិច្ឆ័យបីគឺ៖ **ការព្រមព្រៀង** រវាងរដ្ឋពាក់ព័ន្ធ **ខ្សែបន្ទាត់សមចម្ងាយ/កាលៈទេសៈពិសេស** សម្រាប់ការកំណត់ព្រំដែន **សមុទ្រដែនដី** និងគោលការណ៍ **សមធម៌/កាលៈទេសៈសមស្រប** សម្រាប់ការកំណត់ព្រំដែន **ខ្ពង់រាបបាតសមុទ្រ**។ ដូច្នេះ ការកំណត់ព្រំដែនសមុទ្រដែនដីត្រូវតែញែកឲ្យដាច់ពីការកំណត់ព្រំដែនខ្ពង់រាបបាតសមុទ្រ និង **តំបន់នេសាទ** ឬ **តំបន់សេដ្ឋកិច្ចផ្តាច់មុខ** ។ វិធានដែលអនុវត្តនៅក្នុងការកំណត់ព្រំដែនសមុទ្រដែនដីរវាងរដ្ឋពីរដែលមានឆ្នេរជាប់គ្នា មានចែងនៅក្នុងមាត្រាទី ១៥ នៃអនុសញ្ញា **ម៉ុងតេហ្គោ បេយ៍** ។ អនុសញ្ញានេះចែងអំពីការប្រើប្រាស់វិធី **សមចម្ងាយ** លើកលែងតែក្នុងករណីដែល **កម្មសិទ្ធិជាប្រវត្តសាស្ត្រ** ឬ «**កាលៈទេសៈពិសេស**» ពាក់ព័ន្ធនឹងតំបន់ ដែលត្រូវកំណត់ព្រំដែន។ ក្រៅពីសមុទ្រដែនដី ចំពោះការកំណត់ព្រំដែននៃតំបន់ឯទៀត កថាខណ្ឌទី១នៃមាត្រា ៧៤ នៃអនុសញ្ញា **ម៉ុងតេហ្គោ បេយ៍** ចែងថា ការកំណត់ព្រំដែន «*ត្រូវធ្វើឡើងតាមការព្រមព្រៀង អនុលោមតាមនីតិអន្តរជាតិ ដូចមានចែងក្នុងមាត្រា៣៨ នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ ដើម្បីរកបានដំណោះស្រាយប្រកបដោយសមធម៌*»។ បញ្ញត្តិទាំងនេះមានលក្ខណៈពុំជាក់ច្បាស់ និងចោទជាបញ្ហាដល់ការកំណត់ព្រំដែនសមុទ្រ។

ទោះជាយ៉ាងណាក្តី ក្នុងបរិបទនៃការកំណត់ព្រំដែនសមុទ្រ លក្ខណៈភូមិសាស្ត្រគួរកត់សម្គាល់ជាងគេ គឺ **សភាពខូង** នៃឆ្នេរសមុទ្រកម្ពុជាដែលធ្វើឲ្យបាត់បង់ប្រយោជន៍យ៉ាងខ្លាំង ប្រសិនបើការកំណត់ព្រំដែនត្រូវឈរលើមូលដ្ឋាននៃការអនុវត្តវិធី **សមចម្ងាយ**។ វិធីនេះរារាំងកម្ពុជាមិនឲ្យទទួលបាន **ខ្ពង់រាបបាតសមុទ្រ** មួយដ៏ធំ ដែលកម្ពុជាត្រូវទទួលបាន។ ដោយសារមូលហេតុនេះហើយ ទើបការទាមទារដែនសមុទ្ររបស់កម្ពុជា ដែលផ្តើមចេញពីការអនុម័តយក **ខ្សែបន្ទាត់កាត់កែងទៅនឹងសណ្ឋានទូទៅនៃឆ្នេរសមុទ្រ** ជា **ខ្សែព្រំដែនសងខាង** (limite latérale) នៃ **សមុទ្រដែនដី**របស់ខ្លួននោះ បន្ទាប់មកកម្ពុជាបានពង្រឹងការទាមទាររបស់ខ្លួនថែមទៀត តាមរយៈការធ្វើសមុទ្រភាវូបនីយកម្មនៃសន្ធិសញ្ញាព្រំដែន ឆ្នាំ១៩០៧។ ការកំណត់ **ខ្សែបន្ទាត់ព្រំដែនផ្ទៃក្នុង** និង **ខ្សែបន្ទាត់ព្រំដែនខាងក្រៅ** បានប្រព្រឹត្តទៅក្នុងក្របខណ្ឌនៃ **នីតធំនៀមទម្លាប់** និង **នីតសមុទ្រចរដ្ឋមាន**។

ដូច្នេះ ចាំបាច់ត្រូវកំណត់គោលការណ៍ និងវិធានទាំងឡាយនៃនីតិអន្តរជាតិដែលអនុវត្តបាននៅក្នុងការកំណត់ព្រំដែនកម្ពុជា-ថៃក្នុងតំបន់អធិបតេយ្យ (**សមុទ្រដែនដី**) និងនៅក្នុងតំបន់ **សិទ្ធិអធិបតេយ្យ** (**តំបន់សេដ្ឋកិច្ចផ្តាច់មុខ** និង **ខ្ពង់រាបបាតសមុទ្រ**) ដោយពិនិត្យមើលទំនាក់ទំនងរវាង **នីតសមុទ្រចរដ្ឋមាន** និង**នីតធំនៀមទម្លាប់** ពាក់ព័ន្ធនឹងការកំណត់ព្រំដែនសមុទ្រកម្ពុជា-ថៃ។ វិវាទកម្ពុជា-ថៃ អាចដោះស្រាយបានតាមរយៈការកំណត់ព្រំដែនសមុទ្រ ធៀបទៅនឹងយុត្តិសាស្ត្រអន្តរជាតិ ដោយពិនិត្យមើល «**កាលៈទេសៈសមស្រប**» ឬ «**កាលៈទេសៈពិសេស**» ដែលគេអាចលើក

ឡើងដើម្បីទទួលបាន «**លទ្ធផលប្រកបដោយសមធម៌**»[116]។ ទោះជាយ៉ាងណាក្តី **នីតកំណត់ព្រំដែនសមុទ្រ** បានវិវត្តទៅមុខគួរឲ្យកត់សម្គាល់ ចាប់តាំងពីសំណុំរឿងកំណត់ព្រំដែនសមុទ្រទីមួយនៅក្នុងឆ្នាំ១៩៦៩ របស់ **តុលាការយុត្តធម៌អន្តរជាត** មក។ ការវិវត្តនេះត្រូវបានជំរុញដោយសារមតិរិះគន់ផ្នែកទ្រឹស្តីទៅលើយុត្តិសាស្ត្រ ដែលឈានដល់ភាពមិនអាចព្យាករណ៍បាន និងមានភាពអត្តនោមត្តិ។ ដោយមិនពេញចិត្តនឹងមតិរិះគន់ទាំងនេះ **យុត្តាធិការអន្តរជាត** បានអភិវឌ្ឍយុត្តិសាស្ត្ររបស់ខ្លួនឲ្យមានភាពប្រាកដប្រជាជាងមុន។

*ផ្នែកទី១* : វិវាទព្រំដែនសមុទ្ររវាងកម្ពុជា និងថៃឡង់ដ៍។

*ផ្នែកទី២* : ការស្វែងរកដំណោះស្រាយប្រកបដោយសមធម៌ ក្នុងការកំណត់ព្រំដែនសមុទ្ររវាងកម្ពុជា និងថៃឡង់ដ៍។

[116] ពាក់ព័ន្ធនឹងការកំណត់ **ខ្ពង់រាបច្រាតសមុទ្រ** ឬ **តំបន់សេដ្ឋកិច្ចផ្តាច់មុខ** យើងបានលើកឡើងពី «**កាលៈទេសៈសមស្រប**» រីឯនៅក្នុងការកំណត់ព្រំដែន **សមុទ្រដែនដី** ឬ **តំបន់តភ្ជាប់** គេហៅថាជា «**កាលៈទេសៈពិសេស**»។ «**កាលៈទេសៈពិសេស**» មានចែងក្នុងអនុសញ្ញាស្តីពី **សមុទ្រដែនដី** និង **តំបន់តភ្ជាប់** ឆ្នាំ១៩៥៨ ត្រង់មាត្រា ១២ ដែលអនុញ្ញាតឲ្យរដ្ឋធ្វើ **បដិបញ្ញត្ត** លើការអនុវត្តវិធី **សមចម្ងាយ** ក្នុងការកំណត់ព្រំដែន **សមុទ្រដែនដី**។ មាត្រា ១២ នៃអនុសញ្ញា ចែងថា «*បទប្បញ្ញត្តិនៃកថាខ័ណ្ឌនេះមិនយកមកអនុវត្តទេ ក្នុងករណីដែលមាន* ***កម្មសិទ្ធិប្រវត្តសាស្ត្រ*** *ឬ* ***កាលៈទេសៈពិសេស*** *ផ្សេងទៀត ហើយការកំណត់ព្រំដែន* ***សមុទ្រដែនដី*** *របស់រដ្ឋពីរ ត្រូវអនុវត្តតាមវិធានផ្សេងទៀត ដែលមិនមានចែងក្នុងបទប្បញ្ញតិនេះ ឡើយ*»។

# ភាគទី ១
# វិវាទព្រំដែនសមុទ្ររវាងកម្ពុជា និងថៃឡង់ ៖ ជម្លោះនៃការកំណត់ព្រំដែនសមុទ្រ

តើវិវាទព្រំដែនសមុទ្ររវាងកម្ពុជា និងថៃឡង់កើតឡើងដូចម្តេច? សាស្ត្រាចារ្យ **កាឡូ សង់ទូលី** (Carlo SANTULLI) គូសបញ្ជាក់ថា ការកើតឡើងនៃវិវាទបណ្តាលមកពីការប្រសព្វគ្នានៃធាតុផ្សំពីរគឺ **ការទាមទារ** ពីភាគីម្ខាង[117] និង**ការជំទាស់**[118]ពីភាគីម្ខាងទៀត[119]។ ដូច្នេះ ការទាមទារគឺជាចំណុចចាប់ផ្តើមវិវាទមួយ។ ក្នុងបរិបទវិវាទព្រំដែនសមុទ្ររវាងកម្ពុជា និងថៃឡង់ ការទាមទារនេះមានលក្ខណៈដោយប្រយោល ហើយស្តែងចេញតាម**ការពង្រីក**លំហសមុទ្រក្នុងឈូងសមុទ្រថៃ[120]។ ជាការពិតណាស់ មូលដ្ឋានគតិយុត្តិដែលអនុញ្ញាតអោយរដ្ឋទាមទារយកតំបន់សមុទ្រ គឺ **ប័ណ្ណកម្មសិទ្ធិ** (Titre) ដែលជាសន្ធិសញ្ញាព្រំដែន ។ ការវិវត្តនៃប័ណ្ណកម្មសិទ្ធិគតិយុត្តិនេះមានការទាក់ទងទៅនឹង ការវិវត្តទ្រឹស្តីនៃការកំណត់ព្រំដែនសមុទ្រ។ គេឃើញមាន *ទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងដែនដីគោក និង លំហសមុទ្រ (មាតិកាទី១)*។

---

117 **ការទាមទារ** (Prétention) គឺជា «ការអះអាងទាមទារច្បាប់ ឬអង្គហេតុ ឬវិធានច្បាប់មួយ ឬនៃការបកស្រាយវិធានច្បាប់នេះ ដែលអ្នកទាមទារចង់ទទួលបាននូវផលវិបាកមួយចំនួន» (SALMON (J.) (dir.), *Dictionnaire de droit international public, Op. cit.,* p. 873 ; BASDEVANT (J.) (dir.), *Dictionnaire, Op. cit.,* pp. 470-471)។ នៅក្នុងរឿងក្តី *ប្រាសាទព្រះវិហារ* តុលាការបានកំណត់ **ការទាមទារ** ថា៖ «ទាំងប្រទេសកម្ពុជា ទាំងប្រទេសថៃធ្វើការទាមទាររៀងៗខ្លួន ដោយពឹងផ្អែកលើអង្គហេតុនិងការអះអាងដែលត្រូវបានបញ្ជាក់ ឬលើកឡើងដោយភាគីម្ខាង ឬភាគីម្ខាងទៀត។ ជាការពិតណាស់ បន្ទុកនៃភស្តុតាងទាក់ទងនឹងការទាមទារ អាស្រ័យលើភាគីដែលបានអះអាង ឬលើកឡើងក្នុងការទាមទារនេះ»។ (តុលាការយុត្តិធម៌អន្តរជាតិ, សាលដីកាចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២, *Rec.* 1962, ទំព័រទី១៦)។ ក្នុងអត្ថន័យនៃពាក្យនេះ ការអនុម័តព្រះរាជក្រិត្យលេខ៤៣៩-៧២ចុះថ្ងៃទី០១ ខែមករា ឆ្នាំ១៩៧២ដោយប្រទេសកម្ពុជា ដើម្បីគូសព្រំប្រទល់ខ្ពង់រាបបាតសមុទ្ររបស់ខ្លួនអាចចាត់ទុកថាជាការទាមទារដែនសមុទ្រក្នុងឈូងសមុទ្រថៃពីសំណាក់កម្ពុជា។ ដូច្នេះ ការទាមទារនេះចាត់ទុកថាជាការទាមទារដោយប្រយោល (Prétention implicite)។

118 គេបានអោយនិយមន័យនៃ **ការជំទាស់** ថាជា «ការខ្វែងគំនិតគ្នា ឬវិវាទដែលអាចកើតចេញពីការប្រកែកច្រានចោលមួយ (Dénégation)» (SALMON (J.) (dir.), *Dictionnaire, Op. cit.,* p. 249)។ តុលាការកត់សំគាល់ឃើញថា ៖«**ការជំទាស់** តវ៉ាទាមទារអោយមានការខ្វែងមតិគ្នារវាងគូភាគីនៅត្រង់ចំនុចជាក់លាក់នានា» (តុលាការយុត្តិធម៌អន្តរជាតិ, *សំណើសុំបកស្រាយសាលដីកាចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៥០ នៅក្នុងរឿងក្តីសិទ្ធិជ្រកកោន* សាលដីកាចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៥០, *Rec.*, 1950, ទំព័រទី៤០៣)។

119 SANTULLI (C.), « Droit du contentieux international », Paris, Montchrestien, 2005, p. 5.

120 ចំពោះសេចក្តីលំអិតនៃ **ការពង្រីក** (Extension) នេះ សូមមើល NORODOM RANARIDDH, *Les limites du domaine maritime du Cambodge*, Thèse pour le doctorat d'État en droit, Université de droit, d'économie et des sciences d'Aix-Marseille, juin 1976, pp. 453 ; et KHIM (Y.), *Le Cambodge et le problème de l'extension des espaces maritimes dans le golf de Thaïlande*, Thèse pour le doctorat d'État en droit, Paris II, 1978, pp. 763។

ដើម្បីពិនិត្យមើលវិវាទព្រំដែនសមុទ្ររវាងកម្ពុជា និងថៃឡុងដ៍ យើងត្រូវវិភាគ**ការជំទាស់**របស់ថៃចំពោះការពង្រីកដែនសមុទ្រដោយភាគីកម្ពុជាក្នុងឈូងសមុទ្រថៃ។ ជាក់ស្តែង ប្រទេសថៃជំទាស់នឹងសកម្មភាពរបស់កម្ពុជា និងជាពិសេសការអនុម័តច្បាប់ជាតិ ដែលរួមបញ្ចូលលំហមានទំនាស់ខាងលើទៅក្នុង **តំបន់អធិបតេយ្យ** (Zone de souveraineté) ឬ **តំបន់សិទ្ធិអធិបតេយ្យ** (Zone de droits souverains) របស់ខ្លួន។ យ៉ាងណាក្តី ដូចការលើកឡើងរបស់លោកសាស្ត្រាចារ្យ **វីរ៉ាល់លី** (VIRALLY) ដើម្បីអោយការជំទាស់របស់រដ្ឋមួយអាចប្រឆាំងនឹងតតីយជនដែលមិនអាចជំទាស់នឹងសកម្មភាពនេះបាន ការជំទាស់ទាំងនោះត្រូវគោរពយ៉ាងច្បាស់ទៅតាមវិធានច្បាប់អន្តរជាតិទូទៅ[121]។ ដូច្នេះ ការពិនិត្យលើការជំទាស់របស់ភាគីថៃចំពោះការពង្រីកដែនសមុទ្រដោយកម្ពុជា គឺចាំបាច់ដើម្បីពិនិត្យមើល*វិវាទក្នុងការកំណត់ព្រំដែនសមុទ្រ* រវាងរដ្ឋទាំងពីរ (មាតិកាទី២)។

យោងតាមអនុសញ្ញា CMB រដ្ឋជាប់ឆ្នេរទាំងអស់មានសិទ្ធិទទួលបានខ្ពង់រាបបាតសមុទ្រ ដែលមានចម្ងាយកំណត់ត្រឹម២០០ម៉ាលយ៍សមុទ្រ ក្នុងខណៈពេលដែលប្រវែងទទឹងឈូងសមុទ្រថៃមានប្រវែងពុំលើស៤០០ម៉ាលយ៍សមុទ្រទេ។ ក្នុងខណៈដែលប្រទេសពីរ កម្ពុជា និងថៃ អនុវត្តសិទ្ធិរបស់ខ្លួនលើដែនសមុទ្រ «*ការត្រួតស៊ីគ្នាមួយរវាងប័ណ្ណកម្មសិទ្ធិពីរប្រឆាំងគ្នា*»[122] អាចកើតចេញពីទំនាក់ទំនងជាប្រទេសជិតខាងបាន។ អាស្រ័យហេតុនេះ ការពង្រីកលំហសមុទ្រដោយឯកតោភាគីរបស់ពួកគេចៀសពុំផុតពីបង្កើតអោយមានត្រួតស៊ីគ្នាឡើយ។ ហើយភាពត្រួតស៊ីគ្នានៃប័ណ្ណកម្មសិទ្ធិអធិបតេយ្យ (Titre de souveraineté) នេះហើយដែលជាដើមចមនៃវិវាទដែនសមុទ្ររវាងកម្ពុជា និងថៃ។ ការសិក្សាពីតំបន់សមុទ្រត្រួតស៊ីគ្នារវាងកម្ពុជា និងថៃគឺជាការលក្ខខណ្ឌចាំបាច់ដំបូងដើម្បីឈានទៅដល់ដំណោះស្រាយនៃវិវាទព្រំដែនសមុទ្ររវាងកម្ពុជា និងថៃឡុងដ៍ (ដែលយើងនឹងពិនិត្យនៅក្នុងផ្នែកទី២នៃសារណានេះ) (*មាតិកាទី៣*)។

---

121 VIRALLY (M.), « Panorama du droit international contemporain », *RCADI*, 1983, V. t. 183, p. 157.
122 LUCCHINI (L.) et VŒLCKEL (M.), *Droit de la mer, tome 2, vol. 1, Délimitation, Op. cit.*,p. 14.

# មាតិកាទី១

# ព្រំដែនកម្ពុជា ៖ ទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាង ដែនដីគោក និងលំហសមុទ្រ

នីតិសមុទ្រកម្ពុជាបានបញ្ជាក់ឡើងវិញពីឆន្ទៈកម្ពុជាក្នុងការប្រើប្រាស់ធនធានទឹក និងធនធានបាតសមុទ្ររបស់ខ្លួន និងធានាសន្តិសុខសមុទ្រអោយបានល្អប្រសើរ។ នីតិនេះមានប្រភពពីនីតិបារាំងដែលអនុវត្តនៅឥណ្ឌូចិន ក្នុងអំឡុងពេលអាណាព្យាបាលបារាំង។ បន្ទាប់ពីបានទទួលឯករាជ្យនាឆ្នាំ ១៩៥៣ ប្រទេសកម្ពុជាបានចាប់ផ្តើមដំណើរការពង្រីកលំហសមុទ្ររបស់ខ្លួន។ លំហសមុទ្រទាំងនេះត្រូវចាត់ទុកថាជា *«ផ្នែកមួយនៃដែនដីគោក»*[123] យោងតាមរូបមន្ត *«ដីគោកគ្របដណ្តប់លើសមុទ្រ»*[124]។ ដូច្នេះ ដែនដីគោកផ្តល់ឱ្យកម្ពុជានូវ *«ប័ណ្ណកម្មសិទ្ធិលើលំហសមុទ្រច្បាស់លាស់មួយ»*[125]។ ចំណងគតិយុត្តិរវាងដែនដីគោក និងលំហសមុទ្រត្រូវបានអះអាងបញ្ជាក់ដោយតុលាការយុត្តិធម៌អន្តរជាតិ ៖ *«គឺដីគោកដែលផ្តល់អោយរដ្ឋជាប់សមុទ្រនូវសិទ្ធិទៅលើដែនទឹកដែលនៅជាប់ឆ្នេររបស់រដ្ឋនោះ»*[126]។ ដូច្នេះ ហេតុផលនៃចំណងគតិយុត្តិដ៏ជិតស្និទ្ធរវាងដែនដីគោក និងលំហសមុទ្រទាំងអស់នេះទាមទារអោយមានការពិនិត្យមើលជាមុន ទៅលើ*អនុសញ្ញាព្រំដែនគោករវាងកម្ពុជា និងថៃឡង់ (ជំពូក១)* មុននឹងពិនិត្យមើលដំណើរការពង្រីកលំហសមុទ្រ រួមទាំងព្រំដែននៃដែនសមុទ្រកម្ពុជា (ជំពូក២)។

## ជំពូកទី ១

## អនុសញ្ញាព្រំដែនគោករវាងកម្ពុជា និងថៃឡង់

**ព្រំដែន** គឺជាសញ្ញាសម្គាល់ព្រំប្រទល់នៃដែនដី។ នៅក្នុងបរិវេណព្រំប្រទល់នេះ រដ្ឋមួយត្រូវបានអនុញ្ញាតអោយអនុវត្តនូវរាល់សកម្មភាពដែលជាសមត្ថកិច្ចរបស់ខ្លួន។ ព្រំដែនមានតួនាទីនយោបាយក្នុងការរក្សាស្ថិរភាពរបស់ប្រជាជាតិមួយ និងការបំលែងខ្លួនទៅជា **រដ្ឋ**[127]។ ប៉ុន្តែ អំឡុង

---

[123] (*L'accessoire du territoire terrestre*) នៅក្នុងរឿងក្តី Grisbardana *រវាងប្រទេសស៊ុយអែត និងន័រវេ* តុលាការមជ្ឈត្តការអចិន្ត្រៃយ៍ (Cour Permanent d'Arbitrage) បានប្រកាសនៅក្នុងសាលក្រមចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩០៩ ថា៖ «the maritime territory is an essential appartenance of land territory». Cité par LUCCHINI (L.) et VOELCKEL (M.), *Droit de la mer*, tome II, *Op. cit.*, p. 36»។

[124] (*La terre domine la mer*). CIJ, Rec. 1969, §96, p. 51.

[125] LUCCHINI (L.) et VOELCKEL (M.), *Droit de la mer, tome 2, vol. 1, Op. cit.*, p. 13.

[126] CIJ, *Affaire des Pêcheries anglo-norvégiennes.* Rec. 1951, p. 133.

[127] BLUMANN (C.), « Frontières et limites », in SOCIÉTÉ FRANÇAISE POUR LE DROIT INTERNATIONAL, *La frontière,* Colloque de Poitiers, Paris, Pedone, 1980, p. 4.

ពេលអាណានិគម ព្រំដែនជាក់លាក់បានដើរតួនាទីសំខាន់មួយទៀត គឺប្រើសម្រាប់សម្គាល់ដែនកំណត់តំបន់ឥទ្ធិពល ការបែងចែកអាណានិគម និងសម្រាប់ទប់ទល់នឹងការរុលទៅមុខរបស់គូបដិបក្ស[128]។ នយោបាយវាតទីនិយមនេះបានបង្កើតជាមនោគមវិជ្ជានៃលំហ **ព្រំដែនធម្មជាត** ដែលសំខាន់សម្រាប់អាយុជីវិត។ គេពុំស្វែងរកត្រឹមតែស្ថិរភាពព្រំដែនប៉ុណ្ណោះទេ គេថែមទាំងស្វែងរកសមតាផ្នែកកម្លាំង ហើយសមតាផ្នែកកម្លាំងនេះជាគ្រឹះនៃសណ្តាប់ធ្នាប់ពិភពលោកក្នុងសតវត្សន៍ទី១៩។ មូលហេតុនេះហើយទើប *«ការដណ្តើមយកដែនដីមកធ្វើជាកម្មសិទ្ធិរបស់ប្រទេសមួយ ត្រូវបានដាក់ជាបណ្តើរៗឲ្យឋិតនៅក្រោមវិធាននៃច្បាប់...»* [129]។ សន្ធិសញ្ញាព្រំដែនត្រូវបានប្រើប្រាស់ជាបណ្ណកម្មសិទ្ធិគតិយុត្តិយ៉ាងសំខាន់ ជាសន្ធិសញ្ញាអនុប្បទាន (Traité de cession) ដែលជាវិធីបុរាណក្នុងការទទួលបាននូវអធិបតេយ្យភាពដែនដី។ ជាក់ស្តែង ការការពារផលប្រយោជន៍របស់ «មហាអំណាចអ្នកគាំពារ» ពោលគឺប្រទេសបារាំង និងរបស់ «ប្រទេសទទួលការគាំពារ» ពោលគឺប្រទេសកម្ពុជា ត្រូវបានធ្វើឱ្យសម្រេចតាមរយៈការរៀបចំឲ្យមាន **អនុសញ្ញាព្រំដែន** (*ផ្នែកទី១*)។

## ខណ្ឌទី១
## អាណាព្យាបាលបារាំង និងសន្ធិសញ្ញាព្រំដែន
## ដែលជាមូលដ្ឋានព្រំដែនគោកកម្ពុជា

គំនូសព្រំដែនគោកតែងតែត្រូវបានកំណត់នៅក្នុងបទបញ្ញត្តិនានានៃអនុសញ្ញា ក្រោមទម្រង់ជាសន្ធិសញ្ញាព្រំដែន ដែលត្រូវបានចរចាររវាងរដ្ឋអធិបតេយ្យ។ ព្រំដែនរវាងកម្ពុជា និងថៃឡង់ត្រូវបានបង្កើតឡើងដោយផ្អែកលើការពិចារណាខាងផ្នែកភូមិសាស្រ្ត [130] ប្រវត្តិសាស្រ្ត សេដ្ឋកិច្ច [131] និងយុទ្ធសាស្រ្ត ដែលប្រការនេះអាចបង្កើតឱ្យមានសមតានៃផលប្រយោជន៍ដែលប្រទាញប្រទង់គ្នា[132]។ ទោះជាយ៉ាងនេះក្តី តើឈរលើមូលដ្ឋានគតិយុត្តិអ្វី ដែលប្រទេសបារាំងដើរតួនាទីក្នុងនាមប្រទេសកម្ពុជា ដើម្បីទាមទារដីឲ្យកម្ពុជាវិញនោះ? អនុសញ្ញាអាណាព្យាបាល និងសន្ធិសញ្ញាបន្តបន្ទាប់ស្តីពីការផ្ទេរសមត្ថកិច្ចរដ្ឋរបស់ប្រទេសដែលទទួលការគាំពារ (កម្ពុជា) ទៅអោយមហាអំណាចអ្នកគាំពារ (បារាំង) តម្រូវអោយមានការពិនិត្យយ៉ាងល្អិតល្អន់ដើម្បីធានាអំពីសុពលភាពនៃសន្ធិសញ្ញាព្រំដែន (*§1*)។

---

128 DUTHEIL de La ROCHÈRE (J.), « Les procédures de règlement des différends frontaliers », in in SOCIÉTÉ FRANÇAISE POUR LE DROIT INTERNATIONAL, *La frontière, Ibid.*, p. 135.
129 DEVISSCHER (C. de), *Les effectivités du droit international public,* Pedone, Paris, 1967, p. 102.
130 បំណងប្រាថ្នារបស់បារាំងគឺចង់មាន **ព្រំដែនធម្មជាត**។
131 ការស្វែងរកផ្លូវទៅកាន់សមុទ្រដើម្បីសម្រួលដល់ពាណិជ្ជកម្មក្នុងតំបន់ និងអន្តរជាតិ។
132 ការដណ្តើមគ្នារវាងប្រទេសបារាំង និងចក្រភពអង់គ្លេស។

ក្នុងសម័យអាណានិគម ព្រំដែនជាក់លាក់គឺជាមធ្យោបាយបែងចែកតំបន់ឥទ្ធិពល និងដើម្បីទប់ទល់នឹងគូបដិបក្ខរបស់ខ្លួន។ ដូច្នេះ សមតាផ្នែកកម្លាំងដើរតួនាទីដ៏មានឧត្តមានុភាពនៅក្នុងការបង្កើតព្រំដែន។ ដោយហេតុនេះហើយទើបព្រំដែនតែងតែត្រូវបានផ្លាស់ប្តូរ ហើយគំនូសព្រំដែនតែងតែត្រូវបានកំណត់ដោយសន្ធិសញ្ញាព្រំដែនជាច្រើន ពោលគឺមិនមែនសន្ធិសញ្ញាតែមួយនោះទេ។ ដូច្នេះ បញ្ហាគតិយុត្តិបានចោទឡើងនៅក្នុងដំណាក់កាលបន្តបន្ទាប់នៃការកំណត់ព្រំដែនអាណានិគម ដែលក្នុងនោះមានការចុះសន្ធិសញ្ញាព្រំដែន ការកំណត់ព្រំដែនដោយគណៈកម្មការចម្រុះកិច្ចការព្រំដែន ការខ្សែបន្ទាត់ខណ្ឌសីមានៅលើដីជាក់ស្តែង(Démarcation) ក្នុងគោលបំណងទទួលបានព្រំដែនដែលមានស្ថេរភាព និងស្ថាពរ[133] ទាំងសម្រាប់ដែនដីគោក និងលំហសមុទ្រ(*§2*)។

## §១. សន្ធិសញ្ញាអាណាព្យាបាលបារាំង-កម្ពុជា

សន្ធិសញ្ញាអាណាព្យាបាលបារាំង-កម្ពុជាចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៦៣ គឺជាសន្ធិសញ្ញាដំបូងបង្អស់នៃនីតិអន្តរជាតិទំនើបដែលប្រទេសកម្ពុជាបានចុះហត្ថលេខាជាមួយមហាអំណាចបស្ចឹមប្រទេស គឺប្រទេសបារាំង។ សន្ធិសញ្ញានេះត្រូវបានផ្តល់សច្ចាប័ន និងអនុម័តដោយការឡើងគ្រងរាជរបស់ព្រះបាទ **នរោត្តម** នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៨៦៤។ អាណាព្យាបាលនេះអនុញ្ញាតអោយប្រទេសបារាំងមកឈរជើងនៅប្រទេសកម្ពុជា ដើម្បីឡើងបន្តទៅកាន់ប្រទេសចិនតាមទន្លេមេគង្គ។ លោកសាស្ត្រាចារ្យ **ភឹង តុង** បានកត់សម្គាល់ថា ៖ ប្រទេសបារាំងដែល *«ទំនងជាបារម្ភនឹងការវិវត្តផ្នែកពាណិជ្ជកម្មរបស់អង់គ្លេស បានសម្រេចធ្វើសន្ធិសញ្ញាជាមួយប្រទេសទាំងឡាយណាដែលនៅពេលនោះមិនទាន់ឋិតនៅក្រោមឥទ្ធិពលរបស់ខ្លួននៅឡើយ»* [134] ។ សន្ធិសញ្ញានេះអនុញ្ញាតអោយប្រទេសកម្ពុជារួចផុតពីការត្រួតត្រា (Suzeraineté) ត្រួតត្អារបស់សៀម និងវៀតណាម។ អនុលោមតាមសន្ធិសញ្ញានេះ បារាំងសន្យាការពារកម្ពុជាពីចលាចលផ្ទៃក្នុង និងការវាយប្រហារពីខាងក្រៅ (មាត្រា១ និង១៦)។ ដូច្នេះ ការភ័យខ្លាចរបស់ព្រះបាទ **អង្គឌួង** ដែលថានៅថ្ងៃណាមួយនាពេលអនាគត ប្រទេសកម្ពុជានឹងត្រូវលប់បាត់ចេញពីផែនទីនោះ លែងមានទៀតហើយ។

អនុលោមតាមសន្ធិសញ្ញាឆ្នាំ ១៨៦៣ នេះ បារាំងបានដើរតួរជាអ្នកស្នងអធិរាជអាណាម ហើយ *«អធិរាជរបស់ជនជាតិបារាំងព្រមផ្តល់ការគាំពារដល់ព្រះមហាក្សត្រកម្ពុជា»*។ បារាំង *«យល់ព្រមប្រែក្លាយទៅជាអាណាព្យាបាលដើម្បីការពារសិទ្ធិក្នុងការត្រួតត្រា* (Droits de Suzeraineté)» ដែលខ្លួនទទួលបានក្រោយស្នងបន្តនៅក្នុង បណ្តាខេត្តកូសាំងស៊ីនពីអធិរាជអាណាម ដែលក្សត្រកម្ពុជាធ្លាប់បង់

[133] តុលាការយុត្តិធម៌អន្តរជាតិគូសបញ្ជាក់ថា៖ «នៅពេលប្រទេសពីរកំណត់រួមគ្នានូវព្រំដែនមួយ គោលដៅមួយក្នុងចំណោមគោលដៅឯទៀត គឺការទទួលបាននូវដំណោះស្រាយឲ្យមាន **ព្រំដែនដែលមានស្ថេរភាព និងស្ថាពរ**» (CIJ Rec. 1962, pp. 26-37)។

[134] PHUNG TON, *La crise cambodgienne.* Thèse de Doctorat de droit, dir. Ch. ROUSSEAU, Université de Paris, Faculté de droit, 1954, 110 p.

ស្ទួយសារអាករជូនតាំងពីឆ្នាំ ១៨០៧ មក។ បារាំងមានអ្នកតំណាងម្នាក់នៅអមព្រះមហាក្សត្រកម្ពុជា ដែលជារ៉េស៊ីដង់ជាតិបារាំង ដែលដាក់ *«ឲ្យនៅក្រោមសមត្ថកិច្ចជាន់ខ្ពស់របស់ទេសាភិបាលកូសាំងស៊ីន»* (មាត្រា២)។ តាមទស្សនៈគតិយុត្តិ គេអាចកត់សំគាល់បានថា ចាប់ពីមានសន្ធិសញ្ញាឆ្នាំ ១៨៦៣ និងសន្ធិសញ្ញាផ្សេងៗបន្តបន្ទាប់មក ទឹកដីកូសាំងស៊ីនបានត្រូវគេចាត់ទុកជាអាណានិគមបារាំង រីឯ កម្ពុជា អាណាម និង តុងកឹងបិតក្រោមរបបអាណាព្យាបាល។ បណ្ឌិត **សារិន ឆាក** បានកត់សម្គាល់ថា « *ទំនាស់ផលប្រយោជន៍ និងភាពខុសគ្នានៃលក្ខន្តិកៈមានឥទ្ធិពលយ៉ាងអាក្រក់ក្រៃលែងដល់ប្រទេសទទួលការគាំពារ គឺ កម្ពុជា»* [135] ។ ការដាក់តំណាងអាណាព្យាបាលឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភូឈួយទេសាភិបាលអាណានិគម គឺអនុញ្ញាតឱ្យអោយទេសាភិបាលនោះក្លាយជាភាគីផង និងចៅក្រមផង[136] ក្នុងពេលតែមួយ។

ទាក់ទងនឹងទំនាក់ទំនងក្រៅប្រទេស សាស្ត្រាចារ្យ **ហ្គួរ** (GOUR) បានគូសបញ្ជាក់ថាសន្ធិសញ្ញាចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ *«កម្រិតត្រឹមការផ្ទេរទៅឲ្យបារាំងនូវការអនុវត្តសមត្ថកិច្ចអន្តរជាតិរបស់កម្ពុជាតែប៉ុណ្ណោះ និងរក្សានូវស្វ័យភាពផ្ទៃក្នុងទាំងមូលជូនព្រះរាជាណាចក្រកម្ពុជា »*[137]។ សាស្ត្រាចារ្យ GOUR បានបន្ថែមទៀតថា *«អាណាព្យាបាលគឺជាលក្ខន្តិកៈមួយនៃនីតិអន្តរជាតិ ព្រោះវាផ្អែកលើសន្ធិសញ្ញា»*[138]។ មាត្រា៤នៃសន្ធិសញ្ញា បានចែងថា *«គ្មានកុងស៊ុលបរទេសណាម្នាក់ ក្រៅពីកុងស៊ុលរបស់បារាំងអាចត្រូវបានទទួលដោយព្រះមហាក្សត្រ ដោយពុំមានការយល់ព្រមពីទេសាភិបាលកូសាំងស៊ីនឡើយ»*។ សាស្ត្រាចារ្យ **ពីនតូ** (PINTO) កត់សម្គាល់ថា *«សមត្ថកិច្ចមានកម្រិតទាំងនេះត្រូវបានអនុវត្តទៅតាមច្បាប់ និងទៅតាមប្រព្រឹត្តកម្ម ដោយអាជ្ញាធរនៃអាណាព្យាបាល នៅក្រោមការត្រួតពិនិត្យរបស់អគ្គទេសាភិបាល»* [139]។ ឧត្តមនាវីឯក **គ្រង់ឌីយែរ** (GRANDIÈRE) បានសម្រេចចិត្តលើកយកបញ្ហាព្រំដែនមកដោះស្រាយ ហើយនៅក្នុងឆ្នាំ ១៨៦៣ បានចាត់តាំងតំណាងអាណាព្យាបាលឈ្មោះ **ឌូដា ឌឺ ឡាគ្រេ** (DOUDART DE LAGRÉE) អោយយកចិត្តទុកដាក់សិក្សាទៅលើការកំណត់ព្រំដែនរវាងកូសាំងស៊ីន និងកម្ពុជា[140]។

ក៏ប៉ុន្តែ បារាំងយឺតយ៉ាវក្នុងការផ្តល់សច្ចាប័នដល់សន្ធិសញ្ញាអាណាព្យាបាលបារាំង-កម្ពុជាឆ្នាំ ១៨៦៣។ ប្រទេសសៀមក៏បានឆ្លៀតឱកាសនេះបង្ខំអោយព្រះមហាក្សត្រកម្ពុជា ចុះសន្ធិសញ្ញាសម្ងាត់មួយដែលអះអាងបញ្ជាក់ពីអធិបតេយ្យភាពរបស់សៀមលើប្រទេសកម្ពុជា ហើយបានគំរាមទ្រង់ថានឹង

---

[135] SARIN CHHAK, *Les frontières du Cambodge, T.1: Les frontières du Cambodge avec les anciens pays de la Fédération indochinoise, le Laos et le Vietnam (Cochinchine et Annam),* Paris, 1966, p.14.
[136] SARIN CHHAK, *Ibid.*
[137] GOUR (C-G.), *Institutions Constitutionnelles et Politiques du Cambodge.* Paris, Dalloz, 1965, p. 28.
[138] *Ibid.* p. 32-33.
[139] PINTO, *Aspect de l'évolution gouvernementale de l'Indochine Française,* Paris, 1946 ; cité par le Professeur GOUR, *Ibid.,* p. 33.
[140] LAMANT (P.-L.), « La frontière entre le Cambodge et le Vietnam du milieu du XIX^e siècle à nos jours », in LAFONT (P.B.), (dir.), *Les frontière du Vietnam, Ibid.,* p. 161.

ធ្វើការសងសឹកយ៉ាងខ្លាំងក្លា ប្រសិនទ្រង់បដិសេធពុំព្រមចុះហត្ថលេខា[141]។ ទោះយ៉ាងនេះក្តី **អាឡាំង ហ្វ័ររ៉េស** (ALAIN FOREST) បានបកស្រាយសន្ធិសញ្ញាសម្ងាត់នេះថា ជាឆន្ទៈរបស់ព្រះបាទ **នរោត្តម** ក្នុងការដឹកនាំនយោបាយរកតុល្យភាពរវាងបារាំង និងសៀម [142] ។ យោងតាមខ្លឹមសារសន្ធិសញ្ញាសម្ងាត់នេះ សៀមទទួលបន្ទុកបង្ក្រាបចលនាបះបោរ ស្តារស្ថានភាពក្នុងប្រទេសឲ្យសុខសាន្តត្រាណឡើងវិញ និងដោះស្រាយរាល់វិវាទជាមួយមហាអំណាចបរទេស (មាត្រា១)។ ស្តេចសៀមទទួលបាននូវអំណាចតែងតាំងអភិបាលលើទឹកដីកម្ពុជា (មាត្រា៦ និង៧)។ ខេត្តបាត់ដំបង និងអង្គរត្រូវបានកាត់ទៅឲ្យសៀម ហើយការប្រគល់ឲ្យខេត្តពោធិសាត់ និងខេត្តកំពង់ស្វាយដែលពួកសៀមបានកាន់កាប់នាពេលស្តេច **ស៊ីវុត្ថា** បះបោរ ត្រូវភ្ជាប់លក្ខខណ្ឌទៅនឹង «ឥរិយាបថល្អ» របស់ក្សត្រកម្ពុជា[143]។ ដូចការលើកឡើងរបស់បណ្ឌិត **សារិន ឆាក** សន្ធិសញ្ញាសម្ងាត់នោះមាន **ខកាភៈនៃការយល់ព្រម** (Vice de consentement) ហើយត្រូវតែចាត់ទុកថាជាមោឃៈ[144]។

បារាំងបានច្រានចោលសន្ធិសញ្ញាសម្ងាត់កម្ពុជា-សៀម ឆ្នាំ១៨៦៣ ដោយព្យាយាមធ្វើការចរចារជាច្រើនលើកច្រើនសារ ដើម្បីធ្វើសន្ធិសញ្ញាថ្មីមួយជាមួយសៀម។ បារាំងព្យាយាមដោះស្រាយបញ្ហាព្រំដែនខាងលិចរបស់កម្ពុជាជាមួយសៀម [145] អោយបានប្រសើរ និងជាស្ថាពរ។ កុងស៊ុលបារាំងឈ្មោះ **អូបារ៉េ** (AUBARET) បានជំទាស់តវ៉ាយ៉ាងក្តៀវក្លាជាមួយរាជវាំងសៀមនៅទីក្រុងបាងកក ចំពោះសន្ធិសញ្ញាសម្ងាត់ ហើយលោកទទួលបានជោគជ័យក្នុងការចុះហត្ថលេខាលើកិច្ចសម្រុះសម្រួលចុះថ្ងៃទី១៤ ខែមេសា ឆ្នាំ១៨៦៥ ដែលតាមរយៈនោះ សៀមទទួលស្គាល់អាណាព្យាបាលបារាំងនៅកម្ពុជា (មាត្រា១) ហើយប្រកាសថាសន្ធិសញ្ញាសម្ងាត់ ត្រូវបានចាត់ទុកជាមោឃៈ (មាត្រា២) [146]។ ទោះយ៉ាងនេះក្តី សៀមបានបញ្ចូលដោយជោគជ័យនូវមាត្រា៥ ដែលផ្ទុយគ្នាទៅនឹងមាត្រា១ ដែលមានខ្លឹមសារដូចតទៅ៖ «*ព្រះរាជាណាចក្រកម្ពុជាត្រូវបានទទួលស្គាល់ថាជាប្រទេសសេរី និង ឯករាជ្យ។ ព្រះរាជាណាចក្រកម្ពុជាពុំស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រទេសណាមួយឡើយ ហើយដូច្នេះត្រូវដាក់ឱ្យស្ថិតចន្លោះប្រទេសជាកម្មសិទ្ធរបស់បារាំងម្ខាង និងកម្មសិទ្ធិសៀមម្ខាងទៀត*»។ កិច្ចសម្រុះសម្រួលនោះក៏មានបញ្ញត្តិស្តីពីព្រំដែនដែរ ៖«*ព្រំដែនខេត្តបាត់ដំបង និងអង្គរ ព្រមទាំងព្រំដែនប្រទេសឡាវដែលចំណុះសៀម និងដែលឋិតនៅជាប់ប្រទេសកម្ពុជា ត្រូវបានទទួលយក និងទទួលស្គាល់ដោយបារាំង ក្នុងស្ថាន*

---

[141] លិខិតរបស់ឧត្តមនាវី **ក្រង់ឌីយែរ** ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៨៦៤ (លើកឡើងដោយបណ្ឌិត **សារិន ឆាក** ក្នុងសារណារបស់លោកដែលមានចំណងជើងថា៖ « SARIN CHHAK, *Situation politique extérieure du Cambodge de 1863 à 1884.* Mémoire de DES de Sciences politiques, dir., P. REUTEUR, Université de Paris, Faculté de droit et des sciences économiques, 1964, p. 140។

[142] FOREST (A.), *Le Cambodge et la colonisation française. Histoire d'une colonisation sans heurts (1897-1920).* Paris, L'Harmattan, 1980, p. 7.

[143] SARIN CHHAK, *Situation politique extérieure*, *Op. cit.*, p. 150.

[144] SARIN CHHAK, *Situation politique extérieure*, *Op. cit.*, p. 151.

[145] MEYER (Ch.), *Derrière le sourire khmer.* Paris, Plon, 1971, p. 99.

[146] SARIN CHHAK, *Situation politique extérieure, Op. cit.*, p. 154.

*ភាពដូចនៅថ្ងៃចុះហត្ថលេខាលើកិច្ចសម្រុះសម្រួលនោះ»*[147]។ ឧត្តមនាវីឯក GRANDIÈRE គឺជាបុគ្គលដំបូងបង្អស់ដែលជំទាស់តវ៉ាទៅនឹងកិច្ចសម្រុះសម្រួលនេះ។ នៅថ្ងៃទី២៩ ខែមិនា ឆ្នាំ១៨៦៧ លោកបានសរសេរលិខិតជូនរដ្ឋមន្ត្រីក្រសួងកងទ័ពជើងទឹកថា៖ *«ខេត្តបាត់ដំបង និងអង្គរជាកម្មសិទ្ធិរបស់កម្ពុជា ហើយថាប្រទេសសៀមដែលទៅតាំងទីនៅទីនោះពុំមែនតាមច្បាប់ដណ្តើមយកទេ ប៉ុន្តែគឺជាការឆក់ប្លន់យ៉ាងពិតប្រាកដមួយ»* [148] ។ រដ្ឋមន្ត្រីក្រសួងកងទ័ពជើងទឹកក៏បានរិះគន់ផងដែរទៅលើកិច្ចសម្រុះសម្រួលដែលមានយោងទៅដល់ប្រទេសឡាវជារបស់សៀម ដោយរំពឹងថាវាបើកផ្លូវអោយសៀមធ្វើកាត់យកប្រទេសឡាវមកធ្វើជាចំណុះសៀម។

ក្រោយមក បារាំងបានចុះហត្ថលេខាលើសន្ធិសញ្ញាចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៨៦៧[149] ជាមួយសៀមនៅទីក្រុងបារីស ដែលតាមរយៈនោះស្តេចសៀមទទួលស្គាល់អាណាព្យាបាលបារាំងនៅកម្ពុជា (មាត្រា១) ហើយសន្ធិសញ្ញាសម្ងាត់ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៦៣ ត្រូវបានប្រកាសថាជាមោឃៈ (មាត្រា២)។ ជាថ្នូរមកវិញ បារាំងទទួលស្គាល់ការត្រួតត្រារបស់សៀមលើទឹកដីបាត់ដំបង និងអង្គរ។ ជាក់ស្តែង ខេត្តបាត់ដំបូ (បាត់ដំបង) និងអង្គរ (សៀមរាប) នៅតែជាកម្មសិទ្ធិរបស់ព្រះរាជាណាចក្រសៀម (មាត្រា៤)។ សៀមនឹងប្តេជ្ញាមិនទន្ទ្រានយកទឹកដី កម្ពុជាឡើយ (មាត្រា៥)។ រដ្ឋមន្ត្រីក្រសួងការបរទេសបារាំងបានរំពឹងថាវាមានប្រយោជន៍ណាស់សម្រាប់បារាំង ក្នុងការធ្វើសម្បទាន ដោយផ្លាស់ប្តូរការទទួលស្គាល់អាណាព្យាបាលរបស់បារាំងនៅកម្ពុជា ជាមួយនឹងការកាត់ខេត្តទាំងពីរនេះទៅឱ្យសៀម[150]។

សន្ធិសញ្ញាបារាំង-សៀមចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៨៦៧ គឺជាសន្ធិសញ្ញាព្រំដែនដំបូងបង្អស់ដែលបារាំងចុះហត្ថលេខាក្នុងនាមកម្ពុជា។ សន្ធិសញ្ញានេះក៏បង្ហាញផងដែរថា ទាក់ទងទៅនឹងបញ្ហាព្រំដែន សៀមមានបំណងឆ្លងពីក្របខណ្ឌទំនៀមទំលាប់ទៅជាក្របខណ្ឌអនុសញ្ញា។ ដូច្នេះ តាមផ្លូវច្បាប់នេះគឺជាសន្ធិសញ្ញាដំបូងដែលកំណត់ព្រំដែនរវាងកម្ពុជា និងសៀម។ ជាក់ស្តែង តាមព្រឹត្តិហេតុ ខេត្តទាំងពីរនេះត្រូវបានដាក់ឱ្យឋិតក្រោមការគ្រប់គ្រងរបស់សៀម ដើម្បីជាល័ក្ខខណ្ឌឲ្យសៀមទទួលស្គាល់ស្តេច **អង្គ អេង** ដែលបានឡើងគ្រងរាជ្យនៅក្នុងឆ្នាំ ១៧៩៤ នៅក្រុងបាងកក ។ ឧត្តមមន្ត្រីកម្ពុជាម្នាក់ឈ្មោះ **បែន** (Bên) ត្រូវបានសៀមតែងតាំងជាអភិបាលខេត្តបាត់ដំបង និងអង្គរ ក៏ប៉ុន្តែលុះត្រាណាតែរណបសៀមដាច់ខាត ហើយពុំទទួលបញ្ជាណាមួយពីស្តេច **អង្គ អេង** ឡើយ។ លោក **ប្រ៊ីគស៍** (BRIGGS) បានកត់សំគាល់ថា៖ *«ប្រការនេះគឺជាការកាត់យកទឹកដីដោយវិធីល្បួងចិត្ត ដោយពុំមានសន្ធិ*

---

[147] SARIN CHHAK, *Situation politique extérieure*, *Op. cit.*, p. 158.

[148] BERNARD (Colonel F.), *À l'école des diplomates: La perte et le retour d'Angkor. Paris, Les Œuvres Représentatives, 1933*, p. 53.

[149] សន្ធិសញ្ញាធ្វើឡើងរវាងប្រទេសបារាំង និងព្រះរាជាណាចក្រសៀម ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៨៦៧។ Archives nationales de France. Centre des Archives d'Outre Mer, Indochine. Fonds du GGI : 39537-39549 ; DE CLERCQ, *Recueil des Traité de la France,* vol. II, p. 595. JENNAR (R.), *Les frontières du Cambodge contemporain*, Thèse, Institut national des langues et civilisations orientales, Paris, 1998.

[150] SARIN CHHAK, *Situation politique extérieure*, *Op. cit.*, p. 162.

*សញ្ញា និងការព្រមព្រៀងផ្សេងជាលាយល័ក្ខអក្សរ ឬផ្ទាល់មាត់ ប្រាកដប្រជា ឬដោយតុណ្ហីភាព ដែលធ្វើឡើងនៅជំនាន់នោះ ឬក្រោយជំនាន់នោះ រវាងប្រទេសទាំងពីរ»*[151]។

ដូច្នេះ អង្គរ និងបាត់ដំបងត្រូវកាត់ចេញពីប្រទេសកម្ពុជា ដោយរង់ចាំការប្រកាសជាផ្លូវការតាមរយៈសន្ធិសញ្ញាបារាំង-សៀមចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៨៦៧។ ក៏ប៉ុន្តែ ព្រះបាទ **នរោត្តម** ជំទាស់តវ៉ា និងការបោះបង់ចោលអង្គរ និងបាត់ដំបង។ ទ្រង់ក៏បានទាមទារយកមកវិញផងដែរនូវខេត្តម្លូរព្រៃ និងទន្លេរពៅ ព្រោះពុំមានអនុសញ្ញាណាមួយចែងពីការកាត់ខេត្តខាងលើនេះទៅឲ្យសៀមឡើយ។ សៀមដឹងថាប័ណ្ណកម្មសិទ្ធិគតិយុត្តិរបស់ខ្លួនទៅលើខេត្តមួយចំនួនមានមោឃៈភាព[152]។ គណៈកម្មការទទួលបន្ទុកកំណត់ព្រំដែនរវាងកម្ពុជា និងសៀមត្រូវបានបង្កើតឡើង ដោយអនុលោមតាមមាត្រា៩នៃសន្ធិសញ្ញា។ ព្រែកកំពង់ប្រាក់ (បច្ចុប្បន្នគឺស្ទឹងស្វាយដូនកែវ) ត្រូវបានប្រើសម្រាប់កំណត់ព្រំដែនរវាងខេត្តពោធិសាត់ និងខេត្តបាត់ដំបង។ ទោះយ៉ាងនេះក្ដី កិច្ចការកំណត់ព្រំដែនត្រូវបានបញ្ឈប់ នៅពេលដែលមន្ត្រីសៀមចាកចេញទៅកាន់ទីក្រុងបាងកក ទាំងពុំបានផ្ដល់ដំណឹងជាមុនជូនដល់មន្ត្រីបារាំង[153]។

ចាប់ពីឆ្នាំ១៨៧០ ដល់ ១៨៧៣ (សេចក្ដីសម្រេចស្ដីពីការកំណត់ព្រំដែនចុះថ្ងៃទី ៩ កក្កដា ឆ្នាំ១៨៧០ និងអនុសញ្ញាកំណត់ព្រំដែន ចុះថ្ងៃទី១៧ កក្កដា ឆ្នាំ១៨៧៣) ព្រំដែនគោកកម្ពុជា និងកូសាំងស៊ីនទាំងមូលត្រូវបានកំណត់។ បណ្ឌិត **សារិន ឆាក** ក៏បានលើកឡើងពីការជំទាស់តវ៉ារបស់ព្រះបាទ **នរោត្តម** និងប្រជាជនចំពោះការទន្ទ្រានឈ្លានពានលើទឹកដីកម្ពុជាពីសំណាក់អាជ្ញាធរអាណាព្យាបាលផងដែរ។ ទោះបីជាមានការប្រឆាំងតវ៉ាទាំងនេះក្ដី ក៏គំនូសព្រំដែនរវាងកម្ពុជា និងកូសាំងស៊ីនរបស់បារាំងត្រូវបានធ្វើឡើងដោយអនុសញ្ញាមួយដែលចុះហត្ថលេខាដោយព្រះមហាក្សត្រខ្មែរ គឺព្រះបាទ **នរោត្តម** និងទេសាភិបាលកូសាំងស៊ីននៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៨៧៣។ ដោយឡែក ព្រំដែនរវាងកម្ពុជា និងអាណ្ណាមត្រូវបានកំណត់ដោយអាជ្ញាធរអាណានិគម តាមសេចក្ដី សម្រេចឯកតោភាគីចុះថ្ងៃទី ៣០ មេសា ឆ្នាំ ១៩២៩[154]។

នៅក្នុងឆ្នាំ១៨៨៤ ស្ថិតនៅក្រោមការគំរាមប្រើកំលាំង បារាំងបានបង្ខំឲ្យកម្ពុជាចុះអនុសញ្ញាទី២មួយទៀត ដើម្បីបង្កើតសហភាពគយរវាងកម្ពុជា កូសាំងស៊ីន អាណ្ណាម និងតុងកឹង។ អនុសញ្ញានេះត្រូវបានព្រះមហាក្សត្រកម្ពុជាឡាយព្រះហស្ថលេខានាថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤។ យោងតាមខ្លឹមសារនៃអនុសញ្ញានេះ៖ *«មហាក្សត្រខ្មែរយល់ព្រមទទួលកំណែទម្រង់រដ្ឋបាល តុលាការ ហិរញ្ញវត្ថុ និងពាណិជ្ជកម្មគ្រប់រូបភាព ដែលរដ្ឋាភិបាលនៃ សាធារណៈរដ្ឋបារាំងវិនិច្ឆ័យ ថាមានប្រយោជន៍ទៅថ្ងៃមុខ*

---

151 BRIGGS (L. P.), «The treaty of March 23, 1907 between France and Siam and the return of Battambang and Angkor to Cambodia», *The Far Eastern Quarterly,* vol. V, 4 (August), p. 442.
152 BERNARD (Colonel F.), *Opt. cit.,* pp. 61-65.
153 SARIN CHHAK, *Situation politique extérieure, Op. cit.*, p. 173.
154 SARIN CHHAK, *Les frontières du Cambodge, Op. cit.*, p. 48.

*ដើម្បីសម្រួលដល់ការបំពេញអាណាព្យាបាលភាពរបស់ខ្លួន»* (មាត្រា១)។ បណ្ឌិត **សារិន ឆាក** បានកត់សំគាល់ថា៖ *«អនុសញ្ញាពុំមានបំណងបោះបង់សមត្ថកិច្ចរដ្ឋទាំងស្រុងឡើយ ប៉ុន្តែជាការផ្ទេរសមត្ថកិច្ចមួយចំនួន...ជូនមហាអំណាចអ្នកគាំពារ»*[155]។ ផលវិបាកគតិយុត្តិនៃអនុសញ្ញានេះ គឺការពង្រឹងឡើងវិញនូវការត្រួតត្រារដ្ឋបាលក្នុងប្រទេស ក្រោមរដ្ឋាភិបាលកូសាំងស៊ីន និងការពង្រីកអំណាចរបស់រ៉េស៊ីដង់ជាន់ខ្ពស់។ អនុសញ្ញាចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤ អាចត្រូវបកស្រាយថា ជាការផ្ទេរការអនុវត្តសមត្ថកិច្ចអន្តរជាតិ និងផ្ទៃក្នុងរបស់កម្ពុជាឱ្យប្រទេសបារាំង។ អនុសញ្ញាដែលបារាំងបង្ខំនោះ ត្រូវក្លាយជាសញ្ញានៃរបត់នយោបាយបារាំងនៅក្នុងប្រទេសកម្ពុជា ដោយដកហូតការគ្រប់គ្រងប្រទេសពីព្រះមហាក្សត្រ ទៅដាក់នៅក្រោមអំណាចអាណាព្យាបាល[156]។ ព្រះរាជបញ្ញត្តិឆ្នាំ១៩០៥មួយចំនួនបានលុបចោលនូវការបែងចែកខេត្តជាលក្ខណះបុគ្គល ហើយបានបង្រួបបង្រួមការគ្រប់គ្រងខេត្តខាងលើ ក្រោមការដឹកនាំរបស់នាយករដ្ឋមន្ត្រី[157]។ ក្រោយមក អាជ្ញាធរបារាំងបានខ្នះខ្នែងរៀបចំព្រំដែនកម្ពុជាដែលទទួលស្គាល់ជាអន្តរជាតិ តាមរយៈសន្ធិសញ្ញាអន្តរជាតិនានា បន្ទាប់មកកំណត់ព្រំដែនទាំងនោះ និងគូសបន្ទាត់ព្រំដែននៅលើផែនទីតែម្តង។

## §២. សន្ធិសញ្ញាបារាំង-សៀមឆ្នាំ១៩០៤ និង១៩០៧

ដើម្បីបញ្ចៀសការប្រណាំងប្រជែងផ្នែកអាណានិគម ប្រទេសបារាំង និងចក្រភពអង់គ្លេសបានសម្រេចបែងចែកដែនឥទ្ធិពលរបស់ពួកគេ។ នៅចុងសតវត្សរ៍ទី១៩ បារាំងចង់បង្កើតរដ្ឋទ្រនាប់មួយនៅចន្លោះឥណ្ឌូចិន និងភូមា។ នៅថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៨៦ ប្រទេសបារាំង និងអង់គ្លេសបានចុះហត្ថលេខាលើសេចក្តីប្រកាសមួយ ដែលតាមរយៈនោះ មហាអំណាចទាំងពីរទទួលស្គាល់សេរីភាពធ្វើសកម្មភាពក្នុងខេត្តទាំងអស់របស់សៀមដែលពាក់ព័ន្ធទៅនឹងកម្មសិទ្ធិរបស់មហាអំណាចទាំងពីរ [158] ទាំងធានាបូរណភាព និងឯករាជ្យភាពរបស់សៀមមួយផ្នែក។ ឆ្លើយតបទៅនឹងការដាក់អាណាព្យាបាលបារាំងនៅតុងកឹង ពួកអង់គ្លេសបានដណ្តើមយកប្រទេសភូមាខាងលើ នៅក្នុងឆ្នាំ១៨៨៦។ ស្របពេលនោះដែរ នៅក្នុងឆ្នាំ១៨៨៨ ប្រទេសបារាំងបានកាត់យកជាផ្លូវការ ក្នុងនាមប្រទេសវៀតណាម នូវឃុំថៃចំនួន១២នៅលួងប្រាបាង។ សន្ធិសញ្ញាមួយរវាងបារាំង និងអង់គ្លេសបានគ្រោងអំពីការពង្រីកដែនដីអាណានិគម និងអាណាព្យាបាលរៀង១ខ្លួនរបស់ពួកគេ។

សូម្បីតែក្រោយពីបារាំងដាក់អាណាព្យាបាលលើប្រទេសកម្ពុជាក្តី សៀមនៅតែព្យាយាមវាតទីយកទឹកដីរបស់កម្ពុជា។ ឆ្លៀតឱកាសមានការបះបោរក្នុងឆ្នាំ១៨៨៥ សៀមបានលេបយកឃុំមួយចំនួន

---

[155] SARIN CHHAK, *Situation politique extérieure*, *Op. cit.*, p. 118.
[156] MEYER (Ch.), *Op. cit.*, p. 98.
[157] GOUR (C-G.), *Ibid.*, p. 35.
[158] BERNARD (Colonel F.), *Op. cit.*, p. 122.

ក្នុងស្រុកកំពង់ស្វាយ ហើយបានបញ្ចប់ការកាត់យកទឹកដីនៃខេត្តកោះកុងទាំងមូល[159]។ ការទន្ទ្រានចូលទាំងនេះត្រូវបានធ្វើឱ្យសម្រេចដោយការសង់ផ្លូវហ៊ុំព័ទ្ធភូមិនានារបស់កម្ពុជា និងបន្ទាប់មកដោយការបោះទីតាំងប៉ុស្តិ៍គយ។ ក៏ប៉ុន្តែ ខេត្តដែលត្រូវបានកាន់កាប់ដូចជា បាត់ដំបង ម្លូព្រៃ និងទន្លេរពៅ នៅតែឋិតនៅក្រោមអធិបតេយ្យភាពសៀមដដែល។

នៅពេលនោះ បារាំងបារម្ភនឹងប្រទេសឡាវដែលខ្លួនចង់ដាក់អាណានិគម និងពង្រីកឱ្យធំ។ នៅក្នុងឆ្នាំ១៨៨៦ លោក **អូហ្គូស ប៉ាវី** (AUGUSTE PAVIE) (ដែលនៅពេលនោះជាកុងស៊ុលបារាំងនៅលួងព្រះបាង) បានលើកឡើងពីបញ្ហាព្រំដែនរវាងសៀម និងឡាវ។ ប៉ុន្តែ កិច្ចពិភាក្សានានាពុំបានទទួលលទ្ធផលវិជ្ជមានឡើយ។ ចាប់ពីឆ្នាំ១៨៦៨មក ការកំណត់ព្រំដែននៃប្រទេសកម្ពុជានៅពុំទាន់ចប់សព្វគ្រប់នៅឡើយទេ។ លោក PAVIE ទទួលបន្ទុកកំណត់ព្រំដែនទាំងតុងកឹង អាណ្ណាម ឡាវ និងកម្ពុជាផងដែរ[160]។ លោកបានសង្កេតឃើញថា នៅគ្រប់ទីកន្លែង សៀមបានយកធ្វើជាកម្មសិទ្ធិខ្លួននូវដែនដីដែលពួកគេនៅមិនទាន់បានកាន់កាប់[161]។

ដូច្នេះ ប្រទេសបារាំងបានសម្រេចចិត្តពង្រីកអាណាព្យាបាលរបស់ខ្លួននៅត្រើយខាងកើតទាំងមូលនៃទន្លេមេគង្គ ហើយយកលេសពីសិទ្ធិរបស់ខ្លួនក្នុងការត្រួតត្រាលើវៀតណាម ដើម្បីវាតទីយកទឹកដីនៅក្នុងតំបន់។ នៅក្នុងឆ្នាំ១៩៨៣ ឧប្បត្តិហេតុជាច្រើនបានកើតឡើងជាមួយសៀម។ នៅក្នុងឆ្នាំ១៨៩៣ ដោយយកលេសថាសៀមវាយប្រហារអាណ្ណាម ប្រទេសបារាំងបានធ្វើការវាយបកទៅលើសៀមវិញ ដោយប្រើប្រាស់នូវកងទ័ពរបស់ខ្លួនដែលមកពីអាណ្ណាម ដោយវាយបំបាក់យ៉ាងឆាប់រហ័សនូវប៉ុស្តិ៍ទាំងអស់របស់សៀម ដែលបង្កើតនៅតាមបណ្តោយត្រើយខាងឆ្វេងទន្លេមេគង្គ និងចាប់ផ្តើមកាន់កាប់ភាគខាងត្បូងទាំងអស់របស់ប្រទេសឡាវ។ នៅក្នុងខែកក្កដា ឆ្នាំ១៨៩៣ នាវាកាំភ្លើងធំបារាំងពីរគ្រឿងបានសម្រុកចូលទៅក្នុងពាមទន្លេមេណាម ហើយក៏ត្រូវរងការបាញ់សន្ធប់ពីបន្ទាយរឹងមាំរបស់សៀមដែលបង្កអោយមានអ្នករបួស និងស្លាប់។ ដូច្នេះ សៀមប្រព្រឹត្តខុស ដោយបានបាញ់មុន ដែលនេះផ្តល់ជាដើមចម*នៃការប្រកាសសង្គ្រាម* ទៅឱ្យបារាំងដែលកំពុងតែទន្ទឹងរង់ចាំ។ នាវាកាំភ្លើងធំបានវាយតបតយ៉ាងសាហាវ រួចធ្វើដំណើរឆ្ពោះទៅកាន់ទីក្រុងបាងកក និងបានបង្ខំឱ្យបិទផ្លូវគមនាគមន៍លើទន្លេមេណាម។ នៅថ្ងៃទី១៩ ខែកក្កដា លោក **អូហ្គូស ប៉ាវី** (ដែលក្លាយជាអគ្គរដ្ឋទូតរងនៃប្រទេសបារាំងនៅបាងកកតាំងពីខែកុម្ភៈ ឆ្នាំ១៨៩២) បានបង្ហាញឱសានវាទមួយ[162] ឱ្យរដ្ឋាភិបាលសៀម។ គឺចក្រភពអង់គ្លេសដែលដាក់សម្ពាធឱ្យព្រះចៅ **ជូឡា ឡុងកន** ព្រមទទួលរាល់លក្ខខណ្ឌក្នុងឱសានវាទរបស់បារាំង។

---

[159] លិខិតចុះថ្ងៃទី២៨ មេសា ១៨៩១ របស់លោក **ថមសុន** (THOMSON)

[160] BERNARD (Colonel F.), *Op. cit.*, p.105.

[161] BERNARD (Colonel F.), p. 106.

[162] BERNARD (Colonel F.), *Op. cit.*, p.115.

ក្នុងសន្ធិសញ្ញាបារាំង-សៀមចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ១៨៩៣ សៀមបានលះបង់ការទាមទារទាំងអស់នៅលើទឹកដីត្រើយខាងឆ្វេងទន្លេមេគង្គ រួមទាំងកោះទាំងអស់នៃទន្លេ (មាត្រា១)។ ទឹកដីដែលទទួលបានមកវិញត្រូវបានបែងចែកជាបីចំណែក។ នៅទិសខាងជើង លួងប្រាបាងត្រូវបានភ្ជាប់នឹងតុងកឹងឡើងវិញ រីឯទន្លេមេគង្គខាងលើនៅចន្លោះកែមម៉ារ៉ាត (Kemmarat) និងលួងប្រាបាងត្រូវបានភ្ជាប់ទៅនឹងអាណ្ណាមវិញ ហើយខេត្តស្ទឹងត្រែងរបស់ខ្មែរ (ទន្លេមេគង្គកណ្តាល) ត្រូវបានបញ្ចូលក្នុងទឹកដីកូសាំងស៊ីន និងបន្ទាប់មកកាត់ទៅឲ្យប្រទេសឡាវ[163]។ រដ្ឋាភិបាលសៀមត្រូវបានហាមប្រាមពុំអោយសង់ប៉ុស្តិ៍ជាបន្ទាយរឹងមាំ ឬគ្រឹះស្ថានយោធានៅក្នុងខេត្តបាត់ដំបង និងសៀមរាប និងនៅលើចំរៀកដីដែលមានទទឹង២៥គីឡូម៉ែត្រ នៅត្រើយខាងស្តាំទាំងមូលនៃទន្លេមេគង្គឡើយ។ កងកម្លាំងបារាំងបានកាន់កាប់ខេត្តចាន់តាប៊ុនដែលនៅជាប់ឆ្នេរសមុទ្រ (Chantaboun) ដែលមានជនជាតិខ្មែររស់នៅ។ ប៉ុន្តែ សៀមនៅតែរក្សាទុកនូវខេត្តក្រាត (ត្រាត) និងកោះកុងជានិច្ច។ ដូច្នេះ សន្ធិសញ្ញាឆ្នាំ១៨៩៣ បានកំណត់ព្រំដែនទាំងអស់រវាងឡាវ និងសៀម ប៉ុន្តែសន្ធិសញ្ញានេះពុំបានកែប្រែស្ថានភាពនៃប្រទេសកម្ពុជាអ្វីសោះឡើយ។

ក៏ប៉ុន្តែ នៅកន្លែងដទៃវិញ ទំនាក់ទំនងបារាំង និងសៀមនៅតែលំបាក ព្រោះបាងកកពុំមានបំណងគោរពតាមលក្ខខណ្ឌនយោបាយនៃសន្ធិសញ្ញាឆ្នាំ១៨៩៣ឡើយ។ ដោយរំលោភលើតំបន់គ្មានយោធា កងទ័ពសៀមនៅតែបន្តការលុកលុយទន្ទ្រានរបស់ខ្លួននៅប្រទេសឡាវ និងក្នុងបណ្តាខេត្តភាគខាងជើងកម្ពុជា។ លោកអគ្គទេសាភិបាលឥណ្ឌូចិន ឈ្មោះ **ប៉ូល ឌូមើ** (PAUL DOUMER) ក៏បានភ្ជាប់ទំនាក់ទំនងជាមួយសៀមឡើងវិញ ហើយនៅឆ្នាំ១៨៩៩ ភាគីទាំងពីរបានចាប់ផ្តើមធ្វើការចរចារយ៉ាងពិតប្រាកដឡើងវិញអំពីបញ្ហាដែលនៅសេសទាំងអស់ ពិសេសគឺបញ្ហាប្រទេសឡាវ។ ចាប់ពីឆ្នាំ១៩០១មក ដោយមានការព្រមព្រៀងរបស់ទីក្រុងបាងកក អតីតខេត្តក្រាត (ត្រាត) របស់ខ្មែរ ត្រូវបានរ៉េស៊ីដង់មួយរូប និងកងពលបារាំងមួយកាន់កាប់ ទំនងក្នុងគោលបំណងត្រួតពិនិត្យការដឹកជញ្ជូនតាមផ្លូវសមុទ្រនៅតាមបណ្តោយឆ្នេរសមុទ្រកម្ពុជានៃឈូងសមុទ្រថៃអោយបានល្អប្រសើរ។

ពេលប្រទេសកម្ពុជាឋិតក្រោមអាណាព្យាបាលបារាំង យើងឃើញថាប្រទេសសៀមប្រើនយោបាយទន្ទ្រានយ៉ាងសន្សឹមៗ តែប្រាកដប្រជាទៅលើខេត្តជាប់សមុទ្រនានារបស់កម្ពុជា។ ដើម្បីប្រឈមនឹងការពង្រីកដែនដីរបស់សៀម ប្រទេសបារាំងបានស្វះស្វែងធ្វើកិច្ចព្រមព្រៀងព្រំដែនមួយជាមួយសៀម ដើម្បីធានាស្ថិរភាពនៃដែនដីកម្ពុជា។

ព្រំដែនបច្ចុប្បន្នរវាងកម្ពុជា និងសៀមគឺផ្អែកលើសន្ធិសញ្ញាបារាំង-សៀមឆ្នាំ១៩០៤ និងឆ្នាំ១៩០៧ ។ នៅថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩០២ លោក **ដេក្លាសេ** (DECLASSÉ) រដ្ឋមន្ត្រីក្រសួងការបរទេស

[163] SARIN CHHAK, *Les frontières du Cambodge, Op. cit.*, pp. 26-32.

បារាំង បានចុះហត្ថលេខាលើអនុសញ្ញាមួយជាមួយសៀម ធ្វើអោយប្រទេសកម្ពុជាទទួលបានមកវិញនូវខេត្រម្លូព្រៃ និងទន្លេរពៅ ជាថ្នូរនឹងការលុបបំបាត់សិទ្ធិយុត្តាធិការ និងការការពារ ដែលផ្តល់ឱ្យបារាំងដោយអនុសញ្ញាឆ្នាំ១៨៩៣។ អនុសញ្ញានេះពុំត្រូវបានផ្តល់សច្ចាប័ននៅប្រទេសបារាំងទេ។ កិច្ចចរចារថ្មីៗបានឈានដល់ការធ្វើសន្ធិសញ្ញាចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩០៤។ នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩០៤ រដ្ឋមន្រ្តីក្រសួងការបរទេសបារាំង និងសៀមបានចុះហត្ថលេខាលើពិធីសារមួយ។

សន្ធិសញ្ញាបារាំង-សៀមឆ្នាំ១៩០៤[164] មាន១៦ប្រការ។ នៅក្នុងបុព្វកថាគេបានរំលឹកអំពីគោលបំណងរបស់ភាគីទាំងពីរក្នុងការដោះស្រាយការលំបាកមួយចំនួន ដែលកើតឡើងអំពីការបកស្រាយអនុសញ្ញាចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ១៨៩៣។ គំនូសព្រំដែននៅខាងជើងបឹងទន្លេសាបនៅតែពុំច្បាស់លាស់ តាំងពីឆ្នាំ១៨៦៨ មកម្ល៉េះ។ សញ្ញាឆ្នាំ១៩០៤មានគោលបំណងកែតម្រូវបញ្ហានេះផងដែរ។

មាត្រា១នៃសន្ធិសញ្ញាឆ្នាំ១៩០៤ ចែងថា «*ខ្សែបន្ទាត់ព្រំដែនរវាងប្រទេសសៀម និងប្រទេសកម្ពុជា ចាប់ផ្តើម តាមត្រើយខាងឆ្វេងនៃទន្លេសាប ពីមាត់ពាមស្ទឹងរលួសទៅ ហើយព្រំប្រទល់ដែននេះដើរតាមខ្សែស្រប (Parallèle)នឹងចំណុចខាងលើ ទៅតាមទិសខាងកើតរហូតដល់ស្ទឹងព្រែកកំពង់ចាម រួចងាកទៅខាងជើងរហូតទៅប្រសព្វនឹងខ្សែបណ្តោយ (Méridien) នៃចំណុចខាងលើឡើងរហូតដល់ជួរភ្នំដងរែក។ ពីទីនោះ ខ្សែបន្ទាត់ព្រំដែនដើរតាមខ្សែបន្ទាត់បែងចែកទឹក (Ligne de partage des eaux) រវាងអាងនៃទន្លេណាំសេន និងទន្លេមេគង្គមួយផ្នែក និងទន្លេណាំមូនមួយផ្នែកហើយទៅភ្ជាប់និងជួរភ្នំប៉ាដាងដែលខ្សែបន្ទាត់ព្រំដែននេះដើរទៅតាមខ្សែបន្ទាត់ទ្រនុងកំពូលភ្នំ (Crête) ត្រង់ទៅទិសខាងកើតរហូតដល់ទន្លេមេគង្គ។ នៅផ្នែកខាងលើនៃចំណុចនេះ ទន្លេមេគង្គនៅតែជាព្រំប្រទល់ប្រទល់នៃព្រះរាជាណាចក្រសៀម ដោយអនុលោមតាមប្រការទី១នៃសន្ធិសញ្ញាចុះថ្ងៃទី ០៣ តុលា ឆ្នាំ១៨៩៣* »។

តាមរយៈសន្ធិសញ្ញាឆ្នាំ១៩០៤ ប្រទេសបារាំងបានកាត់ផ្តាច់ទឹកដីពីរកន្លែងនៅត្រើយខាងឆ្វេងទន្លេមេគង្គពីប្រទេសសៀម ៖ ខេត្តម្លូព្រៃ និងទន្លេរពៅរបស់កម្ពុជាដែលត្រូវប្រគល់ទៅឲ្យកម្ពុជាវិញ និងទឹកដីនៃព្រះរាជាណាចក្របាសាក់ដែលនឹងជាផ្នែកមួយនៃទឹកដីឡាវ[165]។ រាជធានីចំប៉ាសាក់ (បាសាក់) ដែលគួរតែត្រូវជាទឹកដីរបស់ កម្ពុជានោះត្រូវបានបញ្ចូលទៅក្នុងទឹកដីឡាវវិញ។ សន្ធិសញ្ញានេះបានបន្សល់ទឹកដីនៃត្រើយខាងស្តាំនៃទន្លេ មេគង្គឲ្យទៅប្រទេសសៀម លើកលែងទឹកដីលួងប្រាបាងចេញ។ លើសពីនេះទៀត សន្ធិសញ្ញាឆ្នាំ១៩០៤បានទទួលស្គាល់ថា ខ្សែបន្ទាត់ទ្រនុងកំពូលភ្នំ *(Crête)* ដងរែកគឺជាខ្សែបន្ទាត់ព្រំដែនកម្ពុជាជាមួយសៀម។

---

[164] DE CLERCQ, *Recueil des Traité de la France,* tome III, p. 360 ; JENNAR (R.), Les frontières du Cambodge contemporain, Thèse, Institut national des langues et civilisations orientales, Paris, 1998.
[165] SARIN CHHAK, *Les frontières du Cambodge, Op. cit.,* pp. 53.

យោងតាមប្រកាសសម្ងាត់មួយ ប្រទេសសៀមត្រូវបោះបង់ចោលបញ្ហាការកងកម្លាំងប៉ូលីសដែលឈរជើងនៅខេត្តបាត់ដំបង ស៊ីសុផុន និងសៀមរាប ឱ្យមន្ត្រីបារាំង។ ប៉ុន្តែ សម្រាប់កម្ពុជាវិញ សន្ធិសញ្ញាឆ្នាំ១៩០៤ បានបន្តបញ្ជាក់ពីការបាត់បង់ខេត្តបាត់ដំបង និងសៀមរាបដែលតំណាងអោយដួងព្រលឹងជាតិខ្មែរ។ ដោយមូលហេតុនេះហើយទើបព្រះបាទ **ស៊ីសុវត្ថិ** នៅក្នុងឱកាសធ្វើព្រះរាជទស្សនកិច្ចនៅប្រទេសបារាំងក្នុងឆ្នាំ១៩០៦ បានទាមទារសុំអោយសៀមប្រគល់ខេត្តបាត់ដំបង និងអង្គរមកអោយកម្ពុជាវិញ។ ការទាមទារទាំងនេះទំនងជាត្រូវបានអាជ្ញាធរបារាំងស្តាប់ឮទាំងអស់។

អនុសញ្ញាឆ្នាំ១៩០៤បានបញ្ជាក់អំពីឋានលេខាព្រំដែន។ ដំណាក់កាលបន្ទាប់មកទៀត គឺការ**កំណត់ព្រំដែន**។ គណៈកម្មការចម្រុះដើម្បីកំណត់ព្រំដែនមួយត្រូវបានតែងតាំង និងដឹកនាំដោយវរសេនីយទោ **ប៊ែកណា** (BERNARD) សម្រាប់ភាគីបារាំង។ តាមការស្រាវជ្រាវរបស់គណៈកម្មការព្រំដែនបានអោយដឹងថា សន្ធិសញ្ញា និងឋានលេខាពុំមានភាពស៊ីសង្វាក់គ្នាទេ។ វាក្យខណ្ឌ ១ នៃពិធីសារដែលជាឧបសម្ព័ន្ធនៃសន្ធិសញ្ញាចែងថា ៖ «...*ខ្សែបន្ទាត់ព្រំដែននេះបង្កើតបានជាព្រំដែនធម្មជាតិមួយដែលតាមរយៈព្រំដែនធម្មជាតិនេះ កំពង់ផៃក្រាត (ត្រាត) និងដែនដីទាំងឡាយដែលឋិតនៅខាងត្បូងត្រូវប្រគល់ឱ្យឥណ្ឌូចិនបារាំង...*»។ ក៏ប៉ុន្តែ សមាជិកគណៈកម្មការស្វែងរកពុំឃើញព្រំដែនធម្មជាតិក្នុងតំបន់ត្រាត ដែលគ្រាន់តែជាវាលទំនាបទាបមួយប៉ុណ្ណោះ[166]។

នៅក្នុងជួរភ្នំដងរែក ជាទូទៅ ព្រំដែនត្រូវដើរតាមខ្សែបែងចែកទឹក (ប្រការ១)[167]។ នាសម័យប្រជុំរបស់ គណៈកម្មការចម្រុះ ថ្ងៃទី០២ ខែធ្នូ ឆ្នាំ១៩០៦ ប្រធានគណៈកម្មការចម្រុះទាំងបារាំង និងសៀមបានទៅដល់ភ្នំដងរែក ដោយធ្វើដំណើរចេញពីវាលទំនាបកម្ពុជា ដោយឆ្លងកាត់តាមច្រកភ្នំកិល ដែលឋិតនៅខាងលិចប្រាសាទព្រះវិហារ រួចធ្វើដំណើរឆ្ពោះទៅទិសខាងកើត តាមបណ្តោយជួរកំពូលភ្នំ។ ពួកគេបានទស្សនាប្រាសាទព្រះវិហារ ប៉ុន្តែពុំបានធ្វើការសម្រេចអ្វីឡើយ។ នាខែមករា ឆ្នាំ១៩០៧ អគ្គ

166 BERNARD (Colonel F.), *Op. cit.*, p. 176.

167 ផែនទីដែលគណៈកម្មការកំណត់ព្រំដែនបានផលិតពុំស៊ីសង្វាក់គ្នាទាំងស្រុងទៅនឹងអត្ថបទសន្ធិសញ្ញាឆ្នាំ១៩០៤ឡើយ។ គណៈកម្មការបានគូសខ្សែបន្ទាត់ព្រំដែនឲ្យងាកចេញក្នុងតំបន់ប្រាសាទព្រះវិហារ។ តុលាការយុត្តិធម៌អន្តរជាតិបានកត់សំគាល់ថា៖ «រដ្ឋាភិបាលទាំងពីរប្រាកដជាមានអំណាចក្នុងការអនុម័តការងាកចេញនេះ»។ តុលាការបានកត់សំគាល់ផងដែរថា៖ «នៅពេលដែលផែនទីនេះត្រូវបានគូសផែនទីនេះពុំមានលក្ខណៈចាប់បង្ខំទេ»។ ប៉ុន្តែតុលាការសន្និដ្ឋានថា៖ «ទោះជាយ៉ាងណា ឥរិយាបទរបស់ថៃឡង់ដ៍បានឆ្លើយតបទៅនឹងការទទួលផែនទីទាំងនេះយ៉ាងច្បាស់ ដោយឥតប្រកែកបាន»។ តុលាការបានសន្និដ្ឋានថា៖ «ឥរិយាបទនៅពេលក្រោយទៀតរបស់ថៃឡង់ដ៍បានបញ្ជាក់ និងគាំទ្រការព្រមទទួលយកពីដំបូងរបស់ខ្លួន...»។ សេចក្តីសម្រេចរបស់តុលាការឈរលើមូលដ្ឋាននៃស្ថាប័ននីតិអន្តរជាតិ ESTOPPEL (*ការបដិសេធមិនទទួលស្គាល់ទឡ្ហីករណ៍របស់ភាគីមួយ ដោយសារទឡ្ហីករណ៍នេះវាផ្ទុយនឹងឥរិយាបថ ឬជំហរពីពេលមុនរបស់ភាគីនោះ។* ស្ថាប័ន ESTOPPEL ខុសពី ACQUIESCEMENT (ការយល់ព្រមដោយតុណ្ហីភាព) ត្រង់ភាគីដែលលើកនោះត្រូវបាត់បង់ផលប្រយោជន៍របស់ខ្លួនដោយសារតែភាគីម្ខាងទៀតបាន ប្តូរជំហររបស់ខ្លួន) (C.I.J., រឿងក្តី *ប្រាសាទព្រះវិហារ* តុលាការយុត្តិធម៌អន្តរជាតិ សាលដីកាឆ្នាំ១៩៦២ ទំព័រ ២១-៣៣)។

រដ្ឋទូតរងបារាំងនៅទីក្រុងបាងកក បានរាយការណ៍ជូនរដ្ឋាភិបាលបារាំងថា កិច្ចការកំណត់ព្រំដែនទាំងមូលបានរួចរាល់ ដោយពុំមានឧប្បត្តិហេតុអ្វីទេ[168]។

អំឡុងពេលយុទ្ធនាការកំណត់ព្រំដែនលួងប្រាបាងលើកទី២ ប្រធានគណៈកម្មការសៀម គឺឧត្តមសេនីយ **ឧត្តម** (OUDOM) បានឱ្យវរសេនីយទោ BERNARD ដឹងថា រដ្ឋាភិបាលរបស់លោកចង់ទទួលបានយកមកវិញ (Rétrocession) នូវស្រុកដានសៃ ជាថ្នូរនឹងទឹកដីមួយដែលមានទំហំប៉ុនគ្នា[169]។ ដូច្នេះ នាខែមិថុនា ឆ្នាំ១៩០៦ លោកវរសេនីយទោ BERNARD ក៏បានស្នើរដ្ឋាភិបាលបារាំងអោយធ្វើសម្បទានត្រាត និងដានសៃ (ឡាវ) ឱ្យសៀម និងឱ្យបោះបង់អភ័យឯកសិទ្ធិយុត្តាធិការបារាំង ជាថ្នូរនឹងការផ្តល់ខេត្តបាត់ដំបង និងអង្គរមកកម្ពុជាវិញ [170] ។ ការឡើងកាន់អំណាចរបស់លោក **ក្លេម៉ង់ស្សូ** (CLEMENCEAU) នាខែតុលា ឆ្នាំ១៩០៦បានជំរុញសេចក្តីសម្រេចនេះឱ្យកាន់តែលឿន។ រដ្ឋាភិបាលបារាំងបានដាក់បញ្ជាឱ្យអគ្គរដ្ឋទូតពេញសមត្ថភាពរបស់ខ្លួននៅបាងកក ឱ្យបើកចរចារថ្មីៗជាមួយសៀម។ រដ្ឋាភិបាលសៀមមានបំណងចង់ឲ្យការដោះស្រាយនេះមានភាពស្ថាពរ ហើយនៅថ្ងៃទី១៣ ខែមិនា ឆ្នាំ១៩០៧ កិច្ចព្រមព្រៀងត្រូវបានធ្វើរួច ហើយពិធីចុះហត្ថលេខាបានប្រព្រឹត្តទៅថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩០៧។

សន្ធិសញ្ញាចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩០៧ មាន៩ប្រការ និងមានពិធីសារមួយស្តីពីការកំណត់ព្រំដែន[171]។ នៅក្នុងបុព្វកថា គេបានរំលឹកពីឆន្ទៈរបស់ភាគីទាំងពីរក្នុងការធានាការដោះស្រាយជាស្ថាពរនូវរាល់ទំនាក់ទំនងដែលពាក់ព័ន្ធនឹងព្រំដែនរួមរបស់ឥណ្ឌូចិនបារាំង និងសៀម តាមរយៈប្រព័ន្ធដោះដូរដី និងការដាក់ឲ្យអនុវត្តប្រព័ន្ធយុត្តាធិការឯកភាពមួយសម្រាប់គ្រប់ជាតិសាសន៍ទាំងអស់។

តាមរយៈសន្ធិសញ្ញាឆ្នាំ១៩០៧ រដ្ឋាភិបាលសៀមប្រគល់ឱ្យបារាំងនូវទឹកដីបាត់ដំបង សៀមរាប និងស៊ីសុផុន (ប្រការ១)។ ជាថ្នូរមកវិញ ប្រទេសសៀមទទួលបានទឹកដីត្រាត និងដានសាយ ។ ប្រទេសសៀមក៏យកមកវិញនូវកោះទាំងឡាយដែលស្ថិតនៅខាងត្បូងនៃជ្រោយឡែមលីង (Lem Ling) រួមទាំងកោះគុត (Koh Kut) ផងដែរ (ប្រការ ២)។ ដោយសារប្រទេសបារាំង ប្រទេសកម្ពុជាក៏ទទួលបាននូវព្រំប្រទល់ធម្មជាតិរបស់ខ្លួនមកវិញ។ ប្រទេសបារាំងក៏បានប្រគល់ភ្លាមៗនូវទឹកដីទើបនឹងទទួលបានពីសៀមឱ្យប្រទេសកម្ពុជា ធ្វើអោយប្រទេសកម្ពុជាទទួលបានបូរណភាពទឹកដីយ៉ាងពេញលេញរបស់ខ្លួនវិញ។

ដោយអនុវត្តតាមកិច្ចសន្យានានានៃឆ្នាំ១៩០៧ គណៈកម្មការកំណត់ព្រំដែនបារាំង-សៀមត្រូវបានចាត់ឱ្យទទួលបន្ទុកកំណត់ព្រំដែន (Délimitation) វាស់ខ្សែបន្ទាត់ខណ្ឌសីមានៅនឹងកន្លែង

168 *C.I.J. Rec.* 1962, p. 18.
169 BERNARD (Colonel F.), *Op. cit.*, p.179.
170 *Ibid.*, p. 191.
171 BASDEVANT, *Recueil des Traité de la France,* tome XXII, p. 451 ; JENNAR (R.), Les frontières du Cambodge contemporain, Thèse, Institut national des langues et civilisations orientales, Paris, 1998.

(Démarcation) និងបោះបង្គោលព្រំដែន (Abornement) រវាងកម្ពុជា និងសៀម។ ផែនទីជាក់លាក់នានាត្រូវបានគូសឡើងនៅចុងបញ្ចប់នៃការងាររបស់គណៈកម្មការចម្រុះកំណត់ព្រំដែននេះ ដែលមានសមាជិកជាមន្ត្រីនៃការិយាល័យភូមិសាស្ត្ររបស់ប្រទេសនីមួយៗ ហើយផែនទីនេះទៀតសោត ត្រូវបានចុះហត្ថលេខាដោយប្រធានគណៈកម្មការបារាំង-សៀមទាំងពីរ។ ផែនទីទាំងនេះកំណត់យ៉ាងច្បាស់អំពីគំនូសព្រំដែន ហើយមានតម្លៃគតិយុត្តិនៅចំពោះមុខតុលាការយុត្តិធម៌អន្តរជាតិទីក្រុងឡាអេ នាអំឡុងពេលជម្លោះរវាងកម្ពុជា និងថៃនៅពេលក្រោយមក ទាក់ទិនអំពីកម្មសិទ្ធិលើប្រាសាទព្រះវិហារ[172]។

កិច្ចការកំណត់ព្រំដែនរបស់គណៈកម្មការបារាំង-សៀមបានប្រព្រឹត្តទៅរហូតដល់ឆ្នាំ១៩០៨។ ប៉ុន្តែ តំបន់ព្រះវិហារមិនត្រូវបានរាប់បញ្ចូលនៅក្នុងការងាររបស់គណៈកម្មការនេះទេ ជាហេតុធ្វើអោយគេគិតថាកិច្ចការកំណត់ព្រំដែនក្នុងតំបន់នោះត្រូវបានអនុវត្តហើយ[173]។ ជារួម ការកំណត់ព្រំដែនប្រព្រឹត្តទៅ *«ក្នុងស្មារតីជឿទុកចិត្តទាំងស្រុង»* យោងតាមលិខិតថ្លែងអំណរគុណរបស់រដ្ឋមន្ត្រីក្រសួងការបរទេសសៀម ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ១៩០៨ ផ្ញើរជូនរដ្ឋមន្ត្រីអាណានិគមបារាំងដែលបានបញ្ជាក់ថា *«ឥរិយាបថ (របស់ជនជាតិបារាំងដែលជាសមាជិកគណៈកម្មការ) ត្រូវបានវាយតម្លៃខ្ពស់ក្រៃលែងនៅក្នុងមជ្ឈដ្ឋានសៀម»*។

ចំណុចចុងក្រោយនៃប្រតិបត្តិការកំណត់ព្រំដែន គឺការរៀបចំ និងបោះពុម្ពផែនទី។ កិច្ចការនេះត្រូវបានអនុវត្តដោយក្រុមការងារមួយ ដែលមានសមាសភាពមន្ត្រីបារាំងចំនួន៤រូប បន្ទាប់ពីសៀមបានលើកសំណើនេះឡើង[174]។ នៅឆ្នាំ១៩០៩ គណៈកម្មការបារាំង-សៀមបានបោះពុម្ពផែនទីចំនួន៧ផ្ទាំង។ ផែនទីមួយក្នុងចំណោមផែនទីទាំងនេះ ពាក់ព័ន្ធនឹងផ្នែកនៃជួរភ្នំដងរែក ដែលមានប្រាសាទព្រះវិហារស្ថិតនៅ (ផែនទីឧបសម្ព័ន្ធ១)។ លើផែនទីនេះដាក់ពយភ្នំព្រះវិហារទាំងមូល ព្រមទាំងតំបន់ជុំវិញប្រាសាទផងដែរនៅក្នុងទឹកដីកម្ពុជា[175]។

ដំណាក់កាលចុងក្រោយ គឺ **ប្រតិបត្តការវាស់ខ្សែបន្ទាត់ខណ្ឌសីមានៅនឹងកន្លែង** (Démarcation) និង**បោះបង្គោលព្រំដែន** (Abornement) ដែលធ្វើឡើងរវាងឆ្នាំ១៩០៨ និង១៩០៩ នៅលើបណ្តោយប្រវែង៨០៣គីឡូម៉ែត្រ ចាប់ពីជួរភ្នំដងរែកនៅទិសខាងជើង (ព្រំដែនជាមួយប្រទេសឡាវ) រហូតដល់ឈូងសមុទ្រថៃ នៅទិសខាងត្បូង។ សរុបមក បង្គោលព្រំដែនចំនួន៧៣ដើម ត្រូវបានបោះនៅតាមព្រំដែនរវាងប្រទេសទាំងពីរ។ ប៉ុន្តែ កំណាត់ព្រំដែនដែលឥតបោះបង្គោល ជួនកាលមានប្រវែង ១០០គីឡូម៉ែត្រងណោះ។ ពេលខ្លះ បង្គោលទាំងនេះបោះនៅលើតម្រុយពុំមានភាពអចិន្ត្រៃយ៍ ដូចជាដើមឈើ ឬដុំថ្មជាដើម។ ដោយយល់ថាតម្រុយទាំងនេះមិនអាចទុកចិត្តបាន គណៈកម្មការព្រំដែនក៏

[172] *C.I.J. Rec.* 1962, p. 20.
[173] *C.I.J. Rec.* 1962, p. 19.
[174] *C.I.J. Rec.* 1962, p. 20.
[175] *C.I.J. Rec.* 1962, p. 21.

បានសង់បង្គោលអំពីបេតុងឆ្អឹងដែក នៅចន្លោះឆ្នាំ១៩១៨ និង១៩១៩ ដើម្បីជំនួសបង្គោលបណ្ដោះអាសន្នដំបូងៗទាំងនេះ។

លោកបណ្ឌិត **សារិន ឆាក** បានគូសបញ្ជាក់ថា ៖

*«ដូច្នេះ ប្រទេសបារាំងត្រូវតែសម្រេចឲ្យបាននូវគោលដៅពីរ ទីមួយគឺធ្វើអោយប្រទេសកម្ពុជា ដែលជាអ្នកទទួលការគាំពារ ទទួលបានទឹកដីដែលគេរំលោភយកទាំងបំពានច្បាប់ និងទីពីរគឺបោះទីតាំងរបស់ខ្លួននៅតាមត្រើយខាងស្ដាំនៃទន្លេមេគង្គកណ្ដាលដើម្បីទប់ទល់នឹងឥទ្ធិពលសៀម»*[176]។

## §៣. ខ្សែបន្ទាត់ព្រំដែនសមុទ្រក្នុងសន្ធិសញ្ញាបារាំងសៀមឆ្នាំ១៩០៤ និង១៩០៧

នាឆ្នាំ១៨៦៩ អ្នករុករកជាតិបារាំង ឈ្មោះ **ហ្វ្រង់ស៊ីស ហ្គានីញេ** (FRANCIS GARNIER) បានបង្កើតផែនទីមួយផ្ទាំង ដែលចង្អុលបង្ហាញព្រំដែនសមុទ្ររបស់ប្រទេសកម្ពុជាត្រឹមកោះគុត។ លើសពីនេះគោលដៅមួយនៃសន្ធិសញ្ញាឆ្នាំ១៩០៤ គឺការកំណត់ព្រំដែនសមុទ្រ។ នាខែកក្កដា ឆ្នាំ១៨៩១ តំណាងជាតិអង់គ្លេសនៅក្រុងបាងកក បានកត់សំគាល់ថា៖

«... *នៅលើបន្ទាត់ឆ្នេរសមុទ្រ ព្រំដែនជាមួយបារាំងពុំទាន់បានកំណត់នៅឡើយទេ។ ជាក់ស្ដែងលើកលែងតែតំបន់នៅក្បែរបឹងធំ (ទន្លេសាប) នៅប៉ែកខាងត្បូង ព្រំដែនពុំទាន់បានកំណត់នៅត្រង់ចំណុចណាមួយនៅឡើយ»*[177]។

គឺសន្ធិសញ្ញាឆ្នាំ១៩០៤នេះហើយ ដែលបង្ហាញយ៉ាងប្រត្យក្សជាលើកដំបូងអំពីគំនូសព្រំដែនរវាងទន្លេសាប និងសមុទ្រ។ សន្ធិសញ្ញាមានកម្មវត្ថុបង្កើតព្រំដែនធម្មជាតិមួយ។ ពិធីសារដែលភ្ជាប់ជាឧបសម្ព័ន្ធនៃសន្ធិសញ្ញាចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩០៤ បានបង្ហាញគំនូសព្រំដែនពីទន្លេសាបទៅសមុទ្រ។ វាក្យខណ្ឌទី១នៃពិធីសារជាឧបសម្ព័ន្ធបានចែងថា៖

«... *ខ្សែបន្ទាត់ព្រំដែននេះបង្កើតជាព្រំដែនធម្មជាតិ ដែលយោងតាមព្រំដែននេះ កំពង់ផែក្រាត (ត្រាត) និងទឹកដីដែលឋិតនៅខាងត្បូងត្រូវប្រគល់ទៅឱ្យឥណ្ឌូចិនបារាំង...។ ជាបច្ច័យ កោះទាំងឡាយណាដែលឋិតនៅជិតឆ្នេរ គិតចាប់ពីជ្រោយឡែមលឹងទៅ (ដូចជាកោះឆាង និងកោះបន្ទបន្ទាប់) ព្រមទាំងទឹកដីឋិតនៅខាងត្បូងព្រំដែនដែលបានកំណត់ដូច្នេះ គឺជាកម្មសិទ្ធិរបស់ឥណ្ឌូចិនបារាំង»*[178]។

---

[176] SARIN CHHAK, *Les frontières du Cambodge, Op. cit.*, p.124.
[177] *British Foreign and State Papers*, Vol. 87, p. 204.
[178] DE CLERCQ, *Recueil des Traité de la France,* tome XXII, p. 451 ; JENNAR (R.), Les frontières du Cambodge contemporain, Thèse, Institut national des langues et civilisations orientales, Paris, 1998.

តាមរយៈសន្ធិសញ្ញាឆ្នាំ១៩០៤ បារាំងបានយកកោះកុង និងខេត្តត្រាតមកអោយកម្ពុជាវិញ ហើយទុកចន្ទតាប៊ុន (ចាន់តាប) អោយសៀម ហើយការធ្វើបែបបនេះ គឺដើម្បីកំណត់សមត្ថកិច្ចរបស់ពួកគេរៀងៗខ្លួននៅក្នុងដែនទឹកនៃឈូងសមុទ្រសៀម ក្រោយពីមានឧប្បត្តិហេតុឆ្នាំ១៩៨៣។ ដូច្នេះ ខេត្តត្រាត ត្រូវបានប្រគល់មកកម្ពុជាវិញ ហើយដែនកំណត់នៃព្រំដែនជាមួយថៃកំណត់យកត្រឹមចំនុចមួយនៃឆ្នេរ ដែលហៅថាជ្រោយឡេមលឹង។ ការប្រគល់ទឹកដីខាងលើនេះគឺជា **សិទ្ធិជាប្រវត្តសាស្រ្ត** របស់កម្ពុជាមកលើតំបន់ត្រាត ដែលនៅមានប្រជាជន កម្ពុជារស់នៅនៅឡើយ។ នៅក្នុងព្រះរាជលិខិតមួយផ្ញើរទៅរេស៊ីដង់ជាន់ខ្ពស់នៅកម្ពុជា ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩០៦ ព្រះចៅក្រុងកម្ពុជា ព្រះបាទ **ស៊ីសុវត្ថ** បានបញ្ជាក់ ថាខេត្តចន្ទតាប៊ុន និងខេត្តក្រាត គឺជាខេត្តបិតក្នុងចំណោមខេត្តរបស់កម្ពុជាដែលសៀមបានកាត់យកទៅ[179]។ ទឹកដីក្រាតបានផ្ទេរមកអោយឥណ្ឌូចិនបារាំង នាថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩០៤។

មាត្រា៣នៃសន្ធិសញ្ញាចែងពីតំបន់ដែលបិតនៅចន្លោះទន្លេសាប និងសមុទ្រ។ អ្នកចរចារជាតិបារាំងមានបំណងទាមទារយកទឹកដីត្រាតមកវិញ ដើម្បីធ្វើជាថ្នូរឱ្យគណៈបក្សអាណានិគមនៅបារាំងយល់ព្រមបោះបង់ចោលខេត្រចន្ទតាប៊ុន។ ពួកគេជឿថា នៅត្រាតនេះមានកំពង់ផែសមុទ្រមួយ [180] ។ ដូច្នេះ ការយកទឹកដីត្រាតអាចបើកផ្លូវឱ្យកម្ពុជាមានច្រកចេញទៅកាន់សមុទ្រ។ **នរោត្តម រណឫទ្ធិ** បានលើកឡើងថា គណៈកម្មការព្រំដែនមានបំណងចង់ប្រែក្លាយទឹកដីត្រាត ទៅជាចំណុចឈានមុខមួយក្នុងឈូងសមុទ្រសៀម និងសាងសង់កំពង់ផែទឹកជ្រៅមួយ[181]នៅកោះឆាង។ យោងតាមសន្ធិសញ្ញាឆ្នាំ១៩០៤ ប្រទេសកម្ពុជាក៏ទទួលបានកោះទាំងអស់ដែលបិតនៅខាងត្បូងជ្រោយឡេមលឹង វិញ ដូចជាកោះឆាង[182] និងកោះគុតជាដើម[183]។ ព្រំដែនសមុទ្ររវាងកម្ពុជា និងសៀម ត្រូវបានដាក់នៅត្រង់កោះឆាង[184]។ នេះគឺជាការប៉ុនប៉ងបែងចែកដែនសមុទ្ររវាងកម្ពុជា និងសៀម។ ប៉ុន្តែ សមាជិករបស់គណៈកម្មការកំណត់ព្រំដែនមានការភ្ញាក់ផ្អើល ដោយសង្កេតឃើញថាកំពង់ផែសមុទ្រនេះបិតនៅលើដីគោកទាំងអស់ ដែលនេះនឹងបង្កឱ្យការលំបាកជៀសពុំរួចចំពោះការធ្វើនាវាចរណ៍ [185] ។ ចំនុចព្រំដែនដែលជាប់ទៅនឹងសមុទ្ររបស់ប្រទេសកម្ពុជា នាឆ្នាំ១៩០៤ គឺបិតនៅជ្រោយឡេមលឹង[186]។

---

179 Archives du Ministère des Colonies – Siam, 107 ; NORODOM RANARIDH, *Op. cit.*, p. 137.
180 BERNARD (Colonel F.), *Op. cit.*, p.175.
181 NORODOM RANARIDH, *Op. cit.*, p. 138.
182 (L :12° ; G : 102°21).
183 (L :11°40 ; G : 102°33).
184 MOUHOT (H.), *Voyage dans les Royaumes de Siam, de Cambodge et de Laos*, Librairie Hachette, Paris, 1868 ; NORODOM RANARIDH, *Op. cit.*, p. 136.
185 *Ibid.*
186 (L : 10°12 ; G : 102°17).

សន្ធិសញ្ញាចុះថ្ងៃទី២៣ មិនា ១៩០៧ក៏មានខនានាស្តីពីព្រំដែនសមុទ្រផងដែរ។ ខទីមួយនៃពិធីសារដែលជាឧបសម្ព័ន្ធនៃសន្ធិសញ្ញាឆ្នាំ១៩០៧បានចែងថា ៖ *«ព្រំដែនរវាងឥណ្ឌូចិនបារាំង និងប្រទេសសៀមផ្តើមចេញពីមាត់សមុទ្រ នៅចំណុចមួយដែលស្ថិតនៅចំពីមុខកំពូលខ្ពស់បំផុតនៃ "កោះគុត" ។ ដោយចេញពីចំណុចនេះ ព្រំដែនដើរឆ្ពោះទៅទិសឦសាន រហូតទៅដល់ខ្សែកំពូលភ្នំ (Crête) ក្រវាញ។ ជាផ្លូវការ ត្រូវបានព្រមព្រៀងគ្នាថា ក្នុងគ្រប់ករណីទាំងអស់ ជំរាលភ្នំខាងកើតនៃភ្នំទាំងអស់នេះ រួមទាំងអាងអូរខ្លួងកោប៉ោទាំងមូលត្រូវនៅជារបស់ឥណ្ឌូចិនបារាំង»* [187] ។ ដូច្នេះ យោងតាមសន្ធិសញ្ញាឆ្នាំ ១៩០៧ ចំនុចចុងក្រោយនៃព្រំដែនគោកនៅសមុទ្រត្រូវដាក់ឱ្យឋិតនៅពីជ្រោយឡែមលឹង (Cap Lem-Ling) ទៅមោងសុតុន (Muong Soton) ទល់មុខកោះគុត ដែលឋិតនៅក្នុងកំណាត់ព្រំដែនទីមួយដែលគណៈកម្មការព្រំដែនចាប់ផ្តើមកិច្ចការរបស់ខ្លួន នាខែតុលា ឆ្នាំ ១៩០៧[188]។ យោងតាមគណៈកម្មការព្រំដែន ចំនុចព្រំដែនគោករបស់កម្ពុជាចាប់ពីឆ្នាំ១៩០៧មក ឋិតនៅចំនុច B' លើផែនទីដែលប្រជាជន អូព្យាម (O-Piam) ដាក់ឈ្មោះឱ្យថា លឹម សារ៉ាផាភីត (Lem Saraphaphit) [189]។ តាមរយៈសន្ធិសញ្ញាឆ្នាំ ១៩០៧ និងពិធីសារជាឧបសម្ព័ន្ធ គណៈកម្មការព្រំដែនបានកំណត់ព្រំដែនសមុទ្ររវាងប្រទេសនេះ និងឥណ្ឌូចិនបារាំង (កម្ពុជា) ជាស្ពានពរក្នុងឈូងសមុទ្រសៀម ដោយខ្សែបន្ទាត់មួយភ្ជាប់កំពូលខ្ពស់ជាងគេរបស់កោះគុត ទៅនឹងចំនុចមួយនៃតំបន់ឆ្នេរដែលឋិតនៅទល់មុខកោះនេះ។

សន្ធិសញ្ញាឆ្នាំ១៩០៧ បានប្រគល់កោះទាំងអស់ដែលឋិតនៅខាងត្បូងជ្រោយឡែមលឹមទៅឱ្យសៀម ក្នុងនោះមានកោះគុតដែរ។ យោងទៅតាមប្រធានគណៈកម្មការព្រំដែនជាតិបារាំង គឺលោកវរសេនីត្រី **ម៉ុងហ្គុយអេ** (MONTGUERS) *«ចំនុចដែលឋិតនៅទល់មុខកំពូលខ្ពស់ជាងគេនៃកោះគុត»* ដែលជាចំណុចចាប់ផ្តើមនៃព្រំដែនរវាងឥណ្ឌូចិនបារាំង និងសៀមឋិតនៅខាងជើងឆក អូព្យាម និងនៅខាងត្បូងនៃកំណាត់ឆ្នេរសមុទ្រមួយ ដែលគេដាក់ឈ្មោះថា ហាត សៃ យៅ (Hat Saï Yao) [190]។ ថ្វីត្បិតតែជ្រោយអូព្យាមជាចំនុចព្រំដែនមួយច្បាស់លាស់ ផ្អែកតាមភូមិសាស្ត្រ ក៏គណៈកម្មការព្រំដែនបានឯកភាពគ្នាជ្រើសយកចំនុច B' មួយទៀត ក្នុងផែនទីដែលភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកំណាត់ហេតុ ដែលមានឈ្មោះថា លឹម សារ៉ាផាតភីត (Lem Saraphat Phit) នៅខាងជើងភូមិអូព្យាម ហើយការជ្រើសយកនេះគឺដោយសារហេតុផលសណ្តាប់ធ្នាប់រដ្ឋបាល។ ជ្រោយនេះគឺជាកំពូលថ្មស្រួចទីពីរដែលគេប្រទះឃើញ

---

187 សន្ធិសញ្ញាធ្វើឡើងនៅថ្ងៃទី២៣ មេសា ១៩០៧ រវាងរដ្ឋាភិបាលនៃសាធារណៈរដ្ឋបារាំង និងរដ្ឋាភិបាលរបស់ស្តេចសៀម។ Archives nationales de France; Centre des Archives d'Outre-mer; Indochine, fonds GGI, dossier 39547 ; BASDEVANT, *Recueil des Traité de la France,* tome XXII, p. 451 ; JENNAR (R.), Les frontières du Cambodge contemporain, Thèse, Institut national des langues et civilisations orientales, Paris, 1998.
188 NORODOM RANARIDH, *Op. cit.*, p. 141.
189 NORODOM RANARIDDH, *Op. cit.*, p. 143.
190 NORODOM RANARIDH, *Op. cit.*, p. 142.

បន្ទាប់ពីឆកខាងជើងនៃភូមិនេះ [191] ។ គំនូសព្រំដែនដែលគណៈកម្មការព្រំដែនស្នើគឺដើរយ៉ាងសុក្រិតបំផុតតាមតែធ្វើទៅបានទៅតាមព្រំប្រទល់ធម្មជាតិ ដែលទាមទារដោយសណ្ឋានដីជាក់ស្តែង ដោយដើរយ៉ាងប្រយ័ត្នប្រយែងទៅតាមជួរកំពូលភ្នំ ច្រកភ្នំ ស្ទឹង ខ្សែបែងចែកទឹក។ល។

ក្នុងខណៈពេលដែលព្រំដែនគោកត្រូវកំណត់ដោយព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ និងនយោបាយព្រំដែន សមុទ្រជាកម្មវត្ថុនៃការកំណត់តាមផ្នែកគតិយុត្តិ តាមរយៈវិធាននានាដែលធ្វើឯកសណ្ឋានកម្មដោយទំនៀមទំលាប់ និងអនុសញ្ញាស្តីពីនីតិសមុទ្រ។ ក្រោយសង្គ្រាមលោកលើកទីពីរ បន្ទាប់ពីខ្ពង់រាបបាតសមុទ្រត្រូវបានលេបយកជាហូរហែរមក អនុសញ្ញាក្រុង **ហ្សឺណែវ** ចុះឆ្នាំ១៩៥៨ បានចាប់ផ្តើមបង្កើតបទដ្ឋានស្តីពីអធិបតេយ្យក្នុងកំណាត់តំបន់សមុទ្រ ហើយជាស្នាដៃដែលអនុសញ្ញា **ម៉ុងតេហ្គោបេយ៍** ឆ្នាំ១៩៨២ ធ្វើរួចរាល់មួយភាគ។ នាឆ្នាំ១៩៥៨ គេទទួលស្គាល់ថា អធិបតេយ្យរដ្ឋជាប់សមុទ្រលាតសន្ធឹងចាប់ពីដែនដីរបស់ខ្លួនរហូតដល់តំបន់ជាប់គ្នាមួយទៀតដែលហៅថា «**សមុទ្រដែនដី**» ដោយគោរពសិទ្ធិមួយចំនួនសម្រាប់រដ្ឋទីបី ដូចជាសិទ្ធិឆ្លងកាត់ដោយមិនបង្កគ្រោះថ្នាក់ (Passage inoffensif) ជាដើម។ អនុសញ្ញាឆ្នាំ១៩៨២ បានអះអាងលើអធិបតេយ្យនេះ ដោយធានាបាននូវខ្សែបន្ទាត់១២ម៉ាលយ៍សមុទ្រជាអតិប្បរមា ចាប់ពីខ្សែបន្ទាត់មូលដ្ឋានដែលគិតបញ្ចូលទាំងស្ថានភាពឆ្នេរ ឬចំណុចដីគោកនៃមាត់សមុទ្រនៅពេលទឹកនាចទាបបំផុត (Laisse de basse mer) ។ **តំបន់តភ្ជាប់** (Zones continguës) និង **តំបន់សេដ្ឋកិច្ចផ្តាច់មុខ** (Zones économiques exclusives) ត្រូវវាស់ចេញពីខ្សែបន្ទាត់មូលដ្ឋាននេះ (Linge de base) ដោយផ្តល់ **សិទ្ធិអធិបតេយ្យ** ដល់ទៅ២៤ និង ២០០ ម៉ាលយ៍សមុទ្រចាប់ពីខ្សែបន្ទាត់មូលដ្ឋានទៅឲ្យ ប្រទេសជាប់ឆ្នេរសមុទ្រ ។ **ខ្ពង់រាបបាតសមុទ្រ** (Plateau continental) នឹងបំពេញបន្ថែមការបែងចែកទាំងនេះ យោងទៅតាមវិធានកំណត់ព្រំដែនសមុទ្រយ៉ាងសាំញ៉ាំ ទោះបីខ្ពង់រាបទាំងមូលមានចម្ងាយរួមប្រវែង២០០ម៉ាលយ៍សមុទ្រក្តី។ ជាទីបញ្ចប់ គួរគូសបញ្ជាក់ថាព្រំដែនអាកាសត្រូវបានកំណត់ដោយយោងទៅតាមព្រំដែនគោក និង **សមុទ្រដែនដី**។ អធិបតេយ្យភាពរដ្ឋមួយនៅក្នុងដែនអាកាសរបស់ខ្លួនមានលក្ខណៈពេញលេញ នៅក្នុងព្រំប្រទល់នៃដែនដីគោក និងសមុទ្រដែនដី។

ទោះយ៉ាងណាប្រាកដជាមានទំនាក់ទំនងមួយរវាងសន្ធិសញ្ញាព្រំដែនគោក និងអ្វីដែលគេហៅថា «**ការពង្រីកលំហសមុទ្រ**» ដោយឥតប្រកែកបាន។ ព្រំដែនគោក និងព្រំដែនសមុទ្រមានទំនាក់ទំនងយ៉ាងជិតស្និទនឹងគ្នា។

---

[191] លិខិតរបស់វរសេនីត្រី **ម៉ុងហ្គូយអេ** (MONTGUERS) ប្រធានគណៈកម្មការព្រំដែនសម្រាប់លោករ៉េស៊ីដង់ជាន់ខ្ពស់នៅកម្ពុជា ភ្នំពេញ ថ្ងៃទី២៥ មិថុនា ១៩០៨។ បណ្ណសារដ្ឋានជាតិនៃកម្ពុជា។ Dossier n° 20106. Document n° 10. Cote D 14 F125, cité par JENNAR (R.), Les frontières du Cambodge contemporain, Thèse, Institut national des langues et civilisations orientales, Paris, 1998។